ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


២២-១០-២០០៩ -ព្រះរាជក្រម នស/រកម/១០០៩/០១៩ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ រវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង ជប៉ុន ៧៩០៧


## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩៧៩

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩៨០

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩៨១

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩៨២

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៩៨៣

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៩៨៤

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៧៩៨៥

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៧៩៨៨

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦៧ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៧៩៩២

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៩៩៣

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៥៦៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៩៩៦


## III. ការិយាល័យក្រសួង

### ធនាគារជាតិ នៃ កម្ពុជា


១៩-១០-២០០៩ -ប្រកាសលេខ ធ៥.០៩.២២៨ ប្រក ស្តីពីការដាក់ឱ្យប្រើប្រាស់មូលប្បទានប័ត្រសង្គងារ របស់ធនាគារជាតិ នៃ កម្ពុជា ៧៩៩៩

១៩-១០-២០០៩ -ប្រកាសលេខ ធ៥.០៩.២៣០ ប្រក ស្តីពីការផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់ ៨០០២

# ព្រះរាជក្រម

នស/រកម/១០០៩/០១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យយោបល់តាមការកំណត់ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
# ស្ដីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាង
# រដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្ដីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាង រដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី *២៦* ខែ *តុលា* ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*នស/រកម.១០០៩/០២៨.១០*

**នរោត្តម សីហមុនី**

*ពរល.០៩១០.១០៣១*

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ ៩៥៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
[illegible]

# កិច្ចព្រមព្រៀង
# ស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិក
# សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន

## មាតិការ


បុព្វកថា

ជំពូក ១ បទប្បញ្ញត្តិទូទៅ

- មាត្រា ១ និយមន័យទូទៅ
- មាត្រា ២ គោលការណ៍
- មាត្រា ៣ គោលបំណង
- មាត្រា ៤ តម្លាភាព
- មាត្រា ៥ ការសម្ងាត់
- មាត្រា ៦ ពន្ធអាករ
- មាត្រា ៧ ការលើកលែងទូទៅ
- មាត្រា ៨ ការលើកលែងផ្នែកសន្តិសុខ
- មាត្រា ៩ ស្ថាប័នមិនមែនរដ្ឋាភិបាល
- មាត្រា ១០ ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងផ្សេងៗ
- មាត្រា ១១ គណៈកម្មាធិការចម្រុះ
- មាត្រា ១២ ការប្រាស្រ័យទាក់ទង

ជំពូក ២ ពាណិជ្ជកម្មទំនិញ

- មាត្រា ១៣ និយមន័យ
- មាត្រា ១៤ ចំណាត់ថ្នាក់ទំនិញ
- មាត្រា ១៥ ប្រព្រឹត្តកម្មជាតិលើពន្ធអាករ និងបទប្បញ្ញត្តិក្នុងស្រុក
- មាត្រា ១៦ ការលុបបំបាត់ ឬការកាត់បន្ថយពន្ធគយ
- មាត្រា ១៧ ការវាយតម្លៃពន្ធគយ

| | | |
|---|---|---|
| | មាត្រា ១៨ | វិធានការមិនមែនពន្ធគយ |
| | មាត្រា ១៩ | ការកែប្រែសម្បទាន |
| | មាត្រា ២០ | វិធានការការពារ |
| | មាត្រា ២១ | វិធានការការពារជញ្ជើងទូទាត់ |
| | មាត្រា ២២ | នីតិវិធីគយ |
| ជំពូក ៣ | | វិធានប្រភពដើម |
| | មាត្រា ២៣ | និយមន័យ |
| | មាត្រា ២៤ | ទំនិញដើមកំណើត |
| | មាត្រា ២៥ | ទំនិញទទួលបានទាំងស្រុង ឬផលិតទាំងស្រុង |
| | មាត្រា ២៦ | ទំនិញមិនទទួលបានទាំងស្រុង ឬផលិតទាំងស្រុង |
| | មាត្រា ២៧ | ការគណនាតម្លៃតំបន់ |
| | មាត្រា ២៨ | អប្បបរមា |
| | មាត្រា ២៩ | ការរួមផ្សំ |
| | មាត្រា ៣០ | ប្រតិបត្តិការមិនគ្រប់លក្ខណៈ |
| | មាត្រា ៣១ | ការបញ្ជូនផ្ទាល់ |
| | មាត្រា ៣២ | សម្ភារៈវេចខ្ចប់ និងកុងតឺណ័រ |
| | មាត្រា ៣៣ | សម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបរណ៍ និងឧបករណ៍បង្ហាញ ឬឧបករណ៍ពតិមានផ្សេងៗ |
| | មាត្រា ៣៤ | វត្ថុធាតុផ្ទាល់ |
| | មាត្រា ៣៥ | វត្ថុធាតុដូចគ្នា និងវត្ថុធាតុដែលអាចប្តូរគ្នាបាន |
| | មាត្រា ៣៦ | នីតិវិធីផ្តល់វិញ្ញាបនប័ត្រប្រតិបត្តិ |
| | មាត្រា ៣៧ | អនុគណៈកម្មាធិការស្តីពីវិធានប្រភពដើម |
| ជំពូក ៤ | | វិធានការអនាម័យ និងភូតគាមអនាម័យ |
| | មាត្រា ៣៨ | វិសាលភាព |
| | មាត្រា ៣៩ | ការអះអាងជាថ្មីអំពីសិទ្ធិ និងកាតព្វកិច្ច |

| | |
|---|---|
| មាត្រា ៤០ | អនុគណៈកម្មាធិការស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ |
| មាត្រា ៤១ | កន្លែងសាកសួរពត៌មាន |
| មាត្រា ៤២ | ការមិនអនុវត្តជំពូកទី ៩ |
| ជំពូក ៥ | ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា |
| មាត្រា ៤៣ | គោលបំណង |
| មាត្រា ៤៤ | វិសាលភាព |
| មាត្រា ៤៥ | ការអះអាងជាថ្មីអំពីសិទ្ធិ និងកាតព្វកិច្ច |
| មាត្រា ៤៦ | សហប្រតិបត្តិការ |
| មាត្រា ៤៧ | កន្លែងសាកសួរពត៌មាន |
| មាត្រា ៤៨ | អនុគណៈកម្មាធិការស្តីពីស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា |
| មាត្រា ៤៩ | ការមិនអនុវត្តជំពូកទី ៩ |
| ជំពូក ៦ | ពាណិជ្ជកម្មសេវាកម្ម |
| មាត្រា ៥០ | ពាណិជ្ជកម្មសេវាកម្ម |
| ជំពូក ៧ | ការវិនិយោគ |
| មាត្រា ៥១ | ការវិនិយោគ |
| ជំពូក ៨ | សហប្រតិបត្តិការសេដ្ឋកិច្ច |
| មាត្រា ៥២ | គោលការណ៍មូលដ្ឋាន |
| មាត្រា ៥៣ | វិស័យសហប្រតិបត្តិការសេដ្ឋកិច្ច |
| មាត្រា ៥៤ | អនុគណៈកម្មាធិការស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច |
| មាត្រា ៥៥ | កម្មវិធីការងារសំរាប់សហប្រតិបត្តិការសេដ្ឋកិច្ច |
| មាត្រា ៥៦ | ធនធានសំរាប់សហប្រតិបត្តិការសេដ្ឋកិច្ច |
| មាត្រា ៥៧ | ការអនុវត្តសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច |
| មាត្រា ៥៨ | ការមិនអនុវត្តជំពូកទី ៩ |

| | |
|---|---|
| ជំពូក ៩ | ការដោះស្រាយវិវាទ |
| មាត្រា ៥៩ | និយមន័យ |
| មាត្រា ៦០ | វិសាលភាពនៃការអនុវត្ត |
| មាត្រា ៦១ | កន្លែងទំនាក់ទំនង |
| មាត្រា ៦២ | ការពិគ្រោះយោបល់ |
| មាត្រា ៦៣ | ការសម្រុះសម្រួល ការផ្សះផ្សា និងសន្ធានកម្ម |
| មាត្រា ៦៤ | ការបង្កើតវេទិកាមជ្ឈត្តការ |
| មាត្រា ៦៥ | សមាសភាពវេទិកាមជ្ឈត្តការ |
| មាត្រា ៦៦ | ភាគីទីបី |
| មាត្រា ៦៧ | មុខងាររបស់វេទិកាមជ្ឈត្តការ |
| មាត្រា ៦៨ | ដំណាក់ការជំរះក្តីរបស់វេទិកាមជ្ឈត្តការ |
| មាត្រា ៦៩ | ការព្រាងសេចក្តីសម្រេច និងសេចក្តីសម្រេច |
| មាត្រា ៧០ | ការព្យួរ និងការបញ្ចប់នីតិវិធី |
| មាត្រា ៧១ | ការអនុវត្តសេចក្តីសម្រេច |
| មាត្រា ៧២ | ការទូទាត់សំណង និងការព្យួរសម្បទាន |
| មាត្រា ៧៣ | សោហ៊ុយចំណាយ |
| ជំពូក ១០ | អវសានបញ្ញត្តិ |
| មាត្រា ៧៤ | មាតិការ ចំណងជើង និងចំណងជើងរង |
| មាត្រា ៧៥ | ការពិនិត្យឡើងវិញ |
| មាត្រា ៧៦ | ឧបសម្ព័ន្ធ និងកំណត់សំគាល់ |
| មាត្រា ៧៧ | វិសោធនកម្ម |
| មាត្រា ៧៨ | ការតម្កល់ទុក |
| មាត្រា ៧៩ | ការចូលជាធរមាន |
| មាត្រា ៨០ | ការដកខ្លួនចេញ និងការបញ្ចប់ |

| | |
|---|---|
| ឧបសម្ព័ន្ធ ១ | កម្មវិធីលុបបំបាត់ និងកាត់បន្ថយពន្ធគយ |
| ឧបសម្ព័ន្ធ ២ | វិធានផលិតផលដោយឡែក |
| ឧបសម្ព័ន្ធ ៣ | ផលិតផលបច្ចេកវិទ្យាពត៌មាន |
| ឧបសម្ព័ន្ធ ៤ | នីតិវិធីផ្តល់នវិញ្ញាបនប័ត្រប្រតិបត្តិ |
| ឧបសម្ព័ន្ធ ៥ | កម្មវិធីការងារសំរាប់សហប្រតិបត្តិការសេដ្ឋកិច្ច |

# បុព្វកថា

រដ្ឋាភិបាលប្រ៊ុយណេដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី រាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជារដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា "អាស៊ាន") និងជប៉ុន

**ដោយរំលឹកឡើងវិញ** នូវសេចក្តីប្រកាសរួមដែលបានចុះហត្ថលេខានៅភ្នំពេញ កម្ពុជា នៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០២ និងក្របខ័ណ្ឌសំរាប់ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងជប៉ុន ដែលបានចុះហត្ថលេខានៅបាលី ឥណ្ឌូណេស៊ី នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៣

**ដោយប្រាថ្នា** ចង់ឱ្យទំនាក់ទំនងរវាងអាស៊ាន និងជប៉ុនកាន់តែស៊ីជំរៅ ដែលត្រូវកសាងនូវជំនឿទុកចិត្ត និងការជឿជាក់ទៅវិញទៅមក នៅលើវិស័យជាច្រើន មិនត្រឹមតែគ្របដណ្តប់ទៅលើតែវិស័យនយោបាយ និងសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែគ្របដណ្តប់ទៅលើវិស័យវប្បធម៌ និងសង្គមផងដែរ

**ដោយបណ្តុះគំនិត** ក្នុងការអភិវឌ្ឍន៍អាស៊ានជាបន្ត តាមរយៈសកម្មភាពសេដ្ឋកិច្ចរវាងរដ្ឋសមាជិកអាស៊ាន និងជប៉ុន និងភាពជឿនលឿនគួរឱ្យកត់សំគាល់អំពីទំនាក់ទំនងសេដ្ឋកិច្ចរវាងអាស៊ាន និងជប៉ុន ដែលបានឆ្លងកាត់រយៈពេល ៣០ ឆ្នាំនៃការផ្សារភ្ជាប់ចំណងសេដ្ឋកិច្ច ដែលបានពង្រីកគ្របដណ្តប់ទៅលើវិស័យកាន់តែច្រើន

**ដោយជឿជាក់ថា** ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងជប៉ុន (ដែលហៅកាត់ថា AJCEP) នឹងពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច បង្កើតទីផ្សារកាន់តែទូលាយ និងកាន់តែមានប្រសិទ្ធិភាព ជាមួយនឹងឱកាសកាន់តែប្រសើរ និងសេដ្ឋកិច្ចមាត្រដ្ឋានកាន់តែធំ និងបង្កើនការទាក់ទាញទុន និងទេពកោសល្យ សំរាប់ផលប្រយោជន៍ទៅវិញទៅមក

**ដោយទទួលស្គាល់** នូវកិច្ចប្រឹងប្រែងជាច្រើនទាំងទ្វេភាគី ទាំងតំបន់ ឆ្ពោះទៅពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរវាងរដ្ឋជាសមាជិកអាស៊ាន និងជប៉ុន នឹងជួយសម្រួលដល់ការសម្រេចបាននូវភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយនេះ

**ដោយចែករំលែក** នូវទស្សនៈថា ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយនេះ អាចទទួលបានអត្ថប្រយោជន៍ពី និងបំពេញបន្ថែមទៅលើសមាហរណកម្មសេដ្ឋកិច្ច និងភាពពេញលេញរបស់អាស៊ាន

**ដោយទទួលស្គាល់** ថែមទៀតនូវការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងដំណាក់កាលផ្សេងៗគ្នា រវាងរដ្ឋសមាជិកអាស៊ាន

**ដោយជឿជាក់ថា** កិច្ចព្រមព្រៀងនេះមានការគ្របដណ្តប់ទៅលើវិស័យនានា ដូចជា ពាណិជ្ជកម្មទំនិញ និងសេវាកម្ម និងវិនិយោគ ដែលជាកត្តាដ៏សំខាន់ដើម្បីឈានទៅធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅអាស៊ីខាងកើត

**ដោយរំលឹកឡើងវិញ** នូវមាត្រា XXIV នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ និងមាត្រា V នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ក្នុងឧបសម្ព័ន្ធ 1A និងឧបសម្ព័ន្ធ 1B នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដែលបានធ្វើឡើងនៅម៉ារ៉ាកេស នាថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៤ (ដែលហៅកាត់ថា "កិច្ចព្រមព្រៀង WTO")

**ដោយទទួលស្គាល់** នូវតួនាទីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ គឺជាកត្តាលីករក្នុងការបង្កើនល្បឿនសេរីភាវូបនីយកម្មតំបន់ និងពិភពលោក នៅក្នុងក្របខណ្ឌនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី

**ដោយអះអាងជាថ្មី** នូវសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗ នៅក្រោមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងពហុភាគី តំបន់ និងទ្វេភាគី និងការរៀបចំផ្សេងៗ និង

**ដោយប្តេជ្ញាចិត្ត** ដើម្បីបង្កើតក្របខ័ណ្ឌច្បាប់មួយសំរាប់ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងបណ្តាភាគី

**បានព្រមព្រៀងដូចតទៅ :**

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១
### និយមន័យទូទៅ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ពាក្យ :

ក- "បណ្តារដ្ឋសមាជិកអាស៊ាន" មានន័យថា ប្រ៊ុយណេដារ៉ូសាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី រាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ខ- "អាជ្ញាធរគយ" មានន័យថា អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបន្ទុកគ្រប់គ្រង និង ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិគយនានា

គ- "បណ្តាថ្ងៃ" មានន័យថា បណ្តាថ្ងៃនៃប្រតិទិន ដែលរួមទាំង ថ្ងៃចុងសប្តាហ៍ និងថ្ងៃសំរាក

ឃ- "GATS" មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ដែលមានចែងក្នុងឧបសម្ព័ន្ធ 1B នៃកិច្ចព្រមព្រៀងអង្គការ WTO

ង- "GATT 1994" មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ ដែលជាឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀង WTO។ សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ឯកសារយោងចំពោះមាត្រានានា នៅក្នុង GATT 1994 មានរួមបញ្ចូលនូវកំណត់សំគាល់ និងបទប្បញ្ញត្តិបន្ថែមផ្សេងៗ ផងដែរ

ច- "ប្រព័ន្ធរួម" ឬ "HS" មានន័យថា ប្រព័ន្ធបរិយាយ និងលេខកូដទំនិញរួម ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ នៃអនុសញ្ញាអន្តរជាតិស្តីពីប្រព័ន្ធបរិយាយ និងលេខកូដទំនិញរួម ដែលបានអនុម័ត និងអនុវត្តដោយបណ្តាភាគី ទៅតាមច្បាប់ក្នុងស្រុករៀងៗខ្លួន

ឆ- "រដ្ឋមាជិកអាស៊ានថ្មី" មានន័យថា ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ជ- "បណ្តាភាគី " មានន័យថា បណ្តារដ្ឋសមាជិកអាស៊ាន ដែលចូលជាធរមាននៅក្នុងកិច្ចព្រមព្រៀងនេះ ជាមួយជប៉ុន

ឈ- "ភាគី" មានន័យថា រដ្ឋសមាជិកអាស៊ានណាមួយ ដែលចូលជាធរមាននៅក្នុងកិច្ចព្រមព្រៀងនេះ ជាមួយ ជប៉ុន។

## មាត្រា ២
## គោលការណ៍

បណ្តាភាគីអះអាងសារជាថ្មីអំពីសារៈសំខាន់នៃការសម្រេចឱ្យបាននូវ AJCEP តាមរយៈកិច្ចព្រមព្រៀងនេះ និងបណ្តាកិច្ចព្រមព្រៀងទ្វេភាគី ឬតំបន់ ឬការរៀបចំផ្សេងៗ និងត្រូវបានណែនាំដោយគោលការណ៍ ដូចខាងក្រោម :

ក- AJCEP ត្រូវចូលរួមដោយរដ្ឋសមាជិកអាស៊ាន និងជប៉ុន និងរួមបញ្ចូលនូវវិស័យជាច្រើន ដោយផ្តោតលើសេរីភាវូបនីយកម្ម ការសម្រួល និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

ខ- ភាពពេញលេញ ភាពរឹងមាំ និងសមាហរណកម្មអាស៊ាន ត្រូវតែរក្សាដើម្បីសម្រេចឱ្យបាននូវ AJCEP

គ-ប្រព្រឹត្តកម្មពិសេស និងដោយឡែក ត្រូវបានផ្តល់ដល់សមាជិកអាស៊ាន ពិសេស ចំពោះសមាជិកអាស៊ានថ្មី ដោយទទួលស្គាល់កម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ចផ្សេងៗគ្នា និងផ្តល់នូវភាពទន់ភ្លន់បន្ថែមជូនរដ្ឋសមាជិកអាស៊ានថ្មី

ឃ-ការទទួលស្គាល់ ត្រូវតែបានផ្តល់ចំពោះប្រការទាំងឡាយនៃសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីវិធានការនានាសំរាប់អនុគ្រោះដល់ប្រទេសអភិវឌ្ឍន៍តិចតួច

ង- ភាពទន់ភ្លន់ គួរត្រូវបានផ្តល់ឱ្យដើម្បីដោះស្រាយលើវិស័យរសេមិតនៅក្នុងរដ្ឋសមាជិកអាស៊ាននីមួយៗ និងជប៉ុន និង

ច-ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព គឺជាកត្តាដ៏សំខាន់នៅក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ

## មាត្រា ៣
## គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះ ដើម្បី :

ក- ធ្វើសេរីភាវូបនីយកម្មជាបណ្តើរៗ និងសម្រួលពាណិជ្ជកម្មទំនិញ និងសេវារវាងបណ្តាភាគី

ខ-កែលម្អឱកាសវិនិយោគ និងធានាការការពារវិនិយោគ និងសកម្មភាពវិនិយោគនៅក្នុងបណ្តាភាគី និង

គ- បង្កើតក្របខណ្ឌសំរាប់បង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងបណ្តាភាគី ដើម្បីគាំទ្រដល់សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ដោយផ្សារភ្ជាប់នូវគម្លាតនៃការអភិវឌ្ឍន៍រវាងរដ្ឋមាជិកអាស៊ាន និងជំរុញពាណិជ្ជកម្ម និងវិនិយោគរវាងបណ្តាភាគី

## មាត្រា ៤
## តម្លាភាព

១- ភាគីនីមួយៗ យោងតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់ខ្លួន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ បទប្បញ្ញត្តិ នីតិវិធីរដ្ឋបាល និងសេចក្តីសំរេចរដ្ឋបាល និងសេចក្តីសំរេចរបស់តុលាការលើការអនុវត្តជាទូទៅ ព្រមទាំង កិច្ចព្រមព្រៀងអន្តរជាតិនានា ដែលភាគីជាសមាជិកមានការពាក់ព័ន្ធ ឬមានឥទ្ធិពលលើការអនុវត្ត និងប្រតិបត្តិការនៃ កិច្ចព្រមព្រៀងនេះ ។

២- ភាគីនីមួយៗត្រូវផ្សព្វផ្សាយជាសាធារណៈនូវឈ្មោះ និងអាស័យដ្ឋាន របស់អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុក ច្បាប់ បទប្បញ្ញត្តិ នីតិវិធីរដ្ឋបាល និងសេចក្តីសំរេចរដ្ឋបាល យោងទៅតាមកថាខ័ណ្ឌ ១ ។

៣- ភាគីនីមួយៗ នៅពេលដែលទទួលបានសំណើពីភាគីមួយផ្សេងទៀត ត្រូវឆ្លើយតបទៅនឹងសំណួរជាក់លាក់របស់ ភាគីស្នើសុំ និងត្រូវផ្តល់ពត៌មានឱ្យភាគីស្នើសុំនោះ បន្ទាប់មកត្រូវផ្តល់ពត៌មានជាភាសាអង់គ្លេសដល់ភាគីស្នើសុំនោះ លើ បញ្ហាដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ ។

## មាត្រា ៥
## ការសម្ងាត់

១- គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតម្រូវឱ្យភាគីមួយផ្តល់នូវពត៌មានសម្ងាត់ ធ្វើការផ្សព្វផ្សាយនូវពត៌មាន សម្ងាត់ដែលនឹងបន្ទុចបង្អាក់ដល់ការអនុវត្តច្បាប់របស់ភាគីនោះ ឬផ្ទុយនឹងផលប្រយោជន៍សាធារណៈ ឬខូចខាតដល់ផល ប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់សហគ្រាសឯកជន ឬសាធារណៈណាមួយឡើយ ។

២- គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយ ដើម្បីតម្រូវឱ្យភាគីមួយផ្តល់នូវពត៌មានពាក់ព័ន្ធទៅនឹង កិច្ចការ និងគណនីរបស់អតិថិជន នៃស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ឡើយ ។

៣- ភាគីនីមួយៗ ដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ត្រូវរក្សាការសម្ងាត់នៃពត៌មានដែលត្រូវបាន ផ្តល់ជាការសម្ងាត់ ដោយភាគីមួយផ្សេងទៀត ស្របទៅតាមកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៦
## ពន្ធអាករ

១- លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ រាល់បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តបានចំពោះរាល់វិធានការពន្ធអាករឡើយ ។

២- គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចនានានៃភាគីណាមួយនៃអនុសញ្ញាស្តីពីពន្ធអាករឡើយ ។ ក្នុងករណីដែលមានភាពផ្ទុយគ្នារវាងកិច្ចព្រមព្រៀងនេះ ហើយបើសមាជិកណាមួយស្ថិតនៅក្រោមអនុសញ្ញាបែបនោះ អនុសញ្ញានោះ ត្រូវលុបលើភាពផ្ទុយគ្នានោះ ។

៣- មាត្រា ៤ និង ៥ ត្រូវអនុវត្តចំពោះវិធានការពន្ធអាករ ក្នុងករណីដែលរាល់បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះអាចអនុវត្តបានចំពោះវិធានការពន្ធអាករទាំងនោះ ។

## មាត្រា ៧
## ការលើកលែងទូទៅ

សំរាប់គោលបំណងនៃជំពូក ២ ដល់ ៥ មាត្រា XX របស់ GATT ១៩៩៤ រួមទាំងការកែប្រែនានា ត្រូវបានបញ្ចូល និងបង្កើតជាផ្នែកមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៨
## ការលើកលែងផ្នែកសន្តិសុខ

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបកស្រាយ ដើម្បី :

(ក) តម្រូវឱ្យភាគីណាមួយផ្តល់ពត៌មានណាមួយ ដែលជាពត៌មានសម្ងាត់ ដែលភាគីនោះចាត់ទុកថាផ្ទុយនឹងផលប្រយោជន៍សំខាន់ៗ ខាងសន្តិសុខរបស់ខ្លួន ឬ

(ខ) រារាំងភាគីណាមួយ ពីការចាត់វិធានណាមួយ ដែលភាគីនោះយល់ថា មានការចាំបាច់សំរាប់ការពារផលប្រយោជន៍ខាងសន្តិសុខសំខាន់ៗ របស់ខ្លួន

(i) ពាក់ព័ន្ធទៅនឹងវត្ថុធាតុដែលអាចផ្ទុះ និងវត្ថុធាតុដែលចេញពីជាតិផ្ទុះទាំងនោះ

(ii) ពាក់ព័ន្ធទៅនឹងចរាចរអាវុធ គ្រាប់រំសេវ និងឧបករណ៍សំរាប់សង្គ្រាម និងការចរាចរបែបនេះ ចំពោះទំនិញ និងវត្ថុធាតុផ្សេងៗ ដែលដឹកជញ្ជូនផ្ទាល់ និងមិនផ្ទាល់ ក្នុងគោលបំណងផ្គត់ផ្គង់ដល់មូលដ្ឋានកងទ័ព

(iii) ដែលធ្វើឡើងចំពោះការការពារហេដ្ឋារចនាសម្ព័ន្ធអាយុជីវិតសាធារណៈ រួមទាំងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ថាមពល និងទឹក ពីការប៉ុនប៉ងធ្វើឱ្យអសកម្ម ឬធ្វើឱ្យខូចខាតនូវហេដ្ឋារចនាសម្ព័ន្ធទាំងនោះដោយចេតនា

(iv) ដែលធ្វើឡើងក្នុងពេលដែលមានគ្រោះអាសន្នក្នុងស្រុក ឬសង្គ្រាម ឬ គ្រោះអាសន្នពាក់ព័ន្ធទៅនឹងទំនាក់ទំនងអន្តរជាតិផ្សេងៗទៀត ឬ

(គ) រារាំងភាគីណាមួយ ដើម្បីប្រើសកម្មភាពណាមួយ អនុលោមទៅតាមកាតព្វកិច្ចនានានៅក្រោមធម្មនុញ្ញរបស់សហប្រជាជាតិសំរាប់ការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ។

## មាត្រា ៩
## ស្ថាប័នមិនមែនរដ្ឋាភិបាល

ដើម្បីបំពេញនូវកាតព្វកិច្ច និងការសន្យានានានៅក្រោមកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗ ត្រូវប្រឹងប្រែងដើម្បីធានានូវការប្រតិបត្តិរបស់ខ្លួនចំពោះស្ថាប័នមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្តសិទ្ធិរបស់ពួកគេដែលផ្តល់ជូនដោយរដ្ឋាភិបាល ឬអាជ្ញាធរ ថ្នាក់កណ្តាល តំបន់ ឬមូលដ្ឋាន នៅក្នុងភាគីនោះ ។

## មាត្រា ១០
## ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងផ្សេងៗទៀត

១- ភាគីនីមួយៗ ធ្វើការអះអាងជាថ្មីនូវសិទ្ធិ និងកាតព្វកិច្ចនានា ចំពោះភាគីមួយផ្សេងទៀត នៅក្រោមកិច្ចព្រមព្រៀង WTO និង/ឬ ចំពោះកិច្ចព្រមព្រៀងផ្សេងៗទៀតដែលភាគីទាំងនោះជាភាគី ។

២- គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបកស្រាយធ្វើឱ្យចុះថយនូវកាតព្វកិច្ចណាមួយរបស់ភាគីណាមួយ ពីការផ្តល់ឱ្យចំពោះភាគីមួយផ្សេងទៀតនៅក្រោមកិច្ចព្រមព្រៀងនានាដែលភាគីទាំងនេះជាភាគី ទោះជាកាតព្វកិច្ចនោះ ផ្តល់ឱ្យភាគីបន្ទាប់នូវប្រព្រឹត្តកម្មអនុគ្រោះប្រសើជាងការផ្តល់នៅក្នុងកិច្ចព្រមព្រៀងនេះក៏ដោយ ។

៣- ក្នុងករណីដែលមានភាពផ្ទុយគ្នារវាងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀង WTO នោះកិច្ចព្រមព្រៀង WTO ត្រូវមានតម្លៃអនុវត្តលើករណីមានភាពផ្ទុយគ្នានោះ។

៤- នៅក្នុងករណីដែលមានភាពផ្ទុយគ្នាណាមួយរវាងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងមួយផ្សេងទៀត ក្រៅពីកិច្ចព្រមព្រៀង WTO ដែលកិច្ចព្រមព្រៀងផ្សេងមួយនោះមានភាគីច្រើនជាងមួយ (១) ជាបណ្តាភាគី ភាគីទាំងនេះត្រូវធ្វើការពិគ្រោះយោបល់ជាបន្ទាន់ជាមួយគ្នា ដើម្បីស្វែងរកដំណោះស្រាយប្រកបដោយការស្រុះស្រួលទៅវិញទៅមក ដោយយកចិត្តទុកដាក់ទៅលើគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ។

៥- ភាគីមួយដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀង WTO ត្រូវអនុវត្តតាមរាល់បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងខាងលើឱ្យស្របទៅនឹងការសន្យាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់ខ្លួន។

## មាត្រា ១១
## គណៈកម្មាធិការចម្រុះ

១- គណៈកម្មាធិការចម្រុះ នឹងត្រូវបង្កើតឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ។

២- មុខងាររបស់គណៈកម្មាធិការចម្រុះ មាន :

(ក) ពិនិត្យឡើងវិញនូវការអនុវត្ត និងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ

(ខ) ផ្តល់របាយការណ៍ទៅបណ្តាភាគី អំពីការអនុវត្ត និងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ

(គ) ពិចារណា និងផ្តល់អនុសាសន៍ ទៅបណ្តាភាគីអំពីវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ

(ឃ) ត្រួតមើល និងសម្របសម្រួលការងាររបស់អនុគណៈកម្មាធិការ ដែលបានបង្កើតក្រោមកិច្ចព្រមព្រៀងនេះ

(ង) អនុម័ត :

(i) បទប្បញ្ញត្តិអនុវត្តន៍ ដែលមានចែងនៅក្នុងវិធាន ១១ នៃ ឧបសម្ព័ន្ធ ៤ និង

(ii) សេចក្តីសម្រេចដ៏សំខាន់ណាមួយ និង

(ច) បំពេញរាល់មុខងារផ្សេងៗទៀត ដែលមានការឯកភាពពីបណ្តាភាគី

៣- គណៈកម្មាធិការចម្រុះ ៖

(ក) ត្រូវបានមានសមាសភាពតំណាងមកពីរដ្ឋជាមាជិកអាស៊ាន និងជប៉ុន និង

(ខ) អាចបង្កើតអនុគណៈកម្មាធិការ និងធ្វើប្រតិភូកម្មរបស់ខ្លួនជូនអនុគណៈកម្មាធិការនេះ

៤- គណៈកម្មាធិការចម្រុះ ត្រូវជួបប្រជុំ ទៅតាមទីកន្លែង និងពេលវេលា ដែលបានឯកភាពដោយបណ្តាភាគី

## មាត្រា ១២
## ការទ្រាស្រ័យទាក់ទង

ភាគីនីមួយៗត្រូវចាត់តាំងអ្នកទទួលទំនាក់ទំនង ដើម្បីសម្រួលដល់ការទាក់ទងរវាងបណ្តាភាគីអំពីបញ្ហាផ្សេងៗនៃកិច្ចព្រមព្រៀងនេះ លើកលែងតែ មានចែងនៅក្នុងមាត្រា ៦១ ។ រាល់ការទំនាក់ទំនងជាផ្លូវការ ត្រូវធ្វើជាភាសាអង់គ្លេស ។

## ជំពូក ២
## ពាណិជ្ជកម្មទំនិញ

## មាត្រា ១៣
## និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យ ៖

(ក) "ពន្ធគយ" មានន័យថា ពន្ធគយ ឬពន្ធនាំចូល និងការយកពន្ធណាមួយ ដែលពាក់ព័ន្ធនឹងការនាំចូលទំនិញ ប៉ុន្តែមិនរាប់បញ្ចូលនូវ ៖

( i ) ការយកពន្ធដែលដូចគ្នានៅនឹងការយកពន្ធក្នុងស្រុក ដោយអនុលោមទៅតាមបទប្បញ្ញត្តិនានាដែលមានចែងក្នុងកថាខ័ណ្ឌ ២ មាត្រា III នៃ GATT ១៩៩៤ ចំពោះទំនិញដូចគ្នាក្នុងស្រុក ឬចំពោះទំនិញដែលបានកែច្នៃ ឬផលិតពីទំនិញនាំចូលនោះទាំងស្រុង ឬដោយផ្នែក

(ii) ការដាក់ពន្ធលើការលក់បង្ខូចតម្លៃ ឬពន្ធប៉ះប៉ូវ ដោយស្របទៅនឹងបទប្បញ្ញត្តិដែលមានចែងក្នុងកថាខ័ណ្ឌ ២ មាត្រា VI នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VI នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ ដែលមានចែងក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀង WTO ឬ

(iii) ថ្លៃឈ្នួល ឬការយកពន្ធណាមួយ ស្មើនឹងតម្លៃសេវាដែលបានផ្តល់

(ខ) "ច្បាប់គយ" មានន័យថា ច្បាប់ និងបទប្បញ្ញត្តិនានា ដែលគ្រប់គ្រង និងអនុវត្ត ដោយអាជ្ញាធរគយរបស់ភាគីនីមួយៗ ពាក់ព័ន្ធទៅនឹងការនាំចូល ការនាំចេញ ការដឹកទំនិញឆ្លងកាត់ ដែលច្បាប់ និងបទប្បញ្ញត្តិទាំងនោះ ទាក់ទងទៅនឹងពន្ធគយ ការយកពន្ធ និងពន្ធអាករផ្សេងៗ ឬទាក់ទងនឹងការហាមឃាត់ ការរឹតត្បិត និងការត្រួតពិនិត្យផ្សេងៗ ដែលស្រដៀងគ្នានេះ ចំពោះចលនានៃការត្រួតពិនិត្យទំនិញនៅក្នុងដែនដីគយនៃភាគីនីមួយៗ

(គ) "តម្លៃពន្ធគយនៃទំនិញ" មានន័យថា តម្លៃទំនិញសំរាប់គោលបំណងនៃការហូតពន្ធ ដោយផ្អែកលើអត្រាពន្ធគយលើទំនិញនាំចូល

(ឃ) "ឧស្សាហកម្មក្នុងស្រុក" មានន័យថា ជាអ្នកផលិតទំនិញដូចគ្នាទាំងស្រុង ឬទំនិញដែលមានការប្រកួតប្រជែងដោយផ្ទាល់ ដែលមានប្រភពដើម្បីចេញពីភាគីមួយ ឬទំនិញទាំងនោះ ដែលមានទិន្នផលជាទំនិញដូចគ្នា ឬ ជាទំនិញមានការប្រកួតប្រជែងដោយផ្ទាល់ ដែលផ្សំជាចំណែកមួយភាគធំនៃផលិតកម្មក្នុងស្រុករបស់ទំនិញទាំងនោះ

(ង) "ទំនិញដើមកំណើត" មានន័យថា ជាទំនិញគ្រប់លក្ខណៈដែលមានដើមកំណើតស្របទៅតាមបទប្បញ្ញត្តិនានា ដែលមានចែងក្នុងជំពូក ៣

(ច) "ការខូចខាតធ្ងន់ធ្ងរ" មានន័យថា ការធ្វើឱ្យមានការចុះខ្សោយទូទៅលើតួនាទីរបស់ឧស្សាហកម្មក្នុងស្រុក

(ឆ) "ការគំរាមកំហែងនៃការខូចខាតធ្ងន់ធ្ងរ" មានន័យថា ការខូចខាតធ្ងន់ធ្ងរ ដោយផ្អែកទៅលើការជាក់ស្តែង និងមិនគ្រាន់តែជាការនិយាយអះអាង ការស្មាន ឬការច្បាស់ក្នុងចិត្តថាអាចកើតឡើងនៅថ្ងៃក្រោយទេ។

### មាត្រា ១៤

### ចំណាត់ថ្នាក់ទំនិញ

ការចាត់ចំណាត់ថ្នាក់ទំនិញ ជាទំនិញពាណិជ្ជកម្មរវាងបណ្តាភាគី ត្រូវស្របតាមប្រព័ន្ធពន្ធរួម ។

### មាត្រា ១៥

### ប្រព្រឹត្តកម្មជាតិលើពន្ធអាករ និងបទប្បញ្ញត្តិក្នុងស្រុក

ភាគីនីមួយៗត្រូវផ្តល់នូវប្រព្រឹត្តកម្មជាតិចំពោះទំនិញរបស់ភាគីនានា អនុលោមទៅតាមមាត្រា III នៃ GATT ១៩៩៤ ដែលជាចុងក្រោយបានបញ្ចូល និងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ទោះជាមានការកែប្រែក៏ដោយ ។

### មាត្រា ១៦

### ការលុបបំបាត់ ឬកាត់បន្ថយពន្ធគយ

១-លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗ ដោយស្របទៅតាមកម្មវិធីដែលមានចែងក្នុងឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀងនេះ ត្រូវលុបបំបាត់ ឬកាត់បន្ថយពន្ធគយរបស់ខ្លួនចំពោះទំនិញដើមកំណើតមកពីបណ្តាភាគីផ្សេងៗទៀត ។ ការលុបបំបាត់ ឬការកាត់បន្ថយបែបនេះ ត្រូវបានអនុវត្តចំពោះទំនិញដើមកំណើតរបស់បណ្តាភាគី ដោយផ្អែកលើមូលដ្ឋានមិនរើសអើង ។

២- បណ្តាភាគី ត្រូវខិតខំអនុវត្តបន្ថែមឆ្ពោះទៅធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញ តាមរយៈការខិតខំប្រឹងប្រែងធ្វើជាឯកតោភាគី ទ្វេភាគី ឬតំបន់ ដោយអនុលោមទៅតាម GATT ១៩៩៤ ។

៣- បណ្តាភាគីអះអាងជាថ្មីថា ដោយអនុលោមតាមមាត្រា ៧ គ្មានអ្វីដែលនៅក្នុងជំពូកនេះ ត្រូវបានបកស្រាយដើម្បីរារាំងភាគីមួយដែលជាភាគីនៃអនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាឆ្លងព្រំដែន នៃកាកសំណល់គ្រោះថ្នាក់ និងការបោះចោលកាកសំណល់ ឬកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនានា ពីការអនុម័ត ឬការចាត់វិធានការណាមួយពាក់ព័ន្ធទៅនឹងកាកសំណល់គ្រោះថ្នាក់ ឬសារធាតុនៃកាកសំណល់គ្រោះថ្នាក់ ដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន អនុលោមទៅតាមកិច្ចព្រមព្រៀងអន្តរជាតិ ឡើយ ។

## មាត្រា ១៧
## ការវាយតម្លៃពន្ធគយ

សម្រាប់គោលបំណងនៃការកំណត់តម្លៃពន្ធគយ ចំពោះទំនិញដែលបានធ្វើពាណិជ្ជកម្មរវាងបណ្តាភាគី រាល់បទប្បញ្ញត្តិដែលមានចែងនៅក្នុងផ្នែកទី ១ នៃកិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VII នៃកិច្ចព្រមព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ នៃឧបសម្ព័ន្ធ 1A របស់កិច្ចព្រមព្រៀង WTO (ដែលហៅកាត់ថា កិច្ចព្រមព្រៀងស្តីពីការវាយតម្លៃពន្ធគយ) នឹងត្រូវអនុវត្ត ទោះជាមានការកែប្រែក៏ដោយ ។

**សំគាល់** : ក្នុងករណីព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀងស្តីពីការវាយតម្លៃពន្ធគយ ត្រូវអនុវត្តដោយយោងទៅតាមបទប្បញ្ញត្តិនៃពិធីសារស្តីពីការចូលជាសមាជិកភាពរបស់ព្រះរាជាណាចក្រកម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ទោះជាមានការកែប្រែក៏ដោយ ។

## មាត្រា ១៨
## វិធានការមិនមែនពន្ធគយ

១- ភាគីនីមួយៗមិនត្រូវបង្កើត ឬរក្សាវិធានការមិនមែនពន្ធគយណាមួយ រួមទាំងការរឹតត្បិតបរិមាណលើការនាំចូលរបស់បណ្តាភាគី ឬលើការនាំចេញ ឬការលក់សំរាប់ការនាំចេញទំនិញណាមួយទៅឱ្យភាគីមួយផ្សេងទៀតឡើយ លើកលែងតែវិធានការទាំងនោះ ត្រូវបានអនុញ្ញាតនៅក្រោមកិច្ចព្រមព្រៀង WTO ។

២- ភាគីនីមួយៗ ត្រូវធានាឱ្យមានតម្លាភាពរាល់វិធានការមិនមែនពន្ធគយ ដែលបានអនុញ្ញាតនៅក្នុងកថាខ័ណ្ឌ ១ រួមទាំងការរឹតត្បិតបរិមាណផងដែរ ។ ភាគីនីមួយៗ ដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ត្រូវធានាឱ្យបាននូវភាពស្របគ្នាពេញលេញនៅនឹងកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រេង WTO ដើម្បីធ្វើឱ្យការកេងប្រវ័ញ្ចផ្នែកពាណិជ្ជកម្ម មានកំរិតអប្បរមាបំផុត ។

## មាត្រា ១៩
## ការកែប្រែសម្បទាន

១- បណ្តាភាគី មិនត្រូវធ្វើមោឃកម្ម ឬធ្វើឱ្យចុះថយនូវសម្បទានណាមួយ នៅក្រោមកិច្ចព្រមព្រៀងនេះឡើយ លើកលែងតែករណីមួយចំនួនដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។

២- ភាគីណាមួយ អាចចរចាជាមួយភាគីដែលខ្លួនចាប់អារម្មណ៍ ដើម្បីការកែប្រែ ឬដកចេញនូវសម្បទានដែលបានផ្តល់រួចហើយនៅក្រោមកិច្ចព្រមព្រៀងនេះ ។ នៅក្នុងការចរចានោះ អាចរួមបញ្ចូលទាំងសំណងកែខែសមស្របចំពោះទំនិញផ្សេងៗ ។ បណ្តាភាគីពាក់ព័ន្ធត្រូវរក្សានូវកំរិតទូទៅនៃសម្បទានទៅវិញទៅមក និងដែលទទួលផលប្រយោជន៍ទៅវិញទៅមក មិនតិចជាងការអនុគ្រោះពាណិជ្ជកម្ម ដែលបានចែងក្នុងកិច្ចព្រមព្រៀងនេះ នៅមុនពេលធ្វើការចរចា។ ដើម្បីឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការចរចា ត្រូវអនុវត្តមាត្រាទី ៧៧ នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ២០
## វិធានការការពារ

១- ភាគីណាមួយ ដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក អាចអនុវត្តវិធានការការពារចំពោះទំនិញដើមកំណើតមួយនៃភាគីផ្សេងៗទៀតបាន ដោយអនុវត្តឱ្យស្របទៅតាមមាត្រា XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីការការពារក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀង WTO ( ដែលហៅថា "កិច្ចព្រមព្រៀស្តីពីការការពារ") ឬមាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម ក្នុងឧបសម្ព័ន 1A នៃកិច្ចព្រមព្រៀង WTO ( ដែលហៅថា "កិច្ចប្រមព្រៀងស្តីពីកសិកម្ម") ។ សកម្មភាពណាមួយដែលធ្វើឡើងអនុលោមទៅតាមមាត្រា XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងការការពារ ឬមាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម គឺមិនត្រូវផ្អែកលើជំពូក៩ នៃកិច្ចព្រមព្រៀងនេះឡើយ ។

២- ភាគីនីមួយៗ មានសេរីភាពក្នុងការអនុវត្តវិធានការការពារ ដែលមានចែងនៅក្នុងមាត្រានេះ (ដែលហៅថាវិធានការការពារ AJCEP) ដោយអនុវត្តនៅកំរិតអប្បបរមាបំផុតនៅក្នុងការការពារ ឬធ្វើការតបស្នងដល់ការប៉ះពាល់ធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកនៃភាគីនោះ និងដើម្បីសម្រួលការកែតម្រូវឱ្យបានសមស្រប ប្រសិនបើមានផលប៉ះពាល់ដល់កាតព្វកិច្ចរបស់ភាគីនោះនៅក្រោមកិច្ចព្រមព្រៀងនេះ រួមទាំងសម្បទានពន្ធគយ ឬប្រសិនបើជាលទ្ធផលនៃការកើតឡើងដោយមិនអាចគិតទុកជាមុនបាន និងជាផលប៉ះពាល់ដល់កាតព្វកិច្ចដែលកើតមានឡើងចំពោះភាគីនោះ

នៅក្រោមកិច្ចព្រមព្រៀងនេះ ដែលទំនិញដើមកំណើតមួយរបស់ភាគីផ្សេងៗ កំពុងត្រូវបាននាំចូលមានបរិមាណកើនឡើងយ៉ាងច្រើនដែលជាទំនិញផលិតនៅបរទេសទាំងស្រុង ឬស្រដៀងគ្នាទៅនឹងទំនិញផលិតក្នុងស្រុក ដែលនៅក្នុងលក្ខខ័ណ្ឌបែបនេះ បានធ្វើឱ្យប៉ះពាល់ ឬគំរាមកំហែងដល់ការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ដោយសារភាគីនាំចូលនោះ បានផលិតទំនិញដូចគ្នា ឬជាទំនិញមានការប្រកួតប្រជែងដោយផ្ទាល់នៅក្នុងប្រទេសនៃភាគីនាំចូលនោះ ។

៣- វិធានការការពារ AJCEP នឹងមិនត្រូវអនុវត្តចំពោះទំនិញដើមកំណើតមកពីភាគីដែលជាសមាជិកអាស៊ានណាមួយឱ្យតែចំណែកនៃការនាំចូលនៃទំនិញពាក់ព័ន្ធនៅក្នុងភាគីនាំចូល មិនលើសពីចំនួនបី (៣) ភាគរយនៃចំនួននាំចូលសរុបពីភាគីផ្សេងៗ ដែលនាំឱ្យភាគីទាំងនោះ មានចំណែកនាំចូលនាំចូលតិចជាងបី (៣) ភាគរយ ដែលជាចំនួនមិនលើសពីប្រាំបួន (៩) ភាគរយ នៃចំនួននាំចូលសរុបនៃទំនិញពាក់ព័ន្ធពីភាគីផ្សេងៗទៀតនោះ ។

៤- ភាគីមួយ មិនត្រូវអនុវត្តវិធានការការពារចំពោះទំនិញដើមកំណើតមួយ ដែលបាននាំចូលដល់កំរិតកំណត់បរិមាណកូតា ដែលបានផ្តល់នៅក្រោមកូតាអត្រាពន្ធគយ ដែលបានអនុវត្តស្របទៅតាមកម្មវិធីរបស់វានៅក្នុងឧបសម្ព័ន្ធ ១ ។

៥- ភាគីមួយដែលប្រើប្រាស់វិធានការការពារ AJCEP អាច :

(ក) ព្យួរការបញ្ចុះពន្ធគយណាមួយលើទំនិញដើមកំណើតនៃបណ្តាភាគីផ្សេងៗ ដែលមានចែងនៅក្នុងជំពូកនេះ ឬ

(ខ) បង្កើនពន្ធគយលើទំនិញដើមកំណើត នៃបណ្តាភាគីផ្សេងៗ ទៅដល់កម្រិតមួយដែលមិនលើសពី :

(i) អត្រាពន្ធអនុវត្តជាតិអនុគ្រោះបំផុត ( ដែលហៅកាត់ថា "អត្រាអនុវត្ត MFN" ) ទៅលើទំនិញមានសុពលភាពចាប់ពីថ្ងៃដែលវិធានការការពារត្រូវបានអនុវត្ត និង

(ii) អត្រាអនុវត្ត MFN លើទំនិញ មានសុពលភាពភ្លាមមុនកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រា ៧៩ ។

៦- (ក) ភាគីមួយអាចអនុវត្តវិធានការការពារ AJCEP បានមួយតែប៉ុណ្ណោះ បន្ទាប់ពីការអង្កេតមួយត្រូវបានធ្វើដោយអាជ្ញាធរមានសមត្ថកិច្ចនានានៃភាគីនោះ ស្របទៅតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រា៣ និងកថាខ័ណ្ឌ ២ នៃមាត្រា ៤ នៃកិច្ចព្រមព្រៀងការការពារ ។

(ខ) ការអង្កេតយោងទៅតាមកថាខ័ណ្ឌរង (ក) ត្រូវបញ្ចប់ឱ្យបានសព្វគ្រប់ក្នុងរយៈពេល (១) ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមអង្កេតដំបូង។

៧- បណ្ណាល័ក្ខខ័ណ្ឌ និងដែនកំណត់ខាងក្រោម ត្រូវអនុវត្តចំពោះវិធានការការពារ AJCEP :

(ក) ភាគីមួយត្រូវជូនដំណឹងជាលាយល័ក្ខអក្សរទៅបណ្តាភាគីផ្សេងៗទៀត អំពី :

(i) ការស៊ើបអង្កេតដែលមានចែងនៅក្នុងកថាខ័ណ្ឌរង ៦ (ក) ពាក់ព័ន្ធទៅនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬគំរាមកំហែងថាមានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងមូលហេតុផ្សេងៗទៀតពាក់ព័ន្ធនឹងបញ្ហានោះ

(ii) ការស្វែងរកអង្គហេតុពីការគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬការគំរាមកំហែងនៃការគ្រោះថ្នាក់ធ្ងន់ធ្ងរដែលបណ្តាលមកពីការកើនឡើងនៃការនាំចូល និង

(iii) ធ្វើការសំរេចចិត្តក្នុងការអនុវត្ត ឬពន្យារពេលសំរាប់ការអនុវត្តវិធានការការពារ AJCEP ។

(ខ) ភាគីដែលផ្តល់នូវការជូនដំណឹងជាលាយល័ក្ខអក្សរយោងតាមកថាខ័ណ្ឌ (ក) ត្រូវផ្តល់ជូនបណ្តាភាគីនូវបណ្តាពត៌មានសមហេតុផល ដែលត្រូវរួមមាន :

(i) ការជូនដំណឹងជាលាយលក្ខ័អក្សរយោងទៅតាមកថាខ័ណ្ឌ (ក)(i) ដោយបញ្ជាក់ពីមូលហេតុនៃការស៊ើបអង្កេត បរិយាយច្បាស់លាស់អំពីទំនិញដើមកំណើតមួយផ្អែកលើការស៊ើបអង្កេត និងលេខពន្ធគយធំ និងលេខពន្ធគយរង នៃប្រព័ន្ធរួម ដោយផ្អែកលើកម្មវិធីរបស់វានៅក្នុងឧបសម្ព័ន្ធ១ រយៈពេលនៃការស៊ើបអង្កេត និងកាលបរិច្ឆេទការចាប់ផ្តើមការស៊ើបអង្កេត និង

(ii) ការជូនដំណឹងជាលាយលក្ខ័អក្សរ យោងទៅតាមកថាខ័ណ្ឌ (ក)(i) និង (iii) ដោយបញ្ជាក់ពីភស្តុតាងនៃគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬការគំរាមកំហែងដែលឱ្យមានការគ្រោះថ្នាក់ធ្ងន់ធ្ងរបណ្តាលមកពីការកើនឡើងនៃការនាំចូលនៃទំនិញដើមកំណើត ផ្អែកទៅលើវិធានការដែលបានស្នើឡើង និងអំពីលេខពន្ធគយធំ និងលេខពន្ធគយរងនៃប្រព័ន្ធរួមនៃទំនិញនោះ ផ្អែកលើកម្មវិធីនៅក្នុងឧបសម្ព័ន្ធ ១ បរិយាយច្បាស់លាស់ពីវិធានការការពារ AJCEP និងកាលបរិច្ឆេទដែលបានស្នើនៃការចាប់ផ្តើមអនុវត្ត និងរយៈពេលរំពឹងទុកជាមុន នៃការអនុវត្តវិធានការនេះ ។

(គ) ភាគីមួយដែលស្នើសុំឱ្យមានការអនុវត្ត ឬពន្យារវិធានការការពារ AJCEP មួយ ត្រូវផ្តល់ឱកាសគ្រប់គ្រាន់សំរាប់ការពិគ្រោះយោបល់ជាមុនជាមួយបណ្តាភាគី ដែលអាចរងការប៉ះពាល់វិធានការការពារ AJCEP ដើម្បីពិនិត្យឡើងវិញនូវពត៌មានដែលកើតឡើងពីការស៊ើបអង្កេតដែលមានចែងនៅក្នុងកថាខ័ណ្ឌ (ក) ដើម្បីធ្វើការផ្លាស់ប្តូរយោបល់អំពីវិធានការការពារ AJCEP និងដើម្បីឈានទៅសំរេចការព្រមព្រៀងស្តីពីសំណងទូទាត់ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៨។

(ឃ) គ្មានវិធានការពារ AJCEP ណាត្រូវបានរក្សា លើកលែងតែការពន្យាពេល និងសំរាប់ប្រើប្រាស់នៅលើស្ថានភាពចាំបាច់ដើម្បីការពារ ឬជួសជុលគ្រោះថ្នាក់ធ្ងន់ធ្ងរ និងដើម្បីសម្រួលដល់ការកែតម្រូវស្ថានភាព ដែលរយៈពេលជាក់វិធានការមិនត្រូវឱ្យលើសពី (៣) ឆ្នាំ ឡើយ។ វិធានការការពារ AJCEP មួយអាចពន្យារបានលុះត្រាតែ បំពេញបានតាមលក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រានេះ។ រយៈពេលសរុបសំរាប់ការអនុវត្តវិធានការការពារ AJCEP រួមមានទាំងការពន្យារផងនោះ មិនត្រូវឱ្យលើសពី ៤ ឆ្នាំឡើយ។ ដើម្បីជួយសម្រួលដល់ការកែតម្រូវនៅក្នុងស្ថានភាពមួយ ដែលរយៈពេលរំពឹងទុកនៃវិធានការការពារ AJCEP លើសពី (១) ឆ្នាំ ភាគី ដែលធ្វើការរក្សានូវវិធានការការពារ AJCEP ត្រូវធ្វើសេរីភាវូបនីយកម្មជាបណ្តើៗ នូវវិធានការការពារ AJCEP ក្នុងចន្លោះពេលជាក់ស្តែងមួយ ក្នុងអំឡុងពេលនៃការអនុវត្ត។

(ង) គ្មានវិធានការការពារ AJCEP ណាត្រូវបានអនុវត្ត ដើម្បីប្រឆាំងទៅនឹងការនាំចូលទំនិញដើមកំណើតជាក់លាក់ណាមួយ ដែលសមស្របទៅនឹងវិធានការការពារ AJCEP បែបនេះ ដែលមានរយៈពេលដូចគ្នាទៅនឹងវិធានការការពាមុន ឬ (១) ឆ្នាំ ឬយូរជាងនេះក៏ដោយ។

(ច) នៅពេលដែលបញ្ចប់វិធានការការពារ AJCEP ទៅលើទំនិញមួយ អត្រាពន្ធគយសំរាប់ទំនិញនោះត្រូវជាអត្រាពន្ធគយដែលបានប្រើប្រាស់មុនពេលវិធានការការពា AJCEP កើតឡើង ដោយអនុលោមទៅតាមកម្មវិធីរបស់ភាគីដែលធ្វើការអនុវត្តវិធានការពារ AJCEP ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ១។

៨- (ក) ភាគីមួយស្នើអនុវត្ត ឬពន្យារវិធានការការពារ AJCEP ត្រូវផ្តល់នូវមធ្យោបាយគ្រប់គ្រាន់ដោយមានការយល់ព្រមទៅវិញទៅមកអំពីសំណងទូទាត់ពាណិជ្ជកម្ម មានទម្រង់ដូចគ្នាទៅនឹងកិរិតនៃសម្បទាន ឬកាតព្វ

កិច្ចផ្សេងៗ ដែលមានស្រាប់នៅក្រោមកិច្ចព្រមព្រៀងនេះ រវាងភាគីស្នើសុំអនុវត្តវិធានការការពារ និងបណ្តាភាគីនាំចេញ ដែលអាចរងនូវការប៉ះពាល់ដោយសារការអនុវត្តវិធានការបែបនេះ ។

(ខ) ក្នុងការស្វែងរកនូវសំណងទូទាត់ ដែលមានចែងនៅក្នុងកថាខ័ណ្ឌរង (ក) បណ្តាភាគីត្រូវធ្វើការពិគ្រោះយោបល់នៅក្នុងគណៈកម្មាធិការចម្រុះ ។ បណ្តឹងណាមួយដែលកើតមានឡើងពីការពិគ្រោះយោបល់ទាំងនោះ ត្រូវតែបញ្ចប់ក្នុងរយៈពេល (៣០) ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែលវិធានការការពារ AJCEP ត្រូវបានប្រើប្រាស់ ។

(គ) ប្រសិនគ្មានការព្រមព្រៀងអំពីការទូរទាត់សំណងក្នុងរយៈពេលដែលមានបញ្ជាក់នៅក្នុងកថាខ័ណ្ឌរង(ខ) បណ្តាភាគីផ្សេងទៀត ក្រៅពីការអនុវត្តវិធានការការពារ AJCEP ត្រូវមានសេរីភាពក្នុងការព្យួរសម្បទានពន្ធគយនៅក្រោមកិច្ចព្រមព្រៀងនេះ ដែលមានប្រសិទ្ធិភាពស្មើនឹងវិធានការការពារ AJCEP ស្តីពីទំនិញដើមកំណើតរបស់ភាគីដែលប្រើប្រាស់វិធានការការពារ AJCEP ។ បណ្តាភាគីអាចព្យួរការផ្តល់សម្បទានសំរាប់តែរយៈពេលចាំបាច់ជាអប្បបរិមា ដើម្បីទប់ទល់ទៅនឹងការប៉ះពាល់ឱ្យបានសម្រេច និងនៅក្នុងអំឡុងពេលដែលវិធានការការពារ AJCEP នៅមានសុពលភាពតែប៉ុណ្ណោះ ។ សិទ្ធិនៃការពន្យាសុពលភាពដែលមានចែងនៅក្នុងកថាខ័ណ្ឌរងនេះ មិនត្រូវអនុវត្តឱ្យលើសពីរយៈពេល (២) ឆ្នាំដំបូង ចាប់ពីពេលដែលវិធានការ AJCEP មួយចូលជាធរមាន ហើយការអនុវត្តនូវវិធានការការពារ AJCEP នេះ គឺដោយសារកាកើនឡើងនូវការនាំចូលយ៉ាងពេលទំហឹង ហើយវិធានការពារ AJCEP នេះ ត្រូវធ្វើឱ្យស្របទៅតាមបទប្បញ្ញត្តិនៃមាត្រានេះ ។

៩- (ក) ភាគីមួយដែលកំពុងអនុវត្តវិធានការការពារ ដែលផ្សាភ្ជាប់ទៅនឹងការនាំចូលនៃទំនិញដើមកំណើតពីភាគីផ្សេងទៀត ទៅតាមមាត្រា XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីវិធានការការពារ ឬមាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម មិនត្រូវប្រើវិធានការការពារ AJCEP ចំពោះការនាំចូលនោះបានឡើយ ។

(ខ) ក្នុងរយៈពេលនៃការអនុវត្តវិធានការការពារដែលមានចែងនៅក្នុងកថាខ័ណ្ឌរង ៧ (ឃ) ភាគីអនុវត្តមិនត្រូវបានរំខាន ដោយភាគីដែលមិនមែនជាអ្នកអនុវត្តវិធានការការពារ AJCEP ឡើយ យោងតាមកថាខ័ណ្ឌរង (ក) ។

១០- (ក) ក្នុងរយៈពេលដប់ (១០) ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ អនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រា ៧៩ បណ្តាភាគីត្រូវពិនិត្យមាត្រានេះឡើងវិញ ក្នុងបំណងដើម្បីកំណត់ថា តើមានការចាំបាច់ក្នុងការរក្សាយន្តការការពារ AJCEP នេះទេ។

(ខ) ប្រសិនបើបណ្តាភាគីមិនមានការឯកភាពឱ្យដកចេញយន្តការការពារ AJCEP ក្នុងដំណាក់កាលពិនិត្យឡើងវិញ យោងទៅតាមកថាខ័ណ្ឌរង (ក) បន្ទាប់ពីនោះ បណ្តាភាគីត្រូវបង្កើតការពិនិត្យឡើងវិញឱ្យបានញឹកញាប់ដើម្បីកំណត់ភាពចាំបាច់នៃយន្តការការពារ AJCEP ជាមួយគ្នានឹងពិនិត្យឡើងវិញទូទៅ អនុលោមទៅតាមមាត្រា ៧៥ ។

១១- (ក) ក្នុងកាលៈទេសៈចាំបាច់ ដែលការពន្យារអាចនាំឱ្យខូចខាតពិបាកជួសជុលបាន ភាគីមួយអាចអនុវត្តបទប្បញ្ញត្តិវិធានការការពារបណ្តោះអាសន្ន AJCEP ដែលត្រូវយកតាមទម្រង់ដូចវិធានការដែលមានចែងនៅក្នុងកថាខ័ណ្ឌរង ៥ (ក) ឬ ៥ (ខ) អនុលោមទៅតាមការកំណត់បឋម ដែលវាជាភស្តុតាងយ៉ាងច្បាស់លាស់ថា ការកើនឡើងការនាំចូលទំនិញដើមកំណើតមួយ ជាមូលហេតុ ឬកំពុងគំរាមកំហែងបង្កឱ្យមានការគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ។

(ខ) ភាគីមួយ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរទៅបណ្តាភាគីដទៃទៀត មុនពេលធ្វើការអនុវត្តវិធានការការពារបណ្តោះអាសន្ន AJCEP ។ ការពិគ្រោះយោបល់ដោយភាគីនានា នៅក្នុងគណកម្មាធិការចម្រុះ អំពីការអនុវត្តវិធានការការពារបណ្តោះអាសន្ន AJCEP ត្រូវចាប់ផ្តើមធ្វើជាបន្ទាន់ បន្ទាប់ពីវិធានការការពារបណ្តោះអាសន្ន AJCEP ត្រូវបានអនុវត្ត ។

(គ) រយៈពេលនៃវិធានការការពារបណ្តោះអាសន្ន AJCEP មិនត្រូវលើសពីពីររយៈពេល (២០០) ថ្ងៃ។ ក្នុងរយៈពេលនោះ តម្រូវការពាក់ព័ន្ធនានានៃកថាខ័ណ្ឌ ៦ ត្រូវតែបានបំពេញ។ ក្នុងរយៈពេលនៃការអនុវត្តវិធានការការពារបណ្តោះអាសន្ន AJCEP ត្រូវបានរាប់បញ្ចូលជាផ្នែកមួយនៃរយៈពេលដែលមានចែងនៅក្នុងកថាខ័ណ្ឌរង ៧ (ឃ) ។

(ឃ) កថាខ័ណ្ឌ ៣ និងកថាខ័ណ្ឌរង ៧ (ច) ត្រូវអនុវត្តចំពោះវិធានការការពារបណ្តោះអាសន្ន AJCEP ទោះជាមានការកែប្រែក៏ដោយ ។

(ង) ពន្ធគយដែលបានដាក់ ដោយសារការអនុវត្តវិធានការការពារបណ្តោះអាសន្ន AJCEP ត្រូវបានសងវិញ ប្រសិនបើការស៊ើបអង្កេតជាបន្តបន្ទាប់ ដោយយោងលើចំណុច ៦ (ក) រកឃើញថា មិនមានការកើនឡើងនៃការនាំចូលទំនិញដើមកំណើត ដែលបង្ក ឬគំរាមកំហែងបណ្តាលឱ្យខូចខាតធ្ងន់ធ្ងរ ដល់ឧស្សាហកម្មក្នុងស្រុកទេ។

១២- រាល់ការទំនាក់ទំនង និងផ្លាស់ប្តូរឯកសារផ្លូវការរវាងបណ្តាភាគី ដែលពាក់ព័ន្ធទៅនឹងវិធានការការពារ AJCEP ត្រូវធ្វើឡើងជាលាយលក្ខអក្សរ និងជាភាសាអង់គ្លេស។

## មាត្រា ២១
## វិធានការការពារជញ្ជីងទូទាត់

គ្មានអ្វីដែលនៅក្នុងជំពូកនេះត្រូវបានបកស្រាយ ដើម្បីការពារភាគីមួយពីការប្រើវិធានការ សំរាប់គោលបំណងជញ្ជីងទូទាត់ឡើយ។ ភាគីមួយដែលប្រើវិធានការទាំងនោះ ត្រូវគោរពទៅតាមលក្ខខណ្ឌនានាដែលមានចែងនៅក្នុងមាត្រា XII នៃ GATT ១៩៩៤ និងមានការយល់ដឹងអំពីបទប្បញ្ញត្តិស្តីពីជញ្ជីងទូទាត់នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀង WTO ។

## មាត្រា ២២
## នីតិវិធីគយ

១- ភាគីនីមួយៗត្រូវប្រឹងប្រែងអនុវត្តនីតិវិធីគយរបស់ខ្លួន តាមដែលអាចព្យាករណ៍បាន ដោយខ្ជាប់ខ្ជួន និងតម្លាភាព។

២- ដោយទទួលស្គាល់នូវសារៈសំខាន់នៃការបង្កើនតម្លាភាពក្នុងវិស័យនីតិវិធីគយ ភាគីនីមួយៗ យោងទៅលើច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន និងធនធានដែលមាន ត្រូវប្រឹងប្រែងផ្តល់នូវព័ត៌មានទាក់ទងទៅនឹងបញ្ហាជាក់លាក់នានា ដែលបានស្នើឡើងដោយអ្នកដែលចាប់អារម្មណ៍នៃបណ្តាភាគីទាក់ទងទៅនឹងច្បាប់គយ។ ភាគីនីមួយៗ មិនត្រឹមតែត្រូវផ្តល់នូវព័ត៌មានទាំងនោះទេ ប៉ុន្តែត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធផ្សេងៗទៀតដែលខ្លួនគិតថា បុគ្គលដែលចាប់អារម្មណ៍គួរត្រូវយល់ដឹង។

៣- ដើម្បីជម្រុះការត្រួតពិនិត្យគយឱ្យបានលឿន នៃទំនិញដែលបានធ្វើពាណិជ្ជកម្មរវាងភាគីនានា ភាគីនីមួយៗ ដោយទទួលស្គាល់ពីតួនាទីដ៏សំខាន់នៃអាជ្ញាធរគយ និងសារៈសំខាន់នៃនីតិវិធីគយក្នុងការជំរុញការសម្រួលពាណិជ្ជកម្ម ត្រូវប្រឹងប្រែង :

(ក) ធ្វើឱ្យងាយស្រួលនូវនីតិវិធីគយ និង

(ខ) ធ្វើឱ្យស្របគ្នានូវប្រព័ន្ធនីតិវិធីគយ ឱ្យបានប្រសើបំផុតប្រសិនបើអាចធ្វើទៅបាន ដែលសមស្របទៅនឹងស្តង់ដារអន្តរជាតិ និងរបៀបអនុវត្តប្រសើរៗ ដូចជា នីតិវិធីគយនៅក្រោមក្រុមប្រឹក្សាសហប្រតិបត្តិការគយជាដើម ។

## ជំពូក ៣
## វិធានប្រភពដើម

### មាត្រា ២៣
### និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យ :

(ក) "អ្នកនាំចេញ" មានន័យថា ជារូបវន្តបុគ្គលឬ នីតិបុគ្គល ដែលមានទីតាំងនៅក្នុងភាគីនាំចេញ ដែលជាអ្នកនាំចេញទំនិញ ពីភាគីនាំចេញ

(ខ) "នាវារោងចក្រនៃភាគី" ឬ "នាវានៃភាគី" មានន័យថា បណ្តានាវារោងចក្រ និងបណ្តានាវា :

(i) ដែលត្រូវបានចុះបញ្ជីក្នុងដែនដីនៃភាគី

(ii) ដែលបើកបរក្រោមទង់ជាតិនៃភាគី

(iii) ដែលមានយ៉ាងហោចណាស់ហាសិប (៥០) ភាគរយ កាន់កាប់ដោយបណ្តាជនជាតិ នៃភាគីមួយ ឬច្រើននៃបណ្តាភាគី ឬដោយនីតិបុគ្គលមួយរូប ដែលមានការិយាល័យមេនៅក្នុងភាគីមួយ ដែលក្នុងនោះមានតំណាងនានា មានប្រធានក្រុមប្រឹក្សានាយក ហើយសមាជិកភាគច្រើននៃក្រុមប្រឹក្សានេះ

គឺជាបណ្តាជនជាតិនៃភាគី១ ឬច្រើននៃបណ្តាភាគី ហើយដែលមានភាគហ៊ុនយ៉ាងហោចណាស់ (៥០) ភាគរយកាន់កាប់ដោយបណ្តាជនជាតិ ឬបណ្តានីតិបុគ្គលនៃភាគីមួយ ឬច្រើននៃបណ្តាភាគី និង

(iv) ដែលមានយ៉ាងតិច (៧៥) ភាគរយ នៃចំនួនសរុបនៃអ្នកគ្រប់គ្រង មន្ត្រី និងនាវិក ជាជនជាតិនៃភាគីមួយ ឬច្រើននៃបណ្តាភាគី

(គ) "គោលការណ៍គណនេយ្យទទួលស្គាល់ទូទៅ " មានន័យថា ការទទួលស្គាល់រួម ឬមានការគាំទ្រពេញលេញពីអាជ្ញាធរនៅក្នុងភាគីមួយ ចំពោះការកត់ចំណូល ចំណាយ តម្លៃ ទ្រព្យសម្បត្តិ និងបំណុល ការផ្សព្វផ្សាយពត៌មាន និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនានា។ ស្តង់ដារទាំងនេះ អាចជាត្រីវិស័យបង្ហាញផ្លូវយ៉ាងទូលំទូលាយសំរាប់ការអនុវត្តជាទូទៅ ព្រមទាំង បកស្រាយលំអិតអំពីស្តង់ដារ ការអនុវត្ត និងនីតិវិធីផ្សេងៗ

(ឃ) "ទំនិញ" មានន័យថា ទំនិញ ផលិតផល ឬវត្ថុធាតុអ្វីមួយ

(ង) "វត្ថុធាតុដូចគ្នា និងវត្ថុធាតុអាចផ្លាស់ប្តូរគ្នាបាន" មានន័យថា វត្ថុធាតុដែលមានប្រភេទដូចគ្នា និងមានគុណភាពពាណិជ្ជកម្មដូចគ្នា មានបច្ចេកទេស និងរូបរាងដូចគ្នា ហើយនៅពេលដែលវត្ថុធាតុទាំងនោះបញ្ចូលជាទំនិញ គេមិនអាចញែកភាពខុសគ្នាពីមួយទៅមួយ សំរាប់គោលបំណងនៃការចំណាំអំពីដើមកំណើតបានឡើយ។

(ច) "អ្នកនាំចូល" មានន័យថា ជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលនាំចូលទំនិញមកពីភាគីនាំចូល

(ឆ) "វត្ថុធាតុដើម" មានន័យថា រូបធាតុណាមួយ ឬសារធាតុដែលបានប្រើប្រាស់ ឬប្រើប្រាស់ទៅក្នុងការផលិតទំនិញ ដែលមានរូបរាងរលាយចូលជាមួយទំនិញ ឬប្រើសំរាប់ផលិតទំនិញមួយផ្សេងទៀត

(ជ) "ទំនិញដើមកំណើត ឬ វត្ថុធាតុដើមដើមកំណើត " មានន័យថា ទំនិញ ឬវត្ថុធាតុដែលចាត់ទុកជាដើមកំណើត ដែលមានចែងនៅក្នុងបណ្តាបទប្បញ្ញត្តិនៃជំពូកនេះ

(ឈ) "សម្ភារៈវេចខ្ចប់ និងកុងតឺណ័រសំរាប់ដឹកជញ្ជូន និងដាក់នាវា" មានន័យថា ជាទំនិញដែលប្រើសំរាប់ការពារទំនិញមួយ ក្នុងអំឡុងពេលដឹកជញ្ជូន និងដាក់នាវា ដែលមានលក្ខណៈខុសគ្នាអំពី កុងតឺណ័រសំរាប់ដាក់ទំនិញ និងវត្ថុធាតុសំរាប់លក់រាយ

(ញ) "ប្រព្រឹត្តកម្មអនុគ្រោះពន្ធគយ" មានន័យថា អត្រាពន្ធគយដែលប្រើចំពោះទំនិញដើមកំណើតពីភាគីនាំចេញ យោងទៅតាមកថាខ័ណ្ឌ ១ នៃមាត្រា ១៦ និង

(ដ) "ផលិតផល" មានន័យថា វិធីសាស្រ្តនៃការទទួលបានជាទំនិញ រួមទាំងដាំដុះ ការជីករ៉ែ ច្រូតកាត់ ចិញ្ចឹម បង្កាត់ពូជ ចំរាញ់ចេញ ប្រមូលផល ជ្រើសរើស ចាប់ នេសាទ លម្អ បរបាញ់ ផលិតកម្ម កែច្នៃ ឬតម្លើង។

## មាត្រា ២៤
## ទំនិញដើមកំណើត

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ទំនិញដែលគ្រប់លក្ខណៈជាទំនិញមានដើមកំណើតពីភាគី មួយ ប្រសិនបើវាៈ

(ក) ទទួលបានទាំងស្រុង ឬផលិតទាំស្រុង នៅក្នុងភាគីដែលមានចែងនៅក្នុងមាត្រា ២៥

(ខ) បំពេញបានទៅនឹងតម្រូវការនៅក្នុងមាត្រា ២៦ នៅពេលប្រើប្រាស់វត្ថុធាតុមិនមែនដើមកំណើត

(គ) ត្រូវបានផលិតទាំងស្រុងនៅក្នុងភាគីផ្ដាច់មុខ ពីវត្ថុធាតុដើមកំណើតនៃភាគីមួយ ឬច្រើននៃ បណ្ដាភាគី និងបំពេញបានទូវរាល់តម្រូវការអនុវត្តផ្សេងៗ នៅក្នុងជំពូកនេះ។

## មាត្រា ២៥
## ទំនិញទទួលបានទាំងស្រុង ឬផលិតទាំងស្រុង

សម្រាប់គោលបំណងនៃកថាខ័ណ្ឌ (ក) នៃមាត្រា ២៤ ខាងក្រោមនេះ ត្រូវបានចាត់ទុកជាទំនិញទទួលបានទាំងស្រុង ឬ ផលិតទាំងស្រុង នៅក្នុងភាគីមួយ :

(ក) រុក្ខជាតិ និងផលិតផលពីរុក្ខជាតិដាំដុះ និងច្រូតកាត់ បេះ ឬប្រមូល នៅក្នុងភាគី

**កំណត់សម្គាល់** : សម្រាប់គោលបំណងនៃកថាខ័ណ្ឌនេះ ពាក្យថា "រុក្ខជាតិ" សំដៅទៅលើរុក្ខជាតិដែលមានជីវិតទាំងអស់រួមទាំង ផ្លែឈើ ផ្កា បន្លែ ដើមឈើ សារាយសមុទ្រ ផ្សិត និងរុក្ខជាតិមានជីវិត។

(ខ) សត្វរស់ដែលកើត និងចិញ្ចឹមនៅក្នុងភាគី

**កំណត់សម្គាល់** : សំរាប់គោលបំណងនៃកថាខ័ណ្ឌ (ខ) និង (គ) ពាក្យថា "សត្វ" គ្រប ដណ្តប់គ្រប់សត្វដែលមានជីវិតទាំងអស់ រួមមានទាំងសត្វចិញ្ចឹមកូនដោយទឹកដោះ សត្វស្លាប ត្រី សត្វវង្គសត្វ សិប្បសត្វ ល្អូន បាក់តេរី និង មេរោគ។

(គ) ទំនិញដែលបានមកពីសត្វរសស់នៅក្នុងភាគី

(ឃ) ទំនិញដែលបានមកពីការបរបាញ់ ដាក់អន្ទាក់ នេសាទ ប្រមូល និងចាប់ដែលបានធ្វើឡើងនៅក្នុងភាគី

(ង) រ៉ែ និងសារធាតុដែលកើតមកតាមលក្ខណៈធម្មជាតិដទៃទៀតដែលមិនមានបញ្ចូលនៅក្នុងកថាខ័ណ្ឌ (ក) ដល់ (ឃ) ដែលយកចេញពីដី ទឹក សមុទ្រ ឬបាតសមុទ្រ ដែលជាសមុទ្ររបស់ភាគី

(ច) ទំនិញដែលយកចេញពីទឹក សមុទ្រ ឬបាតសមុទ្រដែលជាសមុទ្រនៅក្រៅដែនទឹករបស់ភាគី ដោយហេតុថា ភាគីនោះមានសិទ្ធិធ្វើអាជីវកម្មលើទឹកសមុទ្រ ឬបាតសមុទ្រ នៃសមុទ្រ ដោយយោងទៅតាមច្បាប់ និងទម្លាប់របស់ខ្លួន និងច្បាប់អន្តរជាតិ

**កំណត់សម្គាល់:** គ្មានអ្វីដែលនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់បណ្តាភាគីក្រោមច្បាប់អន្តរជាតិ រួមទាំងសិទ្ធិ និងកាតព្វកិច្ចនៅក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ។

(ឆ) ទំនិញពីការនេសាទសមុទ្រ និងផលិតផលពីសមុទ្រផ្សេងៗទៀត ដែលបាននេសាទដោយនាវានៃភាគីពីសមុទ្រខាងក្រៅដែនដីនៃភាគីណាមួយ

(ជ) ទំនិញដែលត្រូវបានកែច្នៃ និង / ឬផលិតនៅលើនាវារោងចក្រនៃភាគី រួមទាំងផលិតផលដែលមានចែងនៅក្នុងកថាខ័ណ្ឌ (ឆ)

(ឈ) សម្ភារៈដែលប្រមូលបាននៅក្នុងភាគី ដែលមិនអាចរក្សាបានសភាពដើម ឬស្តារឡើងវិញ ឬជួសជុលឡើងវិញ ដែលសម្ភារៈទាំងនោះ និងសំរាប់តែបោះចោល សំរាប់ប្រើដើម្បីបង្កើតឡើងវិញនូវគ្រឿងបន្លាស់ ឬវត្ថុធាតុដើម ឬសំរាប់គោលបំណងកែច្នៃឡើងវិញ

(៣) កំទេច និងកាកសំណល់ដែលបានមកពីការផលិត ឬសង្វាក់ផលិតកម្ម រួមទាំង រ៉ែ កសិកម្ម សាងសង់ ចំរាញ់ កាដុត និងប្រព្រឹត្តកម្មសំណល់ ឬពីការប្រើប្រាស់នៅក្នុងភាគី ដែលសំរាប់តែបោះចោល ឬសំរាប់ប្រើកែប្រែវត្ថុធាតុដើម ឡើងវិញ

(ដ) ទំនិញដែលយក ឬ ផលិតនៅក្នុងភាគី រួមទាំងទំនិញដែលមានចែងនៅក្នុងកថាខ័ណ្ឌ (ក) ដល់ (៣) ។

## មាត្រា ២៦
## ទំនិញមិនទទួលបានទាំងស្រុង ឬផលិតទាំងស្រុង

១- សំរាប់គោលបំណងនៃកថាខ័ណ្ឌ (ខ) នៃមាត្រា ២៤ ទំនិញដែលត្រូវចាត់ទុកថា ជាទំនិញដើមកំណើតពីភាគីមួយ ប្រសិនបើ :

(ក) ទំនិញដែលមានតម្លៃផ្សំតំបន់ (ដែលហៅកាត់ថា "RVC" ដោយគណនា តាមរូបមន្តមានចែងនៅក្នុងមាត្រា ២៧ ដែលមិនតិចជាង (៤០) ភាគរយ និងសង្វាក់ផលិតកម្មចុងក្រោយត្រូវបានអនុវត្តនៅក្នុងភាគី ឬ

(ខ) វត្ថុធាតុមិនមែនដើមកំណើតទាំងអស់ ត្រូវបានប្រើប្រាស់នៅក្នុងការផលិតទំនិញនៅក្នុងភាគី ដែលត្រូវតែឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ (ហៅកាត់ថា "CTC") ក្នុងកំរិត ៤ ខ្ទង់ ( ឱ. ការផ្លាស់ប្តូរទីតាំងលេខពន្ធគយធំ) នៃប្រព័ន្ធរួម ។

**កំណត់សម្គាល់ :** សំរាប់គោលបំណងនៃកថាខ័ណ្ឌរងនេះ "ប្រព័ន្ធរួម" គឺផ្អែកទៅលើវិធានផលិតផលដោយឡែក ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២

ភាគីនីមួយៗត្រូវអនុញ្ញាតឱ្យអ្នកនាំចេញទំនិញដើម្បីសម្រេចថាតើត្រូវប្រើកថាខ័ណ្ឌរង (ក) ឬ (ខ) នៅពេលដែលធ្វើការសម្រេចថា តើទំនិញនោះគ្រប់លក្ខណៈជាទំនិញមួយមានដើមកំណើតនៃភាគីឬទេ។

២-ថ្វីបើមានកថាខ័ណ្ឌ ១ ទំនិញមួយនៅក្រោមវិធានទំនិញដោយឡែក ត្រូវមានលក្ខណៈជាទំនិញដើមកំណើត ប្រសិនបើវាបំពេញបានតាមវិធានផលិតផលដោយឡែកដែលអាចអនុវត្តបាន ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២។ នៅពេលដែលវិធានផលិតផលដោយឡែក បានផ្តល់នូវជម្រើសមួយក្នុងចំណោមវិធាននានានៃវិធានប្រភពដើម ផ្អែកលើ RVC វិធានប្រភពដើមមួយផ្អែកលើ CTC ផលិតកម្មជាក់លាក់ ឬប្រតិបត្តិការកែច្នៃ ឬការច្របាច់បញ្ចូលគ្នាមួយ ពីវិធាន

ណាមួយនៃវិធានទាំងនេះ ភាគីនីមួយៗត្រូវអនុញ្ញាតឱ្យអ្នកនាំចេញទំនិញ សម្រេចលើការប្រើប្រាស់វិធានណាមួយនៅក្នុងការកំណត់ ថាតើ ទំនិញមួយគ្រប់លក្ខណៈជាទំនិញដើមកំណើតនៃភាគី ឬទេ ។

៣- សម្រាប់គោលបំណងនៃកថាខ័ណ្ឌរង ១ (ក) ហើយពាក់ព័ន្ធទៅនឹងវិធានផលិតផលដោយឡែក ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២ ដែលបានបញ្ជាក់នូវ RVC ជាក់លាក់មួយ វាតម្រូវថា RVC ទំនិញមួយ ត្រូវបានគណនាដោយប្រើរូបមន្តដែលមានចែងនៅក្នុងមាត្រា ២៧ គឺមិនតិចជាងភាគរយដែលបានបញ្ជាក់ដោយវិធានសំរាប់ទំនិញឡើយ ។

៤- សម្រាប់គោលបំណងនៃកថាខ័ណ្ឌរង ១ (ខ) ហើយពាក់ព័ន្ធទៅនឹងវិធានផលិតផលដោយឡែកដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២ វិធានបានតម្រូវថា វត្ថុធាតុប្រើប្រាស់តាមរយៈ CTC ឬ ផលិតកម្មជាក់លាក់ ឬប្រតិបត្តិការកែច្នៃត្រូវអនុវត្តសំរាប់តែវត្ថុធាតុមិនមែនដើមកំណើត ប៉ុណ្ណោះ ។

៥- សម្រាប់គោលបំណងនៃជំពូកនេះ ឧបសម្ព័ន្ធបី (៣) ត្រូវយកមកអនុវត្ត ។

## មាត្រា ២៧
## គណនាតម្លៃផ្ទៃតំបន់

១- សម្រាប់គោលបំណងនៃការគណនា RVC សំរាប់ទំនិញមួយ ត្រូវប្រើរូបមន្តដូចខាងក្រោម :

$$RVC = \frac{FOB - VNM}{FOB} \times 100\%$$

២- សម្រាប់គោលបំណងនៃមាត្រានេះ :

(ក) "FOB" លើកលែងតែមានចែងក្នុងកថាខ័ណ្ឌ ៣ គឺជាតម្លៃដល់នាវានៃទំនិញមួយ រួមទាំងថ្លៃដឹកជញ្ជូនពីអ្នកផលិតទៅកំពង់ផែ ឬទីកន្លែងចុងក្រោយនៃការដឹកជញ្ជូនទៅឯបរទេស

(ខ) "RVC" គឺជា RVC នៃទំនិញមួយ ប្រាប់ជាភាគរយមួយ និង

(គ) "VNM" គឺជាតម្លៃវត្ថុធាតុមិនមែនដើមកំណើត ប្រើនៅក្នុងការផលិតទំនិញមួយ

៣- FOB មានចែងនៅក្នុងកថាខ័ណ្ឌរង ២ (ក) ត្រូវតែជាតម្លៃ :

(ក) កែតម្រូវទៅលើតម្លៃដែលបានដឹងពិតប្រាកដលើកទី១ ដែលបានបង់សំរាប់ទំនិញមួយពីអ្នកទិញ រហូតដល់អ្នកផលិតទំនិញ ប្រសិនបើមានតម្លៃដល់នាវា ប៉ុន្តែ វាមិនត្រូវបានដឹង និងមិនអាចកំណត់បាន ឬ

(ខ) កំណត់ទៅតាមមាត្រា ១ ដល់ ៨ នៃកិច្ចព្រមព្រៀងស្តីពីការវាយតម្លៃពន្ធគយ ប្រសិនបើមិនមានតម្លៃដល់នាវានៃទំនិញមួយទេ

៤- សម្រាប់គោលបំណងនៃកថាខ័ណ្ឌ ១ តម្លៃនៃវត្ថុធាតុមិនមែនដើមកំណើត ដែលប្រើប្រាស់នៅក្នុងផលិតកម្មទំនិញនៅក្នុងភាគីមួយ ៖

(ក) ត្រូវកំណត់ទៅតាមកិច្ចព្រមព្រៀងអំពីការវាយតម្លៃពន្ធគយ និងត្រូវរាប់បញ្ចូលទាំងការដឹកជញ្ជូនធានារ៉ាប់រង នៅពេលខ្លះអាចគិតពីតម្លៃវេចខ្ចប់ និងរួមទាំងតម្លៃផ្សេងៗ ដែលកើតឡើងក្នុងពេលដឹកជញ្ជូនវត្ថុធាតុដើមទៅកាន់កំពង់ផែនាំចូលនៅក្នុងភាគី ដែលជាទីតាំងដែលអ្នកផលិតទំនិញស្ថិតនៅ ឬ

(ខ) ប្រសិនបើតម្លៃទាំងនោះមិនត្រូវបានដឹង និងមិនអាចកំណត់ច្បាស់លាស់បាន ត្រូវតែជាតម្លៃដែលអាចកំណត់បានបឋម ដែលបានបង់សំរាប់វត្ថុធាតុនៅក្នុងភាគី ប៉ុន្តែអាចដកចេញនូវថ្លៃទាំងអស់ ដែលកើតឡើងនៅក្នុងភាគីក្នុងការដឹកជញ្ជូនវត្ថុធាតុពីឃ្លាំងរបស់អ្នកផ្គត់ផ្គង់វត្ថុធាតុ ទៅទីតាំងអ្នកផលិត ដូចជា ថ្លៃដឹកជញ្ជូន ធានារ៉ាប់រង និងវេចខ្ចប់ ព្រមទាំងថ្លៃផ្សេងៗទៀតដែលមិនបានដឹង និងចំណាយមិនបានកំណត់ដែលកើតមានឡើងនៅក្នុងភាគី ។

៥- សម្រាប់គោលបំណងនៃកថាខ័ណ្ឌ ១ VNM នៃទំនិញមួយ មិនត្រូវបញ្ចូលនូវតម្លៃវត្ថុធាតុមិនមែនដើមកំណើតដែលប្រើសម្រាប់ផលិតកម្ម នៃវត្ថុធាតុដើមកំណើតនៃភាគី ដែលវត្ថុធាតុនោះ ត្រូវបានប្រើសំរាប់ផលិតទំនិញ ។

៦- សម្រាប់គោលបំណងនៃកថាខ័ណ្ឌរង ៣ (ខ) ឬ ៤ (ក) នៅក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីការវាយតម្លៃពន្ធគយ ដើម្បីកំណត់តម្លៃទំនិញ ឬវត្ថុធាតុមិនមែនដើមកំណើត កិច្ចព្រមព្រៀងស្តីពីការវាយតម្លៃពន្ធគយ ទោះជាមានការកែប្រែក៏ដោយ ក៏ត្រូវអនុវត្តចំពោះប្រតិបត្តិការក្នុងស្រុក ឬចំពោះករណីមួយចំនួន ដែលនៅទីកន្លែងមិនមានប្រតិបត្តិការទំនិញក្នុងស្រុក ឬវត្ថុធាតុមិនមែនដើមកំណើត ។

## មាត្រា ២៨

## អប្បបរមា

១- ទំនិញដែលមិនបំពេញទៅនឹងតម្រូវការនៃកថាខ័ណ្ឌរង ១ (ខ) នៃមាត្រា ២៦ ឬ ដែលមិនអាចអនុវត្តបាននូវវិធានប្រភពផ្អែកលើ CTC ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២ ត្រូវចាត់ទុកជាទំនិញដើមកំណើតរបស់ភាគីមួយ ប្រសិនបើ :

(ក) ក្នុងករណីដែលទំនិញទំនិញត្រូវបានចាត់ចំណាត់ថ្នាក់នៅក្នុងជំពូក ១៦ ១៩ ២០ ២២ ២៣ ២៨ ដល់ ៤៩ និង ៦៤ ដល់ ៩៧ នៃប្រព័ន្ធរួម តម្លៃសរុបនៃវត្ថុធាតុដែលមិនមែនដើមកំណើតប្រើប្រាស់ក្នុងការផលិតទំនិញ ដែលមិនបានឆ្លងកាត់នូវតម្រូវការ CTC មិនត្រូវលើស (១០) ភាគរយនៃ FOB ឡើយ

(ខ) ក្នុងករណីទំនិញជាក់លាក់មួយ ត្រូវបានចាត់ចំណាត់ថ្នាក់ក្នុងជំពូក ១៨ និង ២១ នៃប្រព័ន្ធរួម តម្លៃសរុបនៃវត្ថុធាតុមិនមែនដើមកំណើតប្រើប្រាស់នៅក្នុងការផលិតទំនិញ ដែលមិនឆ្លងតាមរយៈតម្រូវការ CTC មិនលើសពី (១០) ភាគរយ ឬ (៧) ភាគរយនៃ FOB ដូចដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២ ឬ

(គ) ក្នុងករណីទំនិញមួយត្រូវបានចំណាត់ថ្នាក់ នៅក្រោមជំពូក ៥០ ដល់ ៦៣ នៃប្រព័ន្ធរួម ទម្ងន់វត្ថុធាតុទាំងអស់ដែលមិនមែនវត្ថុធាតុដើមកំណើត ប្រើប្រាស់នៅក្នុងផលិតកម្មទំនិញដែលមិនបានឆ្លងតាមរយៈ CTC មិនត្រូវលើសដប់ (១០) ភាគរយ នៃទម្ងន់សរុបនៃទំនិញមួយ ឡើយ

ជាហេតុធ្វើឱ្យវាបំពេញបានទៅនឹងលក្ខខណ្ឌទាំងអស់ដែលមានចែងនៅក្នុងជំពូកនេះ សំរាប់គ្រប់លក្ខណៈជាទំនិញដើមកំណើត ។

**កំណត់សម្គាល់ :** សម្រាប់គោលបំណងនៃកថាខ័ណ្ឌនេះ កថាខ័ណ្ឌ ២ (ក) នៃមាត្រា ២៧ ត្រូវយកមកអនុវត្ត ។

២- តម្លៃនៃវត្ថុធាតុដែលមិនមែនដើមកំណើត ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ ទោះជាយ៉ាងណាក៏ដោយ ក៏វាត្រូវបានបញ្ចូលជាតម្លៃនៃវត្ថុធាតុមិនមែនដើមកំណើតសំរាប់វិធានប្រភពដើមផ្អែកលើ RVC ចំពោះទំនិញផងដែរ ។

### មាត្រា ២៩
### ការរួមផ្សំ

វត្ថុធាតុដើមកំណើត នៃភាគីមួយ ដែលត្រូវបានប្រើនៅក្នុងផលិតកម្មទំនិញមួយ នៅក្នុងភាគីផ្សេងមួយផ្សេងទៀត ត្រូវបានចាត់ទុកថា ជាវត្ថុធាតុដើមកំណើតនៃភាគីនោះ នៅពេលដែលការងារ ឬការកែច្នៃទំនិញត្រូវ បានដំណើរការ ។

### មាត្រា ៣០
### ប្រតិបត្តិការមិនគ្រប់លក្ខណៈ

ទំនិញមួយមិនត្រូវបានចាត់ទុកថា បានបំពេញនូវតម្រូវការ CTC ឬផលិតកម្មជាក់លាក់ ឬប្រតិបត្តិការកែច្នៃ ដោយមូលហេតុគ្រាន់តែ ៖

(ក) ប្រតិបត្តិការដើម្បីធានាដល់ការរក្សាទំនិញឱ្យនៅក្នុងលក្ខខ័ណ្ឌល្អ នៅក្នុងតំណាក់កាលដឹកជញ្ជូន និងរក្សាទុកក្នុងឃ្លាំង (ដូចជា សម្ងួត បង្កក ប្រឡាក់ប្រេ) និងប្រតិបត្តិការប្រហាក់ប្រហែល

(ខ) ការផ្លាស់ប្តូរកញ្ចប់ និងការបំបែកចេញ និងតម្លើងកញ្ចប់

(គ) វិការផ្តុំចេញ

(ឃ) ច្រកបញ្ចូលដប ដាក់ក្នុងស្រោម ដាក់ក្នុងប្រអប់ និងប្រតិបត្តិការវេចខ្ចប់ធម្មតាផ្សេងៗទៀត

(ង) ប្រមូលគ្រឿងបន្លាស់ និងគ្រឿងផ្សំផ្សេងៗ ដែលបានចំណាត់ថ្នាក់ជាទំនិញ អនុលោមទៅតាមវិធាន ២(ក) នៃវិធានទូទៅសំរាប់គោលដៅបកស្រាយនៃប្រព័ន្ធរួម

(ច) គ្រាន់តែតុបតែងលម្អជាឈុតទំនិញ ឬ

(ឆ) ការរួមផ្សំប្រតិបត្តិការ ដែលមានចែងនៅក្នុងកថាខ័ណ្ឌរង (ក) ដល់ (ច)

## មាត្រា ៣១
## ការបញ្ជូនទំនិញដោយផ្ទាល់

១- ប្រព្រឹត្តកម្មអនុគ្រោះពន្ធគយត្រូវបានផ្តល់ដល់ទំនិញដើមកំណើតដែលបានបំពេញទៅនឹងតម្រូវការនៃជំពូកនេះ ដែលទំនិញដើមកំណើតនោះ ត្រូវបានបញ្ជូនដោយផ្ទាល់ពីភាគីនាំចេញទៅឱ្យភាគីនាំចូល ។

២- ខាងក្រោមនេះត្រូវចាត់ទុកថា ជាការបញ្ជូនដោយផ្ទាល់ពីភាគីនាំចេញទៅភាគីនាំចូល :

(ក) ទំនិញដែលដឹកជញ្ជូនដោយផ្ទាល់ពីភាគីនាំចេញទៅភាគីនាំចូល ឬ

(ខ) ទំនិញដែលដឹកជញ្ជូនតាមរយៈភាគីមួយ ឬច្រើន ដែលក្រៅពីភាគីនាំចេញ និងភាគីនាំចូល ឬ តាមរយៈភាគីមិនមែនភាគី ដោយហេតុថា ទំនិញនោះមិនមានប្រតិបត្តិការដឹកជញ្ជូន ក្រៅពីដឹកឆ្លងកាត់ ឬរក្សាទុកក្នុងឃ្លាំងបណ្តោះអាសន្ន ជញ្ជូនទំនិញចេញ ដាក់ទំនិញចូល និងការប្រតិបត្តិផ្សេងៗទៀត ដើម្បីរក្សាទំនិញទុកក្នុងលក្ខខណ្ឌល្អ ។

## មាត្រា ៣២
## សម្ភារៈវេចខ្ចប់ និងកុងតឺន័រ

១- សម្ភារៈវេចខ្ចប់ និងកុងតឺណ័រសំរាប់ការដឹកជញ្ជូន និងផ្ទុកទំនិញ មិនត្រូវបានចាត់ទុកជាការកំណត់ដើមកំណើតទំនិញណាមួយឡើយ ។

២- សម្ភារៈវេចខ្ចប់ និងប្រដាប់សម្រាប់វេចខ្ចប់ទំនិញលក់រាយ នៅពេលដែលធ្វើចំណាត់ថ្នាក់ជាមួយទំនិញ មិនត្រូវចាត់ទុកជាការកំណត់ ថាតើវត្ថុធាតុដើមមិនមែនដើមកំណើតប្រើប្រាស់នៅក្នុងការផលិតទំនិញ បំពេញបាននូវវិធានប្រភពដើមទំនិញ ដោយផ្អែកទៅលើ CTC ឡើយ ។

៣- ប្រសិនបើទំនិញមួយ ត្រូវផ្អែកលើការប្រើវិធានប្រភពដើម RVC តម្លៃនៃសម្ភារៈវេចខ្ចប់ និងប្រដាប់សម្រាប់វេចខ្ចប់លក់រាយ ត្រូវបានចាត់ទុកជាវត្ថុធាតុដើមកំណើត ឬវត្ថុធាតុមិនមែនដើមកំណើត ក្នុងករណីបែបនេះ អាចត្រូវបានគណនាតាម RVC នៃទំនិញ ។

## មាត្រា ៣៣
## សម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឧបករណ៍បង្ហាញ ឬឧបករណ៍ពត៌មានផ្សេងៗ

១-ប្រសិនបើទំនិញបានផ្អែកជាចំបងលើតម្រូវការរបស់វិធាន CTC ឬ ផលិតកម្មជាក់លាក់ ឬប្រតិបត្តិការកែច្នៃប្រភពដើមនៃសម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឧបករណ៍បង្ហាញ ឬឧបករណ៍ពត៌មានផ្សេង១ ដែលមានវត្ថុមានជាមួយទំនិញ មិនត្រូវបានចាត់ទុកជាការកំណត់ថា តើទំនិញនោះគ្រប់លក្ខណៈជាទំនិញដើមកំណើតទេ ដោយហេតុថា :

(ក) សម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងសម្ភារៈបង្ហាញ ឬ ឧបករណ៍ពត៌មានផ្សេងៗ មិនត្រូវបានសរសេរចូលក្នុងវិក័យប័ត្រដោយឡែកពីទំនិញឡើយ និង

(ខ) បរិមាណ និងតម្លៃនៃសម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឧបករណ៍បង្ហាញ ឬឧបករណ៍ពត៌មានផ្សេងៗ គឺជាទំនិញត្រូវបង់ពន្ធគយ ។

២- ប្រសិនបើទំនិញអាស្រ័យលើវិធាន RVC សម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឧបករណ៍បង្ហាញ ឬ ឧបករណ៍ពត៌មានផ្សេងៗ ត្រូវរាប់បញ្ចូលជាតម្លៃវត្ថុធាតុដើមកំណើត ឬមិនមែនដើមកំណើត បើសិនជាអាចត្រូវបានគណនាប្រភពដើមទំនិញតាមវិធាន RVC ។

## មាត្រា ៣៤
## វត្ថុធាតុមិនផ្ទាល់

១- វត្ថុធាតុមិនផ្ទាល់ នឹងត្រូវបានចាត់ទុកថា ជាវត្ថុធាតុដើមកំណើត ដោយមិនគិតថាផលិតផលទាំងនោះត្រូវបានផលិតនៅទីណាឡើយ ។

២- សំរាប់គោលបំណងនៃមាត្រានេះ ពាក្យ "វត្ថុធាតុមិនផ្ទាល់" មានន័យថា ទំនិញដែលប្រើប្រាស់នៅក្នុងផលិតកម្ម ការសាកល្បង ឬការត្រួតពិនិត្យទៅលើទំនិញមួយ ប៉ុន្តែមិនបញ្ចូលរូបរាងជាមួយទំនិញ ឬទំនិញដែលប្រើក្នុងការថែទាំអាគារ ឬប្រតិបត្តិការនៃឧបករណ៍ដែលពាក់ព័ន្ធនឹងផលិតកម្ម នៃទំនិញមួយ រួមមាន :

(ក) ប្រេងឥន្ធនៈ និងថាមពល

(ខ) គ្រឿងឧបករណ៍ ពុម្ព និងចាក់ពុម្ព

(គ) គ្រឿងបន្លាស់ និងវត្ថុធាតុប្រើសម្រាប់ការថែទាំឧបករណ៍ និងអាគារ

(ឃ) ប្រេងរំអិល ខ្លាញ់ វត្ថុធាតុផ្សំ និងរាល់វត្ថុធាតុដែលប្រើប្រាស់ក្នុងផលិតកម្ម ឬប្រើក្នុងប្រតិបត្តិការឧបករណ៍ និងអាគារ

(ង) ស្រោមដៃ វ៉ែនតា ស្បែកជើង សម្លៀកបំពាក់ ឧបករណ៍សុវត្ថិភាព និងវត្ថុធាតុផ្គត់ផ្គង់ផ្សេងៗ

(ច) ឧបករណ៍ គ្រឿង និងវត្ថុធាតុផ្គត់ផ្គង់ដែលប្រើប្រាស់សម្រាប់ការសាកល្បង ឬត្រួតពិនិត្យទំនិញ

(ឆ) សារធាតុកាតាលីករ និងទឹកសំរាប់រំលាយ និង

(ជ) ទំនិញផ្សេងណាមួយដែលមិនបញ្ចូលទៅជាទំនិញ ប៉ុន្តែប្រើក្នុងការផលិតទំនិញ ដែលអាចត្រូវបានបង្ហាញយ៉ាងសមស្របជាផ្នែកមួយនៃផលិតកម្ម។

## មាត្រា ៣៥
## វត្ថុធាតុដូចគ្នា និងវត្ថុធាតុអាចផ្លាស់ប្តូរគ្នាបាន

ការកំណត់ថាតើវត្ថុធាតុនោះ ជាវត្ថុធាតុដូចគ្នា និងវត្ថុធាតុដែលអាចផ្លាស់ប្តូរគ្នាបាន គឺជាវត្ថុធាតុដើមកំណើតត្រូវធ្វើឡើងដោយការប្រើគោលការណ៍គណនេយ្យទទួលស្គាល់ទូទៅ នៃការអនុវត្តត្រួតពិនិត្យស្តុក ឬការគ្រប់គ្រងសារពើភ័ណ្ឌដែលបានអនុវត្តនៅក្នុងភាគីនាំចេញ។

## មាត្រា ៣៦
## នីតិវិធីផ្តល់វិញ្ញាបនប័ត្រប្រតិបត្តិ

នីតិវិធីផ្តល់វិញ្ញាបនប័ត្រប្រតិបត្តិដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ៤ ត្រូវអនុវត្តចំពោះនីតិវិធីស្តីពីវិញ្ញាបនប័ត្រប្រភពដើមទំនិញ និងបញ្ហាពាក់ព័ន្ធ។

## មាត្រា ៣៧

## អនុគណៈកម្មាធិការស្តីពីវិធានប្រភពដើម

១- ក្នុងគោលបំណងនៃការអនុវត្ត និងប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាព នៃជំពូកនេះ អនុគណៈកម្មាធិការស្តីពីវិធានប្រភពដើម (ដែលហៅកាត់ថា "អនុគណៈកម្មាធិការ") នឹងត្រូវបង្កើតឡើង យោងទៅតាម មាត្រា ១១ ។

២- មុខងាររបស់អនុគណៈកម្មាធិការ មាន :

(ក) ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍សមស្របនានា ទៅគណៈកម្មាធិការចម្រុះ តាមការចាំបាច់ :

(i) កាអនុវត្ត និងការប្រតិបត្តិ នៃជំពូកនេះ

(ii) ការធ្វើវិសោធនកម្មណាមួយ ចំពោះឧបសម្ព័ន្ធ ២ និង ៣ និងឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធ ៤ ដែលស្នើឡើងដោយភាគីណាមួយ និង

(iii) បទប្បញ្ញត្តិអនុវត្តន៍ យោងទៅតាមវិធាន ១១ នៃឧបសម្ព័ន្ធ ៤

(ខ) ពិចារណាលើបញ្ហាណាមួយ ពីព្រោះ បណ្តាភាគីអាចឯកភាពលើបញ្ហាដែលពាក់ព័ន្ធទៅនឹងជំពូកនេះ

(គ) រាយការណ៍អំពីសេចក្តីសម្រេចរបស់អនុគណៈកម្មាធិការ ជូនទៅគណៈកម្មាធិការចម្រុះ និង

(ឃ) បំពេញមុខងារផ្សេងៗ ដែលអាចត្រូវបានផ្តល់សិទ្ធិ ដោយគណៈកម្មាធិការចម្រុះទៅតាមមាត្រា ១១។

៣- អនុគណៈកម្មាធិការត្រូវចូលរួមដោយតំណាងពីរដ្ឋាភិបាលនៃបណ្តាភាគី និងអាចអញ្ជើញតំណាងពីអង្គភាពផ្សេងៗ ដែលមានជំនាញចាំបាច់ពាក់ព័ន្ធទៅនឹងបញ្ហាដែលត្រូវពិភាក្សា នៅពេលដែលមានការឯកភាពពីបណ្តាភាគី ។

៤- អនុគណៈកម្មាធិការត្រូវជួបទៅតាមទីកន្លែង និងពេលវេលាដែលឯកភាពដោយបណ្តាភាគី ។

## ជំពូក ៥
## វិធានការអនាម័យ និងភូតគាមអនាម័យ

### មាត្រា ៣៨
### វិសាលភាព

ជំពូកនេះត្រូវអនុវត្តចំពោះរាល់វិធានការអនាម័យ និងភូតគាមអនាម័យ (ដែលហៅថា "SPS") នៃបណ្តាភាគី ដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធ A នៃកិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យនៅក្នុងឧសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀង WTO ( ដែលហៅថា "កិច្ចព្រមព្រៀង SPS" ដែលអាចប៉ះពាល់ពាណិជ្ជកម្មដោយផ្ទាល់ និងដោយប្រយោល រវាងបណ្តាភាគី ។

### មាត្រា ៣៩
### ការអះអាងជាថ្មីពីសិទ្ធិ និងកាតព្វកិច្ច

បណ្តាភាគី អះអាងជាថ្មីពីសិទ្ធិ និងកាតព្វកិច្ចដែលពាក់ព័ន្ធទៅនឹងវិធានការ SPS នៅក្រោមកិច្ចព្រមព្រៀង SPS រវាងបណ្តាភាគីទាំងនោះ ដែលជាបណ្តាភាគី នៃកិច្ចព្រមព្រៀងខាងលើ ។

### មាត្រា ៤០
### អនុគណៈកម្មការស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ

១- សម្រាប់គោលបំណងប្រសិទ្ធិភាពនៃការអនុវត្ត និងប្រតិបត្តិការសំរាប់ជំពូកនេះ អនុគណៈកម្មការស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ (ដែលហៅក្នុងមាត្រានេះថា "អនុគណៈកម្មការ") នឹងត្រូវឡើង យោងទៅតាមមាត្រា ១១ ។

២- មុខងាររបស់អនុគណៈកម្មការមាន :

(ក) ផ្លាស់ប្តូរពត៌មានស្តីពីបញ្ហាដែលកើតមានឡើងនៅក្នុងបណ្តាភាគី និងបណ្តាភាគីមិនមែនភាគី និងផ្លាស់ប្តូរឬការបញ្ចូលនូវច្បាប់ និងស្តង់ដារដែលពាក់ព័ន្ធ SPS នៃបណ្តាភាគី ដែលអាចប៉ះពាល់ដល់ពាណិជ្ជកម្ម រវាងជប៉ុន និងភាគីដែលជាសមាជិកអាស៊ានលើសពីមួយ ដែលជាបណ្តាភាគីដោយផ្ទាល់ ឬ ប្រយោល

(ខ) សម្របសម្រួលសហប្រតិបត្តិការនៅក្នុងវិស័យវិធានការ SPS រួមមានទាំងការកសាងសមត្ថភាព ជំនួយបច្ចេកទេស និង ផ្លាស់ប្តូរអ្នកជំនាញអាស្រ័យទៅលើមូលនិធិដែលមានច្បាប់ និងបទប្បញ្ញត្តិដែលមានរបស់ភាគីនីមួយៗ

(គ) ធ្វើការពិគ្រោះយោបល់ដោយផ្អែកលើវិទ្យាសាស្ត្រដើម្បីកំណត់ និងបកស្រាយបញ្ហាជាក់លាក់ ដែលអាចកើតឡើងពីការអនុវត្តវិធានការ SPS ដែលត្រូវបានចែករំលែកដោយជប៉ុន និងជាមួយភាគីអាស៊ានលើសពីមួយ នៃបណ្តាភាគី

(ឃ) ពិនិត្យឡើងវិញនូវការអនុវត្ត និងការប្រតិបត្តិនៃជំពូកនេះ និង

(ង) រាយការណ៍ ឱ្យបានសមស្របនូវរបកគំហើញ ជូនទៅគណៈកម្មការចម្រុះ ។

៣- បណ្តាភាគីត្រូវសម្របសម្រួលរាល់ការងារជាមួយសកម្មភាពដែលត្រូវអនុវត្តជាទ្វេភាគី តំបន់ និងពហុភាគី ជាមួយនឹងគោលដៅ ដើម្បីជៀសវាងការជាន់ភារកិច្ចគ្នាដែលមិនចាំបាច់ និងធ្វើការខិតខំប្រឹងប្រែងឱ្យមានប្រសិទ្ធភាពជាអតិបរមា រវាងបណ្តាភាគីដែលពាក់ព័ន្ធ ។

៤- អនុគណៈកម្មការត្រូវជួបទៅតាមទីកន្លែង និងពេលវេលាដែលឯកភាពដោយបណ្តាភាគី ។

៥- អនុគណៈកម្មការត្រូវ :

(ក) មានតំណាងពីរដ្ឋាភិបាលពីបណ្តាភាគីដែលទទួលបន្ទុកវិធានការ SPS និង

(ខ) សហការដឹកនាំអង្គប្រជុំដោយមន្ត្រីរដ្ឋាភិបាលរបស់ជប៉ុន និងមន្ត្រីរដ្ឋាភិបាលម្នាក់របស់សមាជិកអាស៊ានដែលជាបណ្តាភាគី ។

## មាត្រា ៤១

## ចំណុចសាកសួរព័ត៌មាន

ភាគីនីមួយៗត្រូវកំណត់កន្លែងសាកសួរព័ត៌មានដើម្បីឆ្លើយតបទៅរាល់ការសាកសួរព័ត៌មានសម ស្របពីភាគីដទៃទៀតពាក់ព័ន្ធទៅនឹងវិធានការ SPS និងផ្តល់នូវព័ត៌មានសមស្របពាក់ព័ន្ធទៅនឹងការស្នើសុំ ។

## មាត្រា ៤២

## ការមិនអនុវត្តជំពូក ៩

នីតិវិធីដោះស្រាយវិវាទដែលមានចែងនៅក្នុងជំពូក ៩ មិនត្រូវអនុវត្តចំពោះជំពូកនេះទេ ។

## ជំពូក ៥

## ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា

## មាត្រា ៤៣

## គោលបំណង

គោលបំណងនៃជំពូកនេះ គឺដើម្បីជំរុញពាណិជ្ជកម្មរវាងបណ្តាភាគី ដោយ :

(ក) ធ្វើការធានាថា ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា មិនបង្កើតឱ្យមានឧបសគ្គមិនចាំបាច់ទៅលើពាណិជ្ជកម្ម

(ខ) ជំរុញឱ្យមានការយោគយល់ទៅវិញទៅមកពីស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នានៅក្នុងភាគីនីមួយៗ

(គ) ពង្រឹងការផ្លាស់ប្តូរព័ត៌មាន និងសហប្រតិបត្តិការរវាងបណ្តាភាគីនៅក្នុងការរៀបចំ អនុម័ត និងអនុវត្តស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា

(ឃ) ពង្រឹងសហប្រតិបត្តិការរវាងបណ្តាភាគី នៅក្នុងការងាររបស់ស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធទៅនឹងស្តង់ដារភាវូបនីយកម្ម និងការវាយតម្លៃភាពស្របគ្នា និង

(ង) ផ្តល់នូវក្របខ័ណ្ឌដើម្បីសម្រេចគោលដៅទាំងនេះ ។

### មាត្រា ៤៤
### វិសាលភាព

១- ជំពូកនេះត្រូវអនុវត្តចំពោះស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា ដូចដែលបានកំណត់ នៅក្នុងកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្ម នៅក្នុងឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀង WTO ( ដែលហៅកាត់ថា "កិច្ចព្រមព្រៀង TBT")

២- ជំពូកនេះមិនអនុវត្តចំពោះការទិញនូវការបញ្ជាក់នានាដែលរៀបចំដោយស្ថាប័នរដ្ឋាភិបាលនានាសំរាប់តម្រូវការផលិតកម្ម ឬការប្រើប្រាស់ នៃស្ថាប័នរដ្ឋាភិបាលនានា និងវិធានការអនាម័យ និងភូតគាមអនាម័យ ដូចមានចែងក្នុងឧបសម្ព័ន្ធ ក នៃកិច្ចព្រមព្រៀង SPS ។

៣- គ្មានអ្វីនៅក្នុងជំពូកនេះ ត្រូវដាក់កំរិតអំពីសិទ្ធិនៃភាគីមួយក្នុងការរៀបចំអនុម័ត និងអនុវត្តស្តង់ដារ និងបទប្បញ្ញត្តិបច្ចេកទេសទៅដល់កំរិតចាំបាច់ ដើម្បីបំពេញនូវគោលដៅច្បាប់ ។ នៅក្នុងចំណោមគោលដៅច្បាប់ទាំងនោះ គឺតម្រូវការសន្តិសុខជាតិ ការការពារការអនុវត្តមិនត្រឹមត្រូវ ការការពារសុខភាព ឬសុវត្ថិភាពមនុស្ស ឬជីវិត សត្វ រុក្ខជាតិ ឬសុខភាព ឬបរិស្ថាន។ អនុលោមទៅតាមនេះ ភាគីនីមួយៗ រក្សារាល់សិទ្ធិក្នុងការបកស្រាយច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិរដ្ឋបាលរបស់ខ្លួន។

### មាត្រា ៤៥
### ការអះអាងជាថ្មីពីសិទ្ធិ និងកាតព្វកិច្ច

បណ្តាភាគីបញ្ជាក់បន្ថែមពីសិទ្ធិ និងកាតព្វកិច្ចដែលពាក់ព័ន្ធទៅនឹងស្តង់ដារ បទបញ្ជាបច្ចេកទេស និងនីតិវិធីវាយតម្លៃស្របគ្នានៅក្រោមកិច្ចព្រមព្រៀង TBT រវាងបណ្តាភាគី ដែលជាភាគីទៅនៃកិច្ចព្រមព្រៀងខាងលើ។

## មាត្រា ៤៦
## សហប្រតិបត្តិការ

១- ក្នុងគោលបំណងធានាថា ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃស្របគ្នា មិនបង្កើតនូវឧបសគ្គដែលមិនចាំបាច់ដល់ពាណិជ្ជកម្មទំនិញរវាងបណ្តាភាគី បើសិនអាចធ្វើបាន បណ្តាភាគីត្រូវសហប្រតិបត្តិការលើវិស័យស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃស្របគ្នា។

២- ទម្រង់នៃកិច្ចសហប្រតិបត្តិការ ត្រូវអនុលោមទៅតាមកថាខណ្ឌ ១ អាចរួមបញ្ចូល ដូចខាងក្រោម :

(ក) ធ្វើការសិក្សារួម និងរៀបចំសិក្ខាសាលា ដើម្បីពង្រីកការយល់ដឹងទៅវិញទៅមកអំពីស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃស្របគ្នា នៅក្នុងភាគីនីមួយៗ

(ខ) ផ្លាស់ប្តូរពត៌មានស្តីពីស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃស្របគ្នា

(គ) អភិវឌ្ឍន៍ និងអនុវត្តកម្មវិធីរួមសម្រាប់កសាង និង / ឬបង្កើនសមត្ថភាពនៅក្នុងបណ្តាភាគីដើម្បីធ្វើឱ្យជឿនលឿនទៅមុខនូវសកម្មភាពដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀង TBT

(ឃ) លើកទឹកចិត្តស្ថាប័នដែលទទួលបន្ទុកស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃស្របគ្នា នៅក្នុងភាគីនីមួយៗ ក្នុងការធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីប្រយោជន៍ទៅវិញទៅមក

(ង) ធ្វើការចូលរួមវិភាគទាន បើមានលទ្ធភាព នូវរាល់សកម្មភាពដែលពាក់ព័ន្ធទៅនឹងស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃស្របគ្នា នៅក្នុងវេទិកាអន្តរជាតិ និងតំបន់ និង

(ច) ចូលរួមវិភាគការងារនៅក្នុងវិស័យស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃស្របគ្នា ដើម្បីជៀងវាងនូវឧបសគ្គមិនចាំបាច់ចំពោះពាណិជ្ជកម្មរវាងបណ្តាភាគី។

៣- ការអនុវត្តមាត្រានេះ ត្រូវតែអាស្រ័យលើមូលនិធិសមស្របជាចំបងដែលមាន ច្បាប់ និងបទប្បញ្ញត្តិដែលអាចអនុវត្តបាន នៃភាគីនីមួយៗ។

## មាត្រា ៤៧
## កន្លែងសាកសួរពត៌មាន

១- ភាគីនីមួយៗត្រូវកំណត់កន្លែងសាកសួរពតិមានដែលទទួលបន្ទុកទៅនឹងកិច្ចសហប្រតិបត្តិការអនុវត្តកិច្ចព្រមព្រៀងនេះ ។

២- ភាគីនីមួយៗត្រូវផ្តល់ទៅឱ្យបណ្តាភាគីដទៃទៀតនូវឈ្មោះកន្លែងសាកសួរពតិមានដែលបានកំណត់ និងរៀបរាប់លំអិត អំពីកន្លែងទាក់ទងនៃមន្ត្រីដែលពាក់ព័ន្ធនៅក្នុងស្ថាប័ននេះ រួមទាំងពតិមានពីទូរស័ព្ទ ទូរសារ និងអ៊ីម៉ែល និងពតិមានលំអិតផ្សេងៗ ទៀត ។

៣- ភាគីនីមួយៗត្រូវជូនពតិមានភ្លាមៗទៅបណ្តាភាគីដទៃទៀតឱ្យបានទាន់ពេលវេលានៅរាល់ការផ្លាស់ប្តូរកន្លែងសាកសួរពតិមាន ឬការកែប្រែណាមួយទៅរាល់ពតិមានដែលពាក់ព័ន្ធទៅនឹងមន្ត្រីទាំងនោះ ។

## មាត្រា ៤៨
## អនុគណៈកម្មាធិការស្តីពីស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា

១- សម្រាប់គោលបំណងប្រសិទ្ធិភាពនៃការអនុវត្ត និងប្រតិបត្តិការជំពូកនេះ អនុគណៈកម្មការស្តីពីស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃស្របគ្នា (ដែលហៅនៅក្នុងជំពូកនេះថា ("អនុគណៈកម្មការ") ត្រូវបង្កើតឡើងអនុលោមទៅតាមមាត្រា ១១ ។

២- មុខងាររបស់អនុគណៈកម្មការត្រូវ :

(ក) សម្របសម្រួលកិច្ចសហប្រតិបត្តិការ ដោយអនុលោមទៅតាមមាត្រា ៤៦

(ខ) វិភាគអំពីវិស័យអាទិភាពដែលមានការឯកភាពទៅវិញទៅមក ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ រួមទាំងការផ្តល់ការពិចារណាសមស្របទៅលើសំណើណាមួយរបស់ភាគីផងដែរ

(គ) បង្កើតកម្មវិធីការងារដោយមានការឯកភាពទៅវិញទៅមកលើវិស័យអាទិភាពនានា ដើម្បីសម្រួលដល់ការទទួលយកនូវលទ្ធផលនៃការវាយតម្លៃស្របគ្នា និងបទប្បញ្ញត្តិបច្ចេកទេស និងសមភាពនៃបទប្បញ្ញត្តិបច្ចេកទេស

(ឃ) ពិនិត្យមើលភាពជឿនលឿននៃកម្មវិធីការងារ

(ង) ពិនិត្យឡើងវិញអំពីការអនុវត្ត និងប្រតិបត្តិការ នៃជំពូកនេះ

(ច) សម្រួលដល់ការពិគ្រោះយោបល់បច្ចេកទេស

(ឆ) រាយការណ៍ នូវលទ្ធផលនៃការវិភាគ ជូនដល់គណៈកម្មការចម្រុះ និង

(ជ) បំពេញមុខងារផ្សេងៗទៀត ដែលផ្តល់ដោយគណៈកម្មការចម្រុះ ដោយអនុលោមទៅតាមមាត្រា ១១។

៣- អនុគណៈកម្មការត្រូវជួបទៅតាមទីកន្លែង និងពេលវេលាទៅតាមការឯកភាពដោយបណ្តាភាគី។

៤- បណ្តាភាគីត្រូវសម្របសម្រួលនូវរាល់សកម្មភាពដែលបង្កើតឡើងជាទ្វេភាគី តំបន់ និងពហុភាគី ជាមួយនឹងគោលដៅដើម្បីជៀសវាងនូវការធ្វើកិច្ចការជាន់គ្នាដែលមិនចាំបាច់ និងខិតខំជាអតិបរិមាសម្រាប់ប្រសិទ្ធិភាព ការងារនៃបណ្តាភាគីក្នុងកិច្ចការពាក់ព័ន្ធ។

៥- អនុគណៈកម្មការត្រូវ :

(ក) មានតំណាងពីរដ្ឋាភិបាលពីបណ្តាភាគីដែលទទួលបន្ទុក និង

(ខ) សហការដឹកនាំអង្គប្រជុំដោយមន្ត្រីរដ្ឋាភិបាលរបស់ជប៉ុន និងមន្ត្រីរដ្ឋាភិបាលម្នាក់របស់សមាជិកអាស៊ានដែលជាបណ្តាភាគី។

**មាត្រា ៥៩**

**ការមិនអនុវត្តជំពូក ៩**

នីតិវិធីដោះស្រាយវិវាទដែលមានចែងនៅក្នុងជំពូក ៩ មិនត្រូវបានអនុវត្តចំពោះជំពូកនេះឡើយ។

## ជំពូក ៦
## ពាណិជ្ជកម្មសេវាកម្ម

### មាត្រា ៥០
### ពាណិជ្ជកម្មសេវាកម្ម

១- ភាគីនីមួយៗត្រូវប្រឹងប្រែងចាត់វិធានការដោយយោងតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ ដើម្បីឆ្ពោះទៅពង្រីកវិស័យពាណិជ្ជកម្មសេវាកម្ម រវាងបណ្តាភាគីឱ្យស៊ីសង្វាក់ទៅនឹង GATS ។

២- បណ្តាភាគី ដោយមានការចូលរួមពីបណ្តាសមាជិកអាស៊ាន និងជប៉ុន បន្តពិគ្រោះយោបល់ និងចរចារាល់បទប្បញ្ញត្តិសំរាប់ពាណិជ្ជកម្មសេវាកម្ម ក្នុងគំនិតរិះរកនូវវិធានដើម្បីឈានទៅធ្វើសេរីភាវូបនីយកម្ម និងជំរុញវិស័យពាណិជ្ជកម្មសេវាកម្មរវាងបណ្តាសមាជិកអាស៊ាន និងជប៉ុន និងដើម្បីពង្រីកសហប្រតិបត្តិការក្នុងការលើកកំពស់ប្រសិទ្ធិភាព និងភាពប្រកួតប្រជែងផ្នែកសេវាកម្ម និងការផ្គត់ផ្គង់សេវា របស់បណ្តាសមាជិកអាស៊ាន និងជប៉ុន។ ដើម្បីគោលបំណងនេះ អនុគណៈកម្មការស្តីពីពាណិជ្ជកម្មសេវាកម្ម ត្រូវចូលរួមដោយតំណាងពីរដ្ឋាភិបាលនៃសមាជិកអាស៊ានទាំងអស់ និងជប៉ុន និងត្រូវបង្កើតឡើងទៅតាមមាត្រា ១១ រយៈពេល ១ ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ដោយអនុលោមទៅតាមកថាខណ្ឌ ១ នៃមាត្រា ៧៩ ។

៣- លទ្ធផលនៃការចរចា ដែលមានចែងនៅក្នុងកថាខណ្ឌ ២ ប្រសិនបើមាន ត្រូវបញ្ចូលទៅក្នុងជំពូកនេះ ដោយអនុលោម ទៅតាមមាត្រា ៧៧ ។

## ជំពូក ៧
## ការវិនិយោគ

### មាត្រា ៥១
### ការវិនិយោគ

១- ភាគីនីមួយៗ ដោយយោងតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរបស់ខ្លួន ត្រូវខិតខំបង្កើត និងរក្សានូវលក្ខខ័ណ្ឌល្អប្រសើ និងតម្លាភាព នៅក្នុងបណ្តាភាគី សំរាប់ការវិនិយោគរបស់អ្នកវិនិយោគ ពីបណ្តាភាគីផ្សេងៗទៀត ។

២- បណ្តាភាគី ដោយមានការចូលរួមពីបណ្តាសមាជិកអាស៊ាន និងជប៉ុន ត្រូវបន្តពិភាក្សា និងចរចារាល់បទប្បញ្ញត្តិសំរាប់ការវិនិយោគ ក្នុងបំណងលើកកំពស់ប្រសិទ្ធិភាព និងភាពប្រកួតប្រជែងផ្នែកបរិស្ថានវិនិយោគ របស់បណ្តាសមាជិកអាស៊ាន និងជប៉ុន តាមរយៈការធ្វើសេរីភាវូបនីកម្មបណ្តើរៗ ការជំរុញ ការសម្រួល និងការពារវិនិយោគ។ ដើម្បីគោលបំណងនេះ អនុគណៈកម្មការស្តីពីវិនិយោគ ដែលនឹងត្រូវចូលរួមពីតំណាងរបស់រដ្ឋាភិបាលនៃសមាជិកអាស៊ានទាំងអស់ និងជប៉ុន អនុលោមតាមមាត្រា ១១ នឹងត្រូវបង្កើតឡើង ក្នុងរយៈពេល ១ ឆ្នាំ ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ដោយអនុលោមទៅតាម កថាខណ្ឌ ១ នៃមាត្រា ៧៩។

៣- លទ្ធផលនៃការចរចា ដែលចែងនៅក្នុងកថាខណ្ឌ ២ ប្រសិនបើមាន ត្រូវបញ្ចូលទៅក្នុងជំពូកនេះ ដោយអនុលោមទៅតាមមាត្រា ៧៧។

## ជំពូក ៨
## សហប្រតិបត្តិការសេដ្ឋកិច្ច

### មាត្រា ៥២
### គោលការណ៍មូលដ្ឋាន

១-បណ្តាភាគី ដោយផ្អែកទៅលើធនធានដែលមាន និងគោរពទៅតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុកនានារបស់ខ្លួន ត្រូវជំរុញកិច្ចសហប្រតិបត្តិការនៅក្រោមកិច្ចព្រមព្រៀងនេះ ដើម្បីផលប្រយោជន៍ទៅវិញទៅមក នៅក្នុងការធ្វើសេរីភាវូបនីយកម្ម និងសម្រួលពាណិជ្ជកម្ម និងការវិនិយោគរវាងបណ្តាភាគី និងដើម្បីបង្កើននូវសុខមាលភាពរបស់ប្រជាជននៃបណ្តាភាគី ដោយយកចិត្តទុកដាក់ទៅលើកម្រិតផ្សេងគ្នានៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរវាងបណ្តារដ្ឋជាសមាជិកអាស៊ាន។

២- បណ្តាភាគីត្រូវជំរុញការអភិវឌ្ឍន៍ តំបន់ និងអនុតំបន់ តាមរយៈកិច្ចសហប្រតិបត្តិការសកម្មភាពសេដ្ឋកិច្ច រួមទាំងការសាងសមត្ថភាព ជំនួយបច្ចេកទេស និងសហប្រតិបត្តិការ និងសកម្មភាពផ្សេងៗស្រដៀងគ្នានេះ ដែលមានការព្រមព្រៀងទៅវិញទៅមករវាងបណ្តាភាគី។

## មាត្រា ៥៣

## វិស័យសហប្រតិបត្តិការសេដ្ឋកិច្ច

បណ្តាភាគីដោយផ្អែកទៅលើផលប្រយោជន៍ទៅវិញទៅមក ត្រូវរិះរក និងធ្វើសកម្មភាពសហប្រតិ បត្តិការសេដ្ឋកិច្ចនៅក្នុងវិស័យ ដូចខាងក្រោម ៖

(ក) នីតិវិធីពាក់ព័ន្ធពាណិជ្ជកម្ម

(ខ) បរិស្ថានធុរៈកិច្ច

(គ) កម្មសិទ្ធិបញ្ញា

(ឃ) ថាមពល

(ង) ពត៌មាន និងបច្ចេកវិទ្យាគមនាគមន៍

(ច) អភិវឌ្ឍន៍ធនធានមនុស្ស

(ឆ) សហគ្រាសធុនតូច និងមធ្យម

(ជ) ទេសចរណ៍ និងបដិសណ្ឋារកិច្ច

(ឈ) ដឹកជញ្ជូន និងឡូជីស្ទិច

(ញ) កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

(ដ) បរិស្ថាន

(ឋ) គោលនយោបាយប្រកួតប្រជែង និង

(ឌ) វិស័យផ្សេងៗទៀត ដែលអាចមានការព្រមព្រៀងទៅវិញទៅមក រវាងបណ្តាភាគី

## មាត្រា ៥៤

## អនុគណៈកម្មាធិការស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច

១-សម្រាប់គោលបំណងនៃការអនុវត្ត និងប្រតិបត្តិការជំពូកនេះ ប្រកបដោយប្រសិទ្ធិភាព អនុគណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ច (ដែលហៅក្នុងមាត្រានេះថា "អនុគណៈកម្មការ") ស្របតាមមាត្រា ១១ នឹងត្រូវបង្កើតឡើងចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ដោយអនុលោមទៅតាមកថាខណ្ឌ ១ នៃមាត្រា ៧៩។

២- មុខងាររបស់អនុគណៈកម្មការនេះ ត្រូវ :

(ក) កែប្រែ និងរៀបចំកម្មវិធីការងារពាក់ព័ន្ធជាក់លាក់ រៀបចំវិស័យ និងបង្កើតវិស័យនៃសហប្រតិបត្តិការសេដ្ឋកិច្ចនីមួយៗ។

(ខ) ផ្តល់អនុសាសន៍លើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដែលមានស្រាប់ និងកម្មវិធីកិច្ចសហប្រតិបត្តិការថ្មីនៅក្រោមជំពូកនេះ ទៅតាមវិស័យអាទិភាព នៃបណ្តាភាគី

(គ) ពិនិត្យឡើងវិញ និងតាមដានការអនុវត្ត និងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ និងការអនុវត្តនិងការបំពេញទៅតាមគោលការណ៍ជាមូលដ្ឋានរបស់ជំពូកនេះ និង

(ឃ) រាយការណ៍ការរកឃើញ និងលទ្ធផលនៃការពិភាក្សា ជូនទៅគណៈកម្មការចម្រុះ។

៣- អនុគណៈកម្មការត្រូវ :

(ក) ចូលរួមដោយតំណាងពីរដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ានទាំងអស់ និងជប៉ុន និង

(ខ) ធ្វើជាសហប្រធានដោយមន្ត្រីមួយរូបរបស់រដ្ឋាភិបាលនៃរដ្ឋជាសមាជិកអាស៊ានណាមួយ និងមន្ត្រីមួយរូបពីរដ្ឋាភិបាលជប៉ុន។

## មាត្រា ៥៥

## កម្មវិធីការងារសំរាប់សហប្រតិបត្តិការសេដ្ឋកិច្ច

១- រាល់កម្មវិធីការងារដែលរៀបចំឡើងទៅតាមវិស័យ និងបង្កើតឡើងនូវសកម្មភាពសហប្រតិបត្តិការតាម វិស័យនីមួយៗ ត្រូវមានចែងនៅក្នុងឧបសម្ព័ន្ធ ៥។

២- រាល់ការកែប្រែកម្មវិធីការងារដែលមានស្រាប់ ឬការបង្កើតនូវកម្មវិធីការងារថ្មីផ្សេងៗទៀត ត្រូវតែធ្វើឡើងស្របតាមកថាខណ្ឌ ២ នៃមាត្រា៥៤ និងតាមរយៈការធ្វើវិសោធនកម្មឧបសម្ព័ន្ធ ៥ ដោយអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រា ៧៧ ។

## មាត្រា ៥៦

## ធនធានសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច

ដោយយកចិត្តទុកដាក់ទៅលើកម្រិតផ្សេងគ្នានៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសមត្ថភាពរវាងបណ្តាភាគី បណ្តាធនធានសំរាប់សហប្រតិបត្តិការសេដ្ឋកិច្ចនៅក្រោមជំពូកនេះ ត្រូវអាចត្រូវបានផ្តល់ជូន តាមការព្រមព្រៀងទៅវិញទៅមកដោយបណ្តាភាគី ។

## មាត្រា ៥៧

## ការអនុវត្តសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច

១- សកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ចត្រូវចូលរួមយ៉ាងតិច សមាជិកអាស៊ាន (០២) និងជប៉ុន។

២- ក្រៅពីថាខណ្ឌ ១ កម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចអាចចូលរួមដោយសមាជិកអាស៊ាន (០១) និងជប៉ុន ផងដែរ ឱ្យតែកម្មវិធីទាំងនោះ មានលក្ខណៈជាតំបន់ និងផ្តល់ផលប្រយោជន៍ដល់បណ្តាប្រទេសសមាជិកអាស៊ានដទៃទៀត ។ កម្មវិធីទាំងនោះមានគោលបំណងកាត់បន្ថយគំលាតអភិវឌ្ឍន៍សេដ្ឋកិច្ចរវាងរដ្ឋជាសមាជិកអាស៊ាន ឬដើម្បីបង្កើននូវសុខមាលភាព ដល់ប្រជាជននៃបណ្តារដ្ឋសមាជិកអាស៊ាន ឈានបង្កើនសមាហរណកម្មអាស៊ាន ថែមទៀត ។

៣- បណ្តាភាគីត្រូវអនុវត្តសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច ទៅតាមពេលវេលាដែលបានព្រមព្រៀងទៅវិញទៅមក ។

## មាត្រា ៥៨

## ការមិនអនុវត្តជំពូក ៩

នីតិវិធីដោះស្រាយវិវាទដែលមានចែងនៅក្នុងជំពូក ៩ មិនត្រូវបានអនុវត្តសំរាប់ជំពូកនេះឡើយ ។

## ជំពូក ៩
## ការដោះស្រាយវិវាទ

### មាត្រា ៥៩
### និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យ :

(ក) "ភាគីប្តឹងតវ៉ា" មានន័យថា ភាគីណាមួយ ឬបណ្តាភាគីដែលស្នើសុំធ្វើការពិគ្រោះយោបល់ នៅក្រោមកថាខ័ណ្ឌ ១ នៃមាត្រា ៦២

(ខ) "ភាគីនៃវិវាទ" មានន័យថា ភាគីណាមួយដែលជាភាគីប្តឹងតវ៉ា ឬភាគីត្រូវបានប្តឹងតវ៉ា

(គ) "ភាគីត្រូវបានប្តឹងតវ៉ា" មានន័យថា ភាគីណាមួយ ឬបណ្តាភាគីដែលស្នើសុំឱ្យមានការពិគ្រោះយោបល់ដែលធ្វើឡើងក្រោមកថាខ័ណ្ឌ១ នៃមាត្រា ៦២ និង

(ឃ) "ភាគីទីបី" មានន័យថា ភាគីក្រៅពីបណ្តាភាគីនៃវិវាទដែលបានជូនពត៌មានពីចំណាប់អារម្មណ៍ជាលាយល័ក្ខអក្សរ អនុលោមទៅតាមមាត្រា ៦៦ ។

### មាត្រា ៦០
### វិសាលភាពនៃការអនុវត្ត

១- លើកលែងតែមានចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ ជំពូកនេះត្រូវអនុវត្តដោយគោរពទៅតាមការដោះស្រាយរាល់វិវាទរវាងបណ្តាភាគីដែលពាក់ព័ន្ធទៅនឹងការបកស្រាយ ឬអនុវត្តកិច្ចព្រមព្រៀងនេះ ។

២- ជំពូកនេះអាចអនុវត្តបានចំពោះវិធានការដែលប៉ះពាល់ដល់ការប្រតិបត្តិ នៃកិច្ចព្រមព្រៀងនេះ ដែលធ្វើឡើងដោយបណ្តារដ្ឋាភិបាល ឬអាជ្ញាធរ ថ្នាក់តំបន់ ឬមូលដ្ឋាន នៃភាគី ។ នៅពេលដែលវេទិកាមជ្ឈត្តការសម្រេចថា បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះមិនទាន់បានគោរពទៅតាមមាត្រា ៦៧ ភាគីទទួលខុសត្រូវ ត្រូវមានវិធានការសមស្របដែលមានដើម្បីធានាដល់ការប្រតិបត្តិនេះ ។ កថាខ័ណ្ឌ ៣ និង ៤ នៃមាត្រា ៧១ ត្រូវអនុវត្តនៅក្នុងករណីដែលភាគីនោះ មិនទាន់មានលទ្ធភាពដើម្បីធានាដល់ការប្រតិបត្តិនោះ ។

៣- គ្មានអ្វីនៅក្នុងជំពូកនេះ ត្រូវបុរេនិច្ឆ័យសិទ្ធិណាមួយនៃបណ្តាភាគី ដើម្បីឱ្យមានឧបាស្រ័យទៅរកនីតិវិធីដោះស្រាយវិវាទ ដែលមាននៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ដែលភាគីទាំងអស់នៃវិវាទ ជាបណ្តាភាគី ។

៤- ថ្វីបើមានកថាខណ្ឌ ៣ នៅពេលចាប់ផ្តើមបណ្តឹងដោះស្រាយវិវាទក្រោមជំពូកនេះ ឬក្រោមកិច្ច ព្រមព្រៀងអន្តរជាតិដទៃទៀត ដែលបណ្តាភាគីនៃវិវាទជាបណ្តាភាគី យោងទៅតាមវិវាទជាក់ស្តែង វេទិកាមួយដែលបានជ្រើសរើសដោយភាគីប្តឹងតវ៉ា ត្រូវបានប្រើប្រាស់ដើម្បីបដិសេធនៃវេទិកាណាមួយផ្សេងទៀតសំរាប់វិវាទជាក់ស្តែងនោះ ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានេះមិនត្រូវអនុវត្ត ប្រសិនបើមានការដាច់ចេញ និងប្លែកពីគ្នា នៃសិទ្ធិ និងកាតព្វកិច្ចនានា នៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិ ។

៥- សម្រាប់គោលបំណងនៃកថាខ័ណ្ឌ ៣ និង ៤ ភាគីប្តឹងតវ៉ាត្រូវបានចាត់ទុកថា បានជ្រើសរើសវេទិកាមួយ ហើយនៅពេលដែលភាគីនោះបានសំណូមពរឱ្យបង្កើត ឬបញ្ជូនវិវាទទៅឱ្យវេទិកាមជ្ឈត្តការ ឬទៅឱ្យក្រុមដោះស្រាយវិវាទ អនុលោម ទៅតាមជំពូកនេះ ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត ដែលបណ្តាភាគីនៃវិវាទជាបណ្តាភាគី ។

## មាត្រា ៦១
## កន្លែងទំនាក់ទំនង

១- សម្រាប់គោលបំណងនៃជំពូកនេះ ភាគីមួយអាចកំណត់កន្លែងទំនាក់ទំនងមួយ ដែលទទួលខុសត្រូវលើបញ្ហាទាំងអស់ដែលពាក់ព័ន្ធទៅនឹងជំពូកនេះ ។ ការដាក់ជូននូវសំណើ សេចក្តីជូនដំណឹងណាមួយ ឬឯកសារផ្សេងទៀត ក្រោមជំពូកនេះ ទៅឱ្យកន្លែងទំនាក់ទំនង ដូច្នេះ អ្នកដែលទទួលខុសត្រូវកិច្ចការនេះ ត្រូវទទួលទំនាក់ទំនងជាមួយភាគីនោះ ។

២-នៅពេលដែលភាគីមួយមិនជ្រើសយកការកំណត់កន្លែងទំនាក់ទំនង ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១ ការដាក់ជូនសំណើ សេចក្តីជូនដំណឹងណាមួយ ឬឯកសារផ្សេងទៀត ក្រោមជំពូកនេះ ត្រូវតែធ្វើឡើងតាមកន្លែងទំនាក់ទំនងដែលភាគីបានកំណត់ ដោយអនុលោមទៅតាមមាត្រា ១២ ។

៣- ភាគីណាមួយដែលទទួលនូវសំណើ សេចក្តីជូនដំណឹង ឬឯកសារផ្សេងទៀត នៅក្រោមជំពូកនេះ ត្រូវជូនពត៌មានទៅភាគីស្នើសុំ ពីការទទួលបាននូវសំណើ ជាលាយល័ក្ខអក្សរ ។

## មាត្រា ៦២
## ការពិគ្រោះយោបល់

១- ភាគីមួយ ឬបណ្តាភាគីអាចធ្វើការស្នើជាលាយល័ក្ខអក្សរ ដើម្បីសុំការពិគ្រោះយោបល់ទៅភាគីផ្សេងទៀត ឬបណ្តាភាគី ពាក់ព័ន្ធបញ្ហាណាមួយអំពីការបកស្រាយ ឬអនុវត្តកិច្ចព្រមព្រៀងនេះ នៅពេលដែលភាគីប្តឹងតវ៉ាចាត់ទុកថា ជាផលប្រយោជន៍ដែលកើតមានឡើងក្រោមកិច្ចព្រមព្រៀងនេះ កំពុងត្រូវបានចាត់ជាមោឃៈភាព និងចុះខ្សោយ ដោយសារការខកខានមិនបានប្តឹងតវ៉ារបស់ភាគីនោះទៅនឹងកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ ឬដោយសារការអនុវត្តរបស់ភាគីប្តឹងតវ៉ាចំពោះវិធានការ ដែលខុសទៅនឹងកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រម ព្រៀងនេះ ។

២- សំណូមពរណាមួយសំរាប់ការពិគ្រោះយោបល់ នឹងត្រូវដាក់ស្នើជាលាយល័ក្ខអក្សរ ដោយបញ្ចូលនូវការចង្អុលបង្ហាញនូវវិធានការជាក់លាក់លើបញ្ហា និងធ្វើការបញ្ជាក់នូវមូលដ្ឋាននៃរឿងរ៉ាវជាក់ស្តែង និងមូលដ្ឋានច្បាប់ (រួមទាំងរាល់បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងដែលបានអះអាងថាបានបំពាន និងរាល់បទប្បញ្ញត្តិពាក់ព័ន្ធ) នៅក្នុងការប្តឹង ។ នៅក្នុងពេលនោះ ភាគីប្តឹងតវ៉ាត្រូវជូនដំណឹងទៅបណ្តាភាគីទាំងអស់ ។

៣- នៅពេលដែលបានទទួលសំណើដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ ភាគីដែលបានប្តឹងតវ៉ាត្រូវចេញលិខិតជូនដំណឹងជាបន្ទាន់អំពីការទទួលសំណើនេះ ទៅភាគីប្តឹងតវ៉ា និងបណ្តាភាគីទាំងអស់ក្នុងពេលតំណាលគ្នានោះ ។

៤- ប្រសិនបើសំណើសំរាប់ការពិគ្រោះត្រូវបានធ្វើឡើង ភាគីត្រូវបានប្តឹងតវ៉ាត្រូវឆ្លើយតបទៅនឹងសំណើក្នុងរយៈពេលដប់ (១០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសំណើ និងត្រូវចាប់ផ្តើមពិគ្រោះដោយស្មោះត្រង់ក្នុងរយៈពេលមិនលើសពីសាមសិប (៣០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទួលសំណើ ក្នុងគំនិតមួយដើម្បីឈានទៅរកដំណោះស្រាយមួយដែលពេញចិត្តទាំងសងខាង ។

៥- បណ្តាភាគីវិវាទត្រូវខិតខំដើម្បីឈានដល់ដំណោះស្រាយពេញចិត្តទៅវិញទៅមក លើបញ្ហាណាក៏ដោយ តាមរយៈការពិគ្រោះយោបល់ក្រោមមាត្រានេះ ។ ក្នុងគោលដៅនេះ បណ្តាភាគីនៃវិវាទត្រូវផ្តល់ឱ្យគ្នានូវព័តិមានគ្រប់គ្រាន់ដើម្បីបង្កលទ្ធភាពឱ្យមានការពិនិត្យពេញលេញចំពោះរឿងវិវាទនោះ ។

៦- ការពិគ្រោះចាត់ទុកថា ជាការសម្ងាត់ និងរវាងបណ្តាភាគីនៃវិវាទ និងដោយមិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយក្នុងការបណ្តឹងបន្តក្រោមជំពូកនេះ ឬដំណើការនីតិវិធីផ្សេងទៀត។ បណ្តាភាគីនៃវិវាទត្រូវជូនដំណឹងទៅបណ្តាភាគីទាំងអស់នូវលទ្ធផលនៃការពិគ្រោះយោបល់នោះ។

៧- ក្នុងករណីបន្ទាន់ រាប់បញ្ចូលទាំងករណីនៃទំនិញឆាប់ស្អុយរលួយ បណ្តាភាគីនៃវិវាទ ត្រូវតែចាប់ផ្តើមការពិគ្រោះយោបល់ ក្នុងរយៈពេលមិនឱ្យលើសពីដប់ (១០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានសំណើពីភាគី ត្រូវបានប្តឹងតវ៉ា។

៨- ក្នុងករណីបន្ទាន់ រាប់បញ្ចូលទាំងករណីនៃទំនិញឆាប់ស្អុយរលួយ បណ្តាភាគីនៃវិវាទ ត្រូវខិតខំប្រឹងប្រែងជំរុញកិច្ចពិគ្រោះយោបល់ឱ្យអស់ពីលទ្ធភាព។

## មាត្រា ៦៣
## ការសម្រុះសម្រួល ការផ្សះផ្សារ និងសន្ធានកម្ម

១- ការសម្រុះសម្រួល ការផ្សះផ្សា និងសន្ធានកម្ម គឺជានីតិវិធីដែលធ្វើឡើងដោយស្ម័គ្រចិត្ត បើបណ្តាភាគីវិវាទឯកភាពគ្នា។

២- ការសម្រុះសម្រួល ការផ្សះផ្សា និងសន្ធានកម្ម អាចស្នើដោយភាគីនៃវិវាទណាមួយនៅពេលណាមួយក៏បាន។ ពួកគេអាចចាប់ផ្តើមនៅពេលណាមួយក៏បាន ឱ្យតែមានការឯកភាពដោយបណ្តាភាគីនៃវិវាទ និងបញ្ចប់នៅពេលណាក៏បានដោយមានការស្នើដោយភាគីវិវាទណាមួយ។

៣- ប្រសិនបើភាគីនៃវិវាទឯកភាព ការសម្រុះសម្រួល ការផ្សះផ្សា និងសន្ធានកម្ម អាចបន្តទៅតាមដំណើរការនីតិវិធីដែលមានចែងនៅក្នុងជំពូកនេះ។

៤- បណ្តឹងមានការពាក់ព័ន្ធទៅនឹងការសម្រុះសម្រួល ការផ្សះផ្សា និងសន្ធានកម្ម ហើយជាពិសេស ជំហរដែលប្រកាន់យកដោយបណ្តាភាគីនៃវិវាទ នៅក្នុងអំឡុងពេលនៃបណ្តឹង ភាគីត្រូវរក្សាភាពសម្ងាត់ និងមិនមានការធ្វើបុរេនិច្ឆ័យចំពោះសិទ្ធិនៃភាគីណាមួយនៅក្នុងបណ្តឹងនៅក្រោមជំពូកនេះ ឬបណ្តឹងដទៃទៀត។

## មាត្រា ៦៤
## ការបង្កើតវេទិកាមជ្ឈត្តការ

១- ភាគីប្តឹងតវ៉ាអាចស្នើជាលាយល័ក្ខអក្សរទៅភាគីត្រូវបានប្តឹងតវ៉ា ធ្វើការបង្កើតវេទិកាមជ្ឈត្តការមួយ :

(ក) ប្រសិនបើភាគីត្រូវបានប្តឹងតវ៉ាមិនឆ្លើយតបក្នុងអំឡុងពេលដប់ (១០) ថ្ងៃ ឬ មិនបានចូលពិគ្រោះយោបល់ក្នុងអំឡុងពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសំណើពីកិច្ចពិគ្រោះយោបល់ ឬ

(ខ) ប្រសិនបើបណ្តាភាគីនៃវិវាទខកខានមិនបានដោះស្រាយវិវាទតាមរយៈការពិគ្រោះយោបល់ក្នុងអំឡុងហុកសិប (៦០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលសំណើដើម្បីពិគ្រោះ ឬ ម្ភៃ (២០) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទក្នុងករណីបន្ទាន់ រួមទាំងករណីដែលពាក់ព័ន្ធដល់ទំនិញឆាប់ស្អុយរលួយ ។

២- លិខិតថតចម្លងសំណើដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ ក៏ត្រូវបញ្ជូនទៅឱ្យបណ្តាភាគីទាំងអស់ផងដែរ ។

៣- នៅពេលមានភាគីប្តឹងតវ៉ាច្រើនជាងមួយស្នើឱ្យបង្កើតវេទិកាមជ្ឈត្តការមួយពាក់ព័ន្ធទៅនឹងបញ្ហាដូចគ្នាខាងលើ នៅពេលណាក៏ដោយឱ្យតែអាចធ្វើបាន វេទិកាមជ្ឈត្តការមួយត្រូវបានបង្កើតឡើងដោយបណ្តាភាគីនៃវិវាទ ដើម្បីពិនិត្យលើបញ្ហា ដោយយកចិត្តទុកដាក់ទៅលើសិទ្ធិនៃភាគីវិវាទនីមួយៗ ។

៤- នៅពេលដែលវេទិកាមជ្ឈត្តការតែមួយត្រូវបានបង្កើតឡើង ក្រោមកថាខ័ណ្ឌ ៣ វេទិកាមជ្ឈត្តការនោះ ត្រូវរៀបចំការពិនិត្យ និងបង្ហាញលទ្ធផលទៅដល់បណ្តាភាគីវិវាទទាំងអស់ នៅក្នុងលក្ខណៈដែលសិទ្ធិដែលបណ្តាភាគីវិវាទដែលគួរត្រូវទទួលបាននូវវេទិកាមជ្ឈត្តការដោយឡែកផ្សេងទៀត ពិនិត្យបញ្ហាដូចគ្នានេះ គឺគ្មានហេតុផលណាត្រូវបានបុរេនិច្ឆ័យឡើយ ។ ប្រសិនបើភាគីណាមួយនៃបណ្តាភាគីវិវាទធ្វើការស្នើបែបនេះ វេទិកាមជ្ឈត្តការអាចចេញនូវសេចក្តីសម្រេចដោយឡែកអំពីវិវាទពាក់ព័ន្ធ ឱ្យតែក្របខ័ណ្ឌពេលវេលាសម្រាប់ចេញសេចក្តីសម្រេចនោះផ្តល់ឱកាសឱ្យ ។ ការស្នើសុំជាលាយល័ក្ខអក្សរដោយភាគីណាមួយនៃវិវាទ ត្រូវផ្តល់ជូនដល់បណ្តាភាគីនៃវិវាទផ្សេងៗទៀត ហើយភាគីនីមួយៗ នៃវិវាទត្រូវមានសិទ្ធិចូលបង្ហាញ នៅពេលដែលភាគីណាមួយផ្សេងទៀតនៃវិវាទ ចូលបង្ហាញទស្សនៈរបស់គេនៅវេទិកាមជ្ឈត្តការ ។

៥- នៅពេលដែលមានវេទិកាមជ្ឈត្តការច្រើនជាងមួយត្រូវបានបង្កើតឡើង ដើម្បីពិនិត្យបញ្ហាដូចគ្នា ក្នុងករណីអតិបរិមាដែលអាចធ្វើទៅបាន បុគ្គលដដែលនោះ ត្រូវបានចាត់តាំងដោយបណ្តាភាគីវិវាទ ដើម្បីចូលរួមដោះស្រាយវិវាទនៅក្នុងវេទិកាមជ្ឈត្តការដោយឡែកនីមួយៗ។

៦- សំណើណាមួយដើម្បីធ្វើកាបង្កើតវេទិការមជ្ឈត្តការមួយ ត្រូវបញ្ជាក់ថាតើការពិគ្រោះយោបល់នៅក្រោមមាត្រា ៦២ ត្រូវបានធ្វើឬទេ ត្រូវចង្អុលបង្ហាញមូលដ្ឋានការពិតសំរាប់បណ្តឹង ដោយរាប់បញ្ចូលទាំងវិធានការជាក់ស្តែងនានា នៃបញ្ហា និងផ្តល់នូវមូលដ្ឋានច្បាប់នៃបណ្តឹងដោយរួមទាំងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដែលត្រូវបានអះអាងថាត្រូវបានបំពាន និងបទប្បញ្ញត្តិដែលពាក់ព័ន្ធដទៃៗទៀត ។

## មាត្រា ៦៥
## សមាសភាពវេទិកាមជ្ឈត្តការ

១- វេទិកាមជ្ឈត្តការត្រូវមានសមាជិកចំនួនបី (៣) រូប ។

២- ភាគីប្តឹងតវ៉ា និងភាគីត្រូវបានប្តឹងតវ៉ាត្រូវ ក្នុងអំឡុងរយះពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានសំណើសំរាប់ការបង្កើតវេទិកាមជ្ឈត្តការ ភាគីមួយៗត្រូវតែងតាំងមជ្ឈត្តករមួយ (១)រូប ដែលអាចជាជនជាតិរបស់ភាគីវិវាទណាមួយ និងស្នើតែងតាំងបេក្ខភាពរហូតចំនួនបី (៣) រូប ដើម្បីចូលរួមធ្វើជាមជ្ឈត្តករទីបី ជាអ្នកដែលត្រូវធ្វើជាប្រធានវេទិការមជ្ឈត្តការ ។ មជ្ឈត្តករទីបីមិនមែនជនជាតិនៃភាគីវិវាទណាមួយឡើយ ហើយក៏មិនមានទីកន្លែងស្នាក់នៅធម្មតារបស់កាត់នៅក្នុងភាគីវិវាទណាមួយឡើយ ហើយក៏មិនត្រូវបានបំរើការងារឱ្យភាគីវិវាទណាមួយដែរ ហើយក៏មិនមានទំនាក់ទំនងជាមួយជាមួយនឹងរឿងវិវាទនេះ ទោះជានៅក្នុងរូបភាពណាក៏ដោយ ។

៣- ភាគីប្តឹងតវ៉ា និងភាគីត្រូវបានប្តឹងតវ៉ា ត្រូវព្រមព្រៀងទៅលើការជ្រើសរើសមជ្ឈត្តករទីបីក្នុងកំឡុងសែសិបប្រាំ (៤៥) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសំណើសំរាប់ការបង្កើតវេទិកាមជ្ឈត្តការ ដោយយកចិត្តទុកដាក់ទៅលើបេក្ខភាពនានាដែលបានស្នើឡើងទៅតាមកថាខ័ណ្ឌ ២ ។ ប្រសិនបើភាគីប្តឹងតវ៉ា ឬភាគីត្រូវបានប្តឹងតវ៉ា មិនបានជ្រើសរើសមជ្ឈត្តករទៅតាមកថាខណ្ឌ ២ ឬប្រសិនបើបណ្តាភាគីនៃវិវាទខកខានមិនបានព្រមព្រៀងអំពីការជ្រើសរើសមជ្ឈត្តករទៅតាមកថាខ័ណ្ឌនេះទេ អគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោកត្រូវបានស្នើជ្រើសរើសជាបេក្ខភាពជាបន្ទាន់។ ក្នុងករណីដែលអគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោកជាជនជាតិនៃភាគីវិវាទណាមួយ អគ្គនាយករង

ឬមន្ត្រីជាន់ខ្ពស់មានឋានៈបន្ទាប់នោះដែលមិនមែនជាជនជាតិនៃភាគីវិវាទណាមួយ ត្រូវបានស្នើជ្រើសរើសជាបេក្ខភាព។ ការជ្រើសរើសដែលបានធ្វើតាមកថាខ័ណ្ឌនេះបាន លើកលែងតែ ភាគីប្តឹងតវ៉ា ឬភាគីត្រូវបានប្តឹងតវ៉ាខកខានមិនបានធ្វើការជ្រើសរើសមជ្ឈត្តករទីបីរបស់ពួកគេ។

៤- កាលបរិច្ឆេទនៃការបង្កើតវេទិកាមជ្ឈត្តការ ត្រូវជាកាលបរិច្ឆេទដែលមជ្ឈត្តករទីបីត្រូវបានជ្រើសរើស ដោយអនុលោម ទៅតាមកថាខ័ណ្ឌ ៣។

៥- ប្រសិនបើមជ្ឈត្តករ ដែលបានជ្រើសរើសនៅក្រោមមាត្រានេះ លាឈប់ ឬគ្មានសមត្ថភាពបំពេញមុខងារ សមាជិកស្នងត្រូវបានជ្រើសរើសតាមរបៀបដូចគ្នា ដូចបានរៀបរាប់សំរាប់ការជ្រើសរើសសមាជិកដើម ដែលសមាជិកស្នងនេះត្រូវមានអំណាច និងកាតព្វកិច្ចដូចសមាជិកដើមដែរ។ ការងាររបស់វេទិកាមជ្ឈត្តការ ត្រូវព្យួររហូតទាល់តែមានការជ្រើសរើសសមាជិកស្នង។

៦- បុគ្គលណាម្នាក់ដែលត្រូវបានជ្រើសរើសជាមជ្ឈត្តករ ត្រូវមានជំនាញ ឬបទពិសោធន៍ខាងច្បាប់ ពាណិជ្ជកម្មអន្តរជាតិ បញ្ហាផ្សេងទៀតដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀង ឬការដោះស្រាយវិវាទដែលកើតមានឡើងនៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ។ មជ្ឈត្តករត្រូវបានជ្រើសរើសយ៉ាងតឹងរឹងឈរលើមូលដ្ឋានសត្យាម័ត ភាពជឿជាក់បាន ភាពត្រឹមត្រូវ និងឯករាជ្យភាព និងប្រកាន់ឥរិយាបទនឹងនក្នុងរយៈពេលដំណាក់ការជំរះក្តី។ ប្រសិនបើភាគីវិវាទយល់ឃើញថា មជ្ឈត្តកររូបនោះ មិនបានប្រកាន់ខ្ជាប់នូវមូលដ្ឋានដែលចែងខាងលើ បណ្តាភាគនៃវិវាទត្រូវពិគ្រោះយោបល់ ហើយបើមានការឯកភាពគ្នា មជ្ឈត្តករនោះនឹងត្រូវដកចេញ ហើយមជ្ឈត្តករថ្មីមួយរូបទៀត នឹងត្រូវតែងតាំងជំនួស ស្របទៅតាមមាត្រានេះ។

## មាត្រា ៦៦
## ភាគីទី បី

១. ភាគីណាមួយដែលមានផលប្រយោជន៍ដ៏កំភួនក្នុងរឿងវិវាទមួយនៅមុនពេល វេទិកាមជ្ឈត្តការ និងបានជូនដំណឹងអំពីការចាប់អារម្មណ៍របស់ខ្លួនជាលាយលក្ខ័អក្សរទៅបណ្តាភាគីនៃវិវាទនេះ និងបណ្តាភាគីទាំងអស់ ត្រូវមានឱកាសដាក់ជូននូវការចាប់អារណ៍នោះជាលាយលក្ខ័អក្សរទៅវេទិកាមជ្ឈត្តការ។ សំណើនេះត្រូវដាក់ជូនទៅបណ្តាភាគីនៃវិវាទ និងដែលអាចឆ្លុះបញ្ចាំងទៅនឹងសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តការ។

២. បណ្តាភាគីទី ៣ ត្រូវទទួលការដាក់ឱ្យពិនិត្យពីបណ្តាភាគីនៃវិវាទនូវកិច្ចប្រជុំលើកទីមួយនៃវេទិកាមជ្ឈត្តការ ។

៣. ប្រសិនបើភាគីទី ៣ គិតថាវិធានការមួយដែលជាកម្មវត្ថុនៃរឿងក្តីរបស់វេទិកាមជ្ឈត្តការ ហើយវិធានការនោះធ្វើឱ្យមោឃៈ ឬថយចុះនូវប្រយោជន៍របស់ខ្លួនមានកាន់តែច្រើនឡើង នៅក្រោមបណ្តាកិច្ចព្រមព្រៀងនេះ ភាគីទីបីនោះ អាចងាកទៅរកនីតិវិធីដោះស្រាយវិវាទធម្មតា នៅក្រោមជំពូកនេះ ។

## មាត្រា ៦៧
## មុខងារវេទិការមជ្ឈត្តការ

១- វេទិកាមជ្ឈត្តការ ដែលបង្កើតឡើងទៅតាមមាត្រា ៦៤ :

(ក) គួរធ្វើការវាយតម្លៃលើបញ្ហាមុនវា រួមទាំង ការពិនិត្យលើអង្គហេតុរបស់សំណុំរឿងនោះ និងភាពអាចអនុវត្តបាន និងស្របគ្នាទៅនឹងកិច្ចព្រមព្រៀង

(ខ) គួរពិគ្រោះជាមួយបណ្តាភាគីនៃវិវាទឱ្យបានសមរម្យ និងផ្តល់ឱកាសគ្រប់គ្រាន់ដើម្បីបង្កើតដំណោះស្រាយពេញចិត្តទៅវិញទៅមក

(គ) ត្រូវធ្វើការសម្រេចទៅតាមកិច្ចព្រមព្រៀង និងវិធាននៃច្បាប់អន្តរជាតិដែលមាន

(ឃ) ត្រូវកំណត់ នៅក្នុងការសម្រេច ក្នុងការបង្ហាញឱ្យឃើញនូវតថភាពច្បាប់ និងអង្គហេតុ និងរួមជាមួយនឹងមូលហេតុ

(ង) អាចក្រៅពីផ្តល់នូវការបង្ហាញពីលទ្ធផល រួមទាំងសេចក្តីសម្រេច ដែលស្នើឡើងសម្រាប់ជម្រើសក្នុងការអនុវត្ត ដើម្បីឱ្យបណ្តាភាគីនៃវិវាទពិចារណា ស្របជាមួយនឹងមាត្រា ៧១

(ច) មិនអាច សម្រេច បន្ថែម ឬបន្ថយសិទ្ធិ និងកាតព្វកិច្ច នៃភាគីណាមួយដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។

២- វេទិកាមជ្ឈត្តការអាចស្វែងរកពីបណ្តាភាគី នូវពត៌មានពាក់ព័ន្ធដែលចាត់ទុកថាចាំបាច់ និងសមស្រប ។ បណ្តាភាគីត្រូវឆ្លើយតបជាបន្ទាន់ និងក្បោះក្បាយ ទៅនឹងសំណូមពររបស់វេទិការមជ្ឈត្តការចំពោះពត៌មានទាំងនោះ ។

៣- វេទិកាមជ្ឈត្តការអាចស្វែងរកពត៌មានពីប្រភពផ្សេងៗទៀត និងពិគ្រោះជាមួយអ្នកជំនាញដើម្បីប្រមូលយោបល់ពីភាពពិតនៃបញ្ហា។ ចំពោះបញ្ហាពិតពាក់ព័ន្ធទៅនឹងបញ្ហាវិទ្យាសាស្ត្រ និងបច្ចេកទេសដែលលើកឡើងដោយភាគីវិវាទណាមួយវេទិកាមជ្ឈត្តការអាចស្នើនូវរបាយការណ៍ណែនាំជាលាយល័ក្ខអក្សរពីអ្នកជំនាញ។ ដោយមានសំណើពីភាគីណាមួយនៃវិវាទ ឬគំនិតផ្ទាល់របស់ភាគីនោះ វេទិកាមជ្ឈត្តការអាចជ្រើសរើសអ្នកជំនាញខាងវិទ្យាសាស្ត្រ និងបច្ចេកទេស ដោយមានការពិគ្រោះជាមួយនឹងបណ្តាភាគីនៃវិវាទ មិនតិចជាងអ្នកជំនាញពីរ (២) នាក់ ជាអ្នកដែល ជួយវេទិកាមជ្ឈត្តការក្នុងអំឡុងពេលជំរះក្តីទាំងមូល ប៉ុន្តែជាអ្នកមិនមានសិទ្ធិបោះឆ្នោតចំពោះការសម្រេចណាមួយដែលបានធ្វើឡើងដោយវេទិកាមជ្ឈត្តការ រួមទាំងការសម្រេចចុងក្រោយរបស់វាផងដែរ ។ រាល់ពត៌មាន និងការណែនាំបច្ចេកទេសដែលទទួលបាន ត្រូវផ្តល់ជូនបណ្តាភាគីនៃវិវាទទាំងអស់។

## មាត្រា ៦៨
## ដំណាក់ការជំរះក្តីរបស់វេទិកាមជ្ឈត្តការ

១- វិធាន និងនីតិវិធីទាំងឡាយដែលមានចែងនៅក្នុងមាត្រានេះ ត្រូវអនុវត្តចំពោះដំណាក់ការជំរះក្តីវេទិកាមជ្ឈត្តការ។

២- បណ្តាភាគីនៃវិវាទ ដោយពិគ្រោះយោបល់ជាមួយវេទិកាមជ្ឈត្តការ អាចព្រមព្រៀងក្នុងការអនុម័តវិធាន និងនីតិវិធីបន្ថែម ដែលមិនស៊ីសង្វាក់ជាមួយនឹងបទប្បញ្ញត្តិនៃមាត្រានេះ។

*លក្ខខ័ណ្ឌការងារសំរាប់វេទិកាមជ្ឈត្តការ*

៣- វេទិកាមជ្ឈត្តការត្រូវមានលក្ខខ័ណ្ឌការងារដូចខាងក្រោម :

"ពិនិត្យរាល់ (បទប្បញ្ញត្តិក្នុងកិច្ចព្រមព្រៀងនេះដែលដកស្រង់ដោយបណ្តាភាគីនៃវិវាទ) បញ្ហាដែលទាក់ទងទៅនឹងសំណើបង្កើត វេទិកាមជ្ឈត្តការ អនុលោមទៅតាមមាត្រា ៦៤ និងបញ្ហាសេចក្តីសម្រេច រួមទាំងគំហើញការពិត និងការកំណត់ផ្សេងៗ និងសំណើជំរើសអនុវត្ត ប្រសិនបើមាន ដូចមានចែងនៅក្នុងមាត្រា ៦៧"

*ការដាក់ស្នើជាលាយល័ក្ខអក្សរ និងឯកសារផ្សេងៗទៀត*

៤- ភាគីនីមួយៗ នៃវិវាទ ត្រូវផ្ញើទៅឱ្យបណ្តាភាគីផ្សេងទៀតនៃវិវាទ នូវច្បាប់ចម្លងមួយច្បាប់ដាក់ជូនវេទិកាមជ្ឈត្តការ។

៥- ចំពោះសំណើ ឬការជូនដំណឹងណាមួយ ឬឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងនីតិវិធីវេទិកាមជ្ឈត្តការ ដែលមិនគ្របដណ្តប់ដោយកថាខ័ណ្ឌ ៤ ភាគីនីមួយៗនៃវិវាទ ត្រូវធ្វើច្បាប់ចម្លងទៅឱ្យបណ្តាភាគីវិវាទ តាមរយៈ ទូរសារ អ៊ីម៉ែល ឬមធ្យោបាយបញ្ជូនតាមអេឡិចត្រូនិចផ្សេងៗទៀត ។

៦- ភាគីនីមួយៗនៃវិវាទ នៅពេលណាក៏ដោយ អាចកែតម្រូវកំហុសតិចតួចនៅក្នុងសំណើ សេចក្តីជូនដំណឹង ការដាក់សំណើជាលាយលក្ខអក្សរ ឬឯកសារពាក់ព័ន្ធទៅនឹងដំណាក់ការជំរះក្តីរបស់វេទិកាមជ្ឈត្តការ ដោយបញ្ជូននូវឯកសារថ្មីច្បាស់ៗ ដោយមានបញ្ជាក់អំពីការផ្លាស់ប្តូរមួយចំនួនផងដែរ ។

*កាលវិភាគ*

៧- បន្ទាប់ពីការពិគ្រោះជាមួយបណ្តាភាគីវិវាទ វេទិកាមជ្ឈត្តការ ត្រូវអនុវត្តជាបន្ទាន់ ហើយនៅពេលណាក៏ដោយឱ្យតែអាចធ្វើទៅបាន នៅក្នុងអំឡុងពេលប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីការបង្កើតវេទិកាមជ្ឈត្តការ ត្រូវកំណត់កាលវិភាគសំរាប់ដំណើរការវេទិកាមជ្ឈត្តការ ។ កាលវិភាគដែលបានកំណត់សំរាប់វេទិការមជ្ឈត្តការ ត្រូវការបញ្ជាក់ឱ្យបានច្បាស់លាស់នូវពេលកំណត់សំរាប់ដាក់ស្នើជាលាយល័ក្ខអក្សរទៅឱ្យភាគីវិវាទ ។ ការកែប្រែកាលវិភាគនេះអាចត្រូវបានធ្វើដោយមានការព្រៀមព្រៀងពីបណ្តាភាគីវិវាទ ដោយមានការពិគ្រោះយោបល់ជាមួយនឹង វេទិកាមជ្ឈត្តការ ផ្តល់ដោយបណ្តាភាគីនៃវិវាទ។

*ប្រតិបត្តិការរបស់ វេទិកាមជ្ឈត្តការ*

៨- វេទិកាមជ្ឈត្តការ ត្រូវធ្វើការប្រជុំដោយសម្ងាត់។ បណ្តាភាគីនៃវិវាទត្រូវមានវត្តមាននៅក្នុងកិច្ចប្រជុំ នៅពេលដែលមានការអញ្ជើញឱ្យបង្ហាញខ្លួនតែប៉ុណ្ណោះនៅមុខវេទិកាមជ្ឈត្តការ ។

៩- បណ្តាភាគីទីបីទាំងអស់ ដែលបានជូនដំណឹងអំពីការចាប់អារម្មណ៍ចំពោះវិវាទ ត្រូវបានអញ្ជើញជាលាយល័ក្ខអក្សរឱ្យចូលរួមបញ្ចេញមតិរបស់ពួកគេនៅក្នុងសម័យប្រជុំលើកទីមួយ នៃដំណាក់ការជំរះក្តីរបស់វេទិកាមជ្ឈត្តការ ដែលបានលៃលកសម្រាប់គោលបំណងនេះ ។ រាល់បណ្តាភាគីទីបីទាំងនេះ អាចត្រូវបង្ហាញមុខនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ ។

១០- រាល់ការពិភាក្សារបស់វេទិកាមជ្ឈត្តការ និងឯកសារដែលបានដាក់ស្នើ ត្រូវតែរក្សាជាសម្ងាត់។

១១- ថ្វីបើកថាខ័ណ្ឌ ១០ បានអនុញ្ញាតិឱ្យភាគីណាមួយនៃវិវាទ អាចធ្វើសេចក្តីថ្លែងការជាសាធារណៈនូវគោលជំហរ និងទស្សនៈរបស់ខ្លួនដែលពាក់ព័ន្ធទៅនឹងវិវាទ ប៉ុន្តែត្រូវតែធ្វើជាសម្ងាត់នូវនៅពត៌មាន និងការដាក់ស្នើនានា ដែលធ្វើដោយភាគីវិវាទផ្សេងទៀត ដែលបណ្តាភាគីវិវាទទុកជាការសម្ងាត់។ នៅពេលដែលភាគីវិវាទមួយដាក់នូវសំណើកែថ្មីជាសម្ងាត់ នៃសំណើរបស់ខ្លួនជាលាយល័ក្ខអក្សរទៅវេទិកាមជ្ឈត្តការ តាមការស្នើសុំរបស់ភាគីផ្សេងទៀតនៃវិវាទ ភាគីនោះ ត្រូវផ្តល់ផងដែរនូវសេចក្តីសង្ខេបមិនសម្ងាត់នៃពត៌មាន ឬការដាក់ស្នើជាលាយល័ក្ខអក្សរ ដែលអាចបើកចំហជាសាធារណៈ។

១២- ទីកន្លែងសម្រាប់ដំណាក់ការរឿងក្តីរបស់ វេទិការមជ្ឈត្តការ នឹងត្រូវសម្រេចដោយមានការព្រមព្រៀងដោយភាគីប្តឹងតវ៉ា និងភាគីត្រូវបានប្តឹងតវ៉ា។ ប្រសិនបើមិនមានការព្រមព្រៀង ទីកន្លែងអាចជំនួសបាននៅក្នុងចំណោមរាជធានីនានានៃបណ្តាភាគីវិវាទដោយត្រូវបើកកិច្ចប្រជុំជំរះក្តីរបស់វេទិការមជ្ឈត្តការលើកទីមួយ នៅក្នុងរាជធានី (១) នៃបណ្តារាជធានីរបស់ភាគីត្រូវបានប្តឹងតវ៉ា។

១៣- បណ្តាភាគីនៃវិវាទត្រូវបានផ្តល់ឱកាសចូលរួមធ្វើបទឧទ្ទេសនាម ធ្វើសេចក្តីថ្លែងការ ការឆ្លើយតប ឬការជំទាស់នៅក្នុងដំណាក់ការរឿងក្តីរបស់វេទិការមជ្ឈត្តការ។ ពត៌មានណាមួយដែលបានផ្តល់ និងការដាក់ស្នើជាលាយល័ក្ខអក្សរនានាដែលបានដាក់ជូនវេទិការមជ្ឈត្តការដោយភាគីនៃវិវាទមួយ រួមទាំងយោបល់នានាស្តីពីដែលពណ៌នាភាគ នៃពង្រាងសេចក្តីសម្រេច និងឆ្លើយតបសំណួរនានាដែលបានចោទសួរដោយវេទិការមជ្ឈត្តការ ត្រូវផ្សព្វផ្សាយដល់បណ្តាភាគីនៃវិវាទផ្សេងៗទៀត។

## មាត្រា ៦៩
## ការព្រាងសេចក្តីសម្រេច និងសេចក្តីសម្រេច

១- សេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តការ នឹងត្រូវព្រាងដោយគ្មានមានវត្តមានរបស់បណ្តាភាគីនៃវិវាទ និងទៅតាមពត៌មានដែលបានផ្តល់ និងសេចក្តីថ្លែងការដែលបានធ្វើឡើងនៅក្នុងដំណាក់ការជំរះក្តី។ ជម្រើសនានាដែលបង្ហាញនៅក្នុងសេចក្តីសម្រេចរបស់វេទកាមជ្ឈត្តការ ដោយមជ្ឈករម្នាក់ៗ ត្រូវតែជាអនាមិក។

២- នៅក្នុងរយៈពេល (៩០) ថ្ងៃ បន្ទាប់ពីថ្ងៃបង្កើតមក វេទិកាមជ្ឈត្តការ ត្រូវចេញនូវពង្រាងសេចក្តីសម្រេចរបស់ខ្លួន ជូនដល់បណ្តាភាគីនៃវិវាទ រួមទាំងការពិពណ៌នា និងអង្គហេតុ និងសេចក្តីសរុបរបស់ខ្លួន ក្នុងគោលបំណងបង្កលទ្ធភាព ឱ្យបណ្តាភាគីនៃវិវាទពិនិត្យឡើងវិញនូវពង្រាងសេចក្តីសម្រេចនោះបានជាក់លាក់។

៣- ពេលដែលវេទិកាមជ្ឈត្តការពិចារណាថា ខ្លួនមិនអាចចេញពង្រាងសេចក្តីសម្រេចក្នុងអំឡុងពេលកៅសិប (៩០) ថ្ងៃ ដូចដែលមានចែងនៅក្នុងកថាខណ្ឌ ២ វេទិកាមជ្ឈត្តការ ត្រូវផ្តល់ដំណឹងទៅឱ្យបណ្តាភាគីនៃវិវាទជាលាយល័ក្ខអក្សរអំពីមូលហេតុនៃការយឺតយ៉ាវ ជាមួយនឹងការប៉ាន់ស្មានពេលវេលាដែលខ្លួននឹងចេញពង្រាងសេចក្តីសម្រេចនេះ។

៤- បណ្តាភាគីនៃវិវាទអាចផ្តល់យោបល់ជាលាយល័ក្ខអក្សរទៅវេទិកាមជ្ឈត្តការ ស្តីពីពង្រាងសេចក្តីសម្រេច ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញពង្រាងសេចក្តីការសម្រេចនេះ។

៥- នៅពេលដែលទទួលបានមតិជាលាយល័ក្ខអក្សរដោយបណ្តាភាគីនៃវិវាទ ដូចដែលមានចែងនៅក្នុងកថាខណ្ឌ ៤ វេទិកាមជ្ឈត្តការ ដោយឈរលើគំនិតខ្លួនផ្ទាល់ ឬលើសំណើរបស់ភាគីវិវាទមួយ អាចពិចារណានូវសេចក្តីសម្រេច និងធ្វើការពិនិត្យបន្ថែមទៀត ដែលខ្លួនគិតថាសមស្រប ។

៦- វេទិការមជ្ឈត្តការ ត្រូវចេញនូវសេចក្តីសម្រេចរបស់ខ្លួនទៅឱ្យបណ្តាភាគីនៃវិវាទក្នុងអំឡុងសាមសិប (៣០) ថ្ងៃ បន្ទាប់ពីការចេញពង្រាងសេចក្តីសម្រេច។

៧- វេទិកាមជ្ឈត្តការ ត្រូវធ្វើការសម្រេចចិត្តរបស់ខ្លួន រួមទាំងសេចក្តីសម្រេច ដោយមានការយល់ព្រមពីភាគីទាំងអស់ ហើយបើមានការព្រមព្រៀងគ្នាទេ វេទិកាមជ្ឈត្តការអាចធ្វើការសំរេចចិត្តរបស់ខ្លួន តាមការបោះឆ្នោតដោយសម្លេងភាគច្រើន។

៨- សេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តការ ត្រូវជាលទ្ធផលចុងក្រោយ និងត្រូវប្រតិបត្តិតាមដោយបណ្តាភាគីនៃវិវាទ។

៩- សេចក្តីសម្រេចរបស់ វេទិកាមជ្ឈត្តការត្រូវផ្សព្វផ្សាយទៅបណ្តាភាគីផ្សេងៗក្នុងរយៈពេលដប់ (១០) ថ្ងៃបន្ទាប់ពីការចេញទៅឱ្យបណ្តាភាគីនៃវិវាទ។

## មាត្រា ៧០
## ការព្យួរ និងការបញ្ចប់ដំណាក់ការជំរះក្តី

១- នៅពេលណាដែលបណ្តាភាគីនៃវិវាទឯកភាព វេទិការមជ្ឈត្តការ អាចព្យួរការងាររបស់ខ្លួននៅពេលណាក៏បាន នៅលើរយៈពេលមិនលើសពីដប់ពីរ (១២) ខែ ពីកាលបរិច្ឆេទនៃការជូនដំណឹងរួមគ្នានៃការព្រមព្រៀងនេះ ទៅប្រធានវេទិកាមជ្ឈត្តការ ដោយបណ្តាភាគីនៃវិវាទ។ នៅពេលមានសំណើពីភាគីណាមួយនៃវិវាទ ដំណាក់ការជំរះក្តីរបស់វេទិកាមជ្ឈត្តការនឹងត្រូវបន្តបន្ទាប់ពីការព្យួរនោះ។ ប្រសិនបើការងាររបស់វេទិកាមជ្ឈត្តការ ត្រូវបានព្យួរពីដប់ពីរ (១២) ខែ អំណាចរបស់វេទិកាមជ្ឈត្តការត្រូវអស់សុពលភាព លើកលែងតែ បណ្តាភាគីនៃវិវាទឯកភាព។

២- បណ្តាភាគីនៃវិវាទអាចព្រមព្រៀង ដើម្បីបញ្ចប់នូវដំណាក់ការជំរះក្តីរបស់វេទិកាមជ្ឈត្តការ នៅពេលណាមួយមុនពេលចេញសេចក្តីសម្រេច ដោយធ្វើការជូនដំណឹងរួមគ្នាទៅប្រធានវេទិកាមជ្ឈត្តការ។

៣- នៅមុនពេលវេទិកាមជ្ឈត្តការចេញពង្រាងសេចក្តីសម្រេចរបស់ខ្លួន វេទិកាមជ្ឈត្តការអាច នៅពេលណាមួយ នៅឯដំណាក់ការណាមួយនៃដំណើរការជំរះក្តី ស្នើឱ្យបណ្តាភាគីវិវាទ ដោះស្រាយឱ្យបានរួចរាល់ប្រកបដោយមេត្រីភាព។

## មាត្រា ៧១
## ការអនុវត្តសេចក្តីសម្រេច

១- ភាគីត្រូវបានប្តឹងតវ៉ាត្រូវប្រតិបត្តិជាបន្ទាន់តាមការសេម្រេចចេញដោយ វេទិកាមជ្ឈត្តការ អនុលោមទៅតាមមាត្រា ៦៩ ។

២- ភាគីត្រូវបានប្តឹងតវ៉ា ត្រូវជូនដំណឹងទៅភាគីប្តឹងតវ៉ាក្នុងអំឡុងម្ភៃ (២០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេច ស្តីពីរយៈពេលដែលត្រូវអនុវត្តសេចក្តីសម្រេច។ ប្រសិនបើភាគីប្តឹងតវ៉ាពិចារណាថា រយៈពេលដែលត្រូវបានជូនដំណឹងនោះ មិនអាចទទួលយកបាន ភាគីប្តឹងតវ៉ាអាចបញ្ជូនបញ្ហានេះទៅវេទិកាមជ្ឈត្តការ ដែលបន្ទាប់មកបានកំណត់រយៈពេលអនុវត្តសមស្របមួយ។ វេទិកាមជ្ឈត្តការ ត្រូវជូនដំណឹងទៅបណ្តាភាគីនៃវិវាទនូវការកំណត់រយៈពេលរបស់ខ្លួនក្នុងអំឡុងសាមសិប (៣០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនបញ្ហានេះដល់ខ្លួន។

៣- ប្រសិនបើភាគីត្រូវបានប្តឹងតវ៉ាពិចារណាថា ខ្លួនមិនអាចអនុវត្តបានទៅតាមសេចក្តីសម្រេចនៅក្នុងរយៈពេលអនុវត្តដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌ ២ ភាគីត្រូវបានប្តឹងតវ៉ា ដោយមិនឱ្យហួសពីរយៈពេលអនុវត្ត ត្រូវចាប់ផ្តើមធ្វើការ

ពិគ្រោះយោបល់ជាមួយភាគីប្តឹងតវ៉ា ដើម្បីបង្កើតនូវសំណងទូទាត់ដោយស្រុះស្រួលចិត្តទៅវិញទៅមក។ ប្រសិនបើគ្មានការទូទាត់សំណងដោយស្រុះស្រួលចិត្តត្រូវបានព្រមព្រៀងក្នុងកំឡុងម្ភៃ (២០) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់នៃរយៈពេលអនុវត្តនោះទេ ភាគីប្តឹងតវ៉ាអាច ស្នើទៅ វេទិការមជ្ឈត្តការ ដើម្បីកំណត់ការព្យួរយៈពេលអនុវត្តណាមួយនៅឯកំរិតសមស្រប ទៅភាគីត្រូវបានប្តឹងតវ៉ាអំពីសមប្បទាន ឬកាតព្វកិច្ចផ្សេងៗទៀតនៅក្រោមកិច្ចព្រមព្រៀងនេះ។

៤- ប្រសិនបើភាគីប្តឹងតវ៉ាយល់ឃើញថា ភាគីត្រូវបានប្តឹងតវ៉ាខកខានមិនបានអនុវត្តសេចក្តីសម្រេចនៅក្នុងរយៈពេលអនុវត្ត ដែលបានកំណត់អនុលោមទៅតាមកថាខ័ណ្ឌ ២ ភាគីប្តឹងតវ៉ាអាចបញ្ជូនបញ្ហានេះទៅវេទិកាមជ្ឈត្តការដើម្បីជូនដំណឹងពីការខកខាន និងកំណត់ការព្យួរការអនុវត្តណាមួយនៅកម្រិតសមស្របទៅភាគីត្រូវបានប្តឹងតវ៉ាអំពីសមប្បទាន និងកាតព្វកិច្ចផ្សេងៗ ទៀតនៅក្រោមកិច្ចព្រមព្រៀងនេះ។

៥- វេទិកាមជ្ឈត្តការដែលត្រូវបានបង្កើតនៅក្រោមមាត្រានេះ ពេលណាក៏ដោយឱ្យតែអាចធ្វើទៅបាន ត្រូវមានមជ្ឈត្តកររបស់ខ្លួន ដែលជាមជ្ឈត្តករមកពីវេទិកាមជ្ឈត្តការដើម។ ប្រសិនបើបញ្ហានេះមិនអាចសំរេចទៅបាន បន្ទាប់មកមជ្ឈត្តករនៃវេទិកាមជ្ឈត្តការនេះ នឹងត្រូវបានតែងតាំងឡើង អនុលោមទៅតាមកថាខ័ណ្ឌ ២ និង ៣ នៃមាត្រា ៦៥។

៦-លុះត្រាតែបណ្តាភាគីនៃវិវាទព្រមព្រៀងលើរយៈពេលផ្សេងមួយទៀត វេទិកាមជ្ឈត្តការ ដែលត្រូវបានបង្កើតក្រោមកថាខ័ណ្ឌ ៣ និង ៤ ត្រូវចេញសេចក្តីសម្រេចក្នុងអំឡុងហុកសិប (៦០) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទពីកាលបញ្ហាត្រូវបានបញ្ជូនដល់ខ្លួន។

៧- សេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តការដែលត្រូវបានបង្កើតនៅក្រោមមាត្រានេះ នឹងត្រូវអនុវត្តតាមដោយភាគីនៃវិវាទទាំងអស់។

### មាត្រា ៧២
### សំណងទូទាត់ និងការព្យួរសម្បទាន

១- ការទូទាត់សង និងការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងៗនៅក្រោមកិច្ចព្រមព្រៀងនេះ គឺជាវិធានការបណ្តោះអាសន្ននានាដែលមាន នៅពេលដែលសេចក្តីសម្រេចមិនត្រូវបានអនុវត្តក្នុងរយៈពេលសមស្របមួយ។ ទោះជាយ៉ាងណាក៏ដោយ ទាំងការទូទាត់សង និងការព្យួរ ឬកាតព្វកិច្ចផ្សេងៗទៀត នៅក្រោមកិច្ចព្រមព្រៀងនេះ គឺសំដៅឱ្យមានការ

អនុវត្តពេញលេញនៃសេចក្តីសម្រេច ដើម្បីនាំមកនូវវិធានមួយឱ្យស្របទៅនឹងកិច្ចព្រមព្រៀងនេះ។ សំណងទូទាត់ ប្រសិនបើត្រូវបានផ្តល់ គឺត្រូវធ្វើឱ្យស្របទៅនឹងកិច្ចព្រមព្រៀងនេះ។

២- ការអនុវត្តសម្បទាន ឬ កាតព្វកិច្ចផ្សេងៗទៀតនៅក្រោមកិច្ចព្រមព្រៀងនេះ នឹងមិនត្រូវបានព្យួរមុនពេលការចាប់ផ្តើម និងក្នុងអំឡុងពេលកំពុងដំណាក់ការជំរះក្តី នៅក្រោមកថាខ័ណ្ឌ ៣ និង ៤ នៃមាត្រា ៧១ ឡើយ។

៣- ការព្យួរនៃការអនុវត្តសម្បទាន និងកាតព្វកិច្ចផ្សេងៗទៀតនៅក្រោមកថាខ័ណ្ឌ ៣ និង ៤ នៃមាត្រា ៧១ អាចត្រូវបានអនុវត្តតែបន្ទាប់ពីភាគីប្តឹងតវ៉ាធ្វើការជូនដំណឹងទៅភាគីត្រូវបានប្តឹងតវ៉ា និងភាគីទាំងអស់ដែលភាគីប្តឹងតវ៉ាមានបំណងព្យួរការអនុវត្តទៅភាគីត្រូវបានប្តឹងតវ៉ាអំពីសម្បទាន និងកាតាព្វកិច្ចផ្សេងៗទៀត នៅក្រោមកិច្ចព្រមព្រៀងនេះ។ ភាគីត្រូវបានប្តឹងតវ៉ា និងភាគីទាំងអស់ នឹងត្រូវបានជូនដំណឹងអំពីការចាប់ផ្តើមនៃការព្យួរ ហើយដែលសម្បទាន ឬកាតព្វកិច្ចផ្សេងៗទៀត នៅក្រោមកិច្ចព្រមព្រៀងនោះ ត្រូវបានព្យួរ។

៤- ក្នុងការចាត់ទុកអ្វីជាសម្បទាន ឬកាតព្វកិច្ចផ្សេងៗ នៅក្រោមកិច្ចព្រមព្រៀងនេះត្រូវបានព្យួរ នៅក្រោមកថាខ័ណ្ឌ ៣ និង ៤ នៃមាត្រា ៧១ ការព្យួរនោះនឹងត្រូវ :

(ក) ជាបណ្តោះអាសន្ន និងមិនត្រូវបាន បន្តទៅទៀតពេលដែលបណ្តាភាគីនៃវិវាទឈានទៅដល់ដំណោះស្រាយដោយពេញចិត្តទៅវិញទៅមក ឬនៅពេលដែលការអនុវត្តសេចក្តីសម្រេចត្រូវបានចូលជាធរមាន

(ខ) ត្រូវបានដាក់កម្រិតដូចគ្នានឹងមោឃៈភាព ឬការធ្វើឱ្យអន់ថយដែលអាចសន្មត់បានចំពោះការខកខានមិនបានអនុវត្តសេចក្តីសម្រេច និង

(គ) ត្រូវបានដាក់កម្រិតទៅលើវិស័យដូចគ្នា ឬវិស័យផ្សេងៗ ដែលនៅក្នុងវិស័យទាំងនោះ វេទិកាមជ្ឈត្តការបានរកឃើញអំពីមោឃៈភាព និងការធ្វើឱ្យអន់ថយ លើកលែងតែ វាមិនអាចអនុវត្តបាន ឬមិនមានប្រសិទ្ធិភាព ដើម្បីព្យួរការអនុវត្តសម្បទាន និងកាតព្វកិច្ចផ្សេងៗនៃវិស័យនោះ ឬវិស័យផ្សេងៗ ដែលក្នុងករណីនេះ ភាគីប្តឹងតវ៉ាអាចព្យួរសម្បទាន ឬផលប្រយោជន៍នានា នៅក្នុងវិស័យផ្សេងៗបាន នៅក្រោមកិច្ចព្រមព្រៀងនេះ។

៥- ប្រសិនបើភាគីត្រូវបានប្តឹងតវ៉ាពិចារណាថា ការព្យួរសម្បទាន និងកាតព្វកិច្ចផ្សេងៗទៀតនៅក្រោមកិច្ចព្រមព្រៀងនេះដោយភាគីប្តឹងតវ៉ាមិនស៊ីសង្វាក់ទៅនឹងបទប្បញ្ញត្តិនៃកថាខ័ណ្ឌ ៤ បញ្ហានឹងត្រូវបញ្ជូនទៅវេទិកាមជ្ឈត្តការ។ សម្រាប់គោលបំណងនៃវេទិកាមជ្ឈត្តការដែលត្រូវបានបង្កើតក្រោមមាត្រានេះ កថាខ័ណ្ឌ ៥ នៃមាត្រា ៧១ ត្រូវអនុវត្ត-ទោះជាមានការកែប្រែក៏ដោយ ។

៦- លុះត្រាតែបណ្តាភាគីនៃវិវាទព្រមព្រៀងលើរយៈពេលវេលាផ្សេងមួយ វេទិកាមជ្ឈត្តការដែលត្រូវបានបង្កើតនៅក្រោមមាត្រានេះ ត្រូវចេញសេចក្តីសម្រេចក្នុងអំឡុងពេលហុកសិប ( ៦០) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទ ពីកាលដែលបញ្ហាត្រូវបានបញ្ជូនទៅដល់ខ្លួន ។ សេចក្តីសម្រេចត្រូវតែប្រតិបត្តិតាមដោយភាគីនៃវិវាទទាំងអស់ ។

## មាត្រា ៧៣
## សោហ៊ុយចំណាយ

១- ភាគីប្តឹងតវ៉ា និងភាគីត្រូវប្តឹងតវ៉ាតបវិញត្រូវទទួលខុសចំពោះរាល់ការចំណាយសំរាប់មជ្ឈត្តករដែលពួកគេបានតែងតាំងរៀងៗខ្លួន និងរាល់ការចំណាយសំរាប់ពួកគេផ្ទាល់ និងថ្លៃចំណាយផ្លូវច្បាប់ផ្សេងៗ ។

២-លើកលែងតែបណ្តាភាគីនៃវិវាទមានការព្រមព្រៀងផ្សេងពីនេះ ថ្លៃចំណាយសំរាប់ប្រធានវេទិកាមជ្ឈត្តការនិងរាល់ការចំណាយដែលពាក់ព័ន្ធទៅនឹងដំណើរការជំរះក្តីរបស់វេទិកាមជ្ឈត្តការ បណ្តាភាគីនៃវិវាទនឹងត្រូវចេញស្មើៗគ្នា ។

៣- វេទិកាមជ្ឈត្តការ ត្រូវរក្សាទុកនូវរបាយការណ៍ និងត្រូវសងវិញនូវគណនីចុងក្រោយនៃរាល់សោហ៊ុយចំណាយទូទៅដែលកើតឡើងពាក់ព័ន្ធទៅនឹងដំណើរការជំរះក្តី រួមទាំងការចំណាយទៅលើជំនួយការ អ្នកកត់ត្រាដែលខ្លួនបានចាត់តាំងនានា និងបុគ្គលផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងដំណើរការនេះ ។

# ជំពូក ១០
# អវសានបញ្ញត្តិ

## មាត្រា ៧៤
## មាតិកា ចំណងជើង និងចំណងជើងរង

មាតិការ ចំណងជើង និងចំណងជើងរង ត្រូវបានដាក់បញ្ចូលសំរាប់ការងាយស្រួលក្នុងការយោងតែប៉ុណ្ណោះ និងមិនត្រូវប៉ះពាល់ដល់ការបកស្រាយលើកិច្ចព្រមព្រៀងនេះទេ។

## មាត្រា ៧៥
## ការពិនិត្យឡើងវិញ

បណ្តាភាគីត្រូវធ្វើការត្រួតពិនិត្យឡើងវិញជាទូទៅមួយនូវការអនុវត្ត និងប្រតិបត្តិការ នៃកិច្ចព្រមព្រៀងនេះ នៅក្នុងឆ្នាំទី ៥ នៃប្រតិទិន បន្ទាប់ពីឆ្នាំប្រតិទិនដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រា ៧៩ និងរៀងរាល់ប្រាំ (៥) ឆ្នាំបន្ទាប់ពីនោះ លើកលែងតែមានការឯកភាពផ្សេងពីនេះ ដោយបណ្តាភាគី។

## មាត្រា ៧៦
## ឧបសម្ព័ន្ធ និងកំណត់សំគាល់

ឧបសម្ព័ន្ធ រួមទាំងឯកសារភ្ជាប់ និងកំណត់សំគាល់ ចំពោះកិច្ចព្រមព្រៀងនេះ ត្រូវបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ៧៧
## វិសោធនកម្ម

១- កិច្ចព្រមព្រៀងនេះ អាចត្រូវបានធ្វើវិសោធនកម្ម ដោមានការព្រមព្រៀងរវាងបណ្តាភាគី ។

២- រដ្ឋាភិបាលនៃភាគីនីមួយៗត្រូវជូនដំណឹងទៅរដ្ឋាភិបាលនៃបណ្តាភាគីផ្សេងៗទៀតជាលាយល័ក្ខអក្សរថា នីតិវិធីច្បាប់ចាំបាច់សំរាប់ការចូលជាធរមាននៃសោធនកម្មត្រូវបានធ្វើរួចរាល់។ វិសោធនកម្មនោះត្រូវចូលជាធរមាននៅថ្ងៃទីមួយនៃខែទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងបែបនេះត្រូវបានធ្វើដោយរដ្ឋាភិបាលជប៉ុន និងយ៉ាងហោចណាស់មានសមាជិកអាស៊ានមួយ ជាភាគីមួយ ដែលមានការពាក់ព័ន្ធជាមួយបណ្តាភាគីទាំងនោះ ដែលរដ្ឋាភិបាលពួកគេបានធ្វើការជូនដំណឹង នៅក្នុងកាលបរិច្ឆេទនោះ។

៣- នៅពេលណាដែលរដ្ឋសមាជិកអាស៊ានមួយ ដែលជាភាគីមួយ ធ្វើការជូនដំណឹង យោងទៅតាមកថាខ័ណ្ឌ ២ បន្ទាប់ពីកាលបរិច្ឆេទដែលការជូនដំណឹងត្រូវបានធ្វើដោយរដ្ឋាភិបាលជប៉ុន និងយ៉ាងតិចមានរដ្ឋសមាជិកមួយអាស៊ាន (១) ដែលជាភាគីមួយ យោងទៅតាមកថាខ័ណ្ឌ ២ ការធ្វើវិសោធនកម្មយោងទៅតាមកថាខ័ណ្ឌ ១ ត្រូវចូលជាធរមានចំពោះរដ្ឋសមាជិកអាស៊ាននោះនៅថ្ងៃទីមួយ នៃខែទីពីរ បន្ទាប់ពីកាលបរិច្ឆេទដែលភាគីនោះបានជូនដំណឹង។

៤-ថ្វីបើមានថាខ័ណ្ឌ ២ និង ៣ ចំនួននៃសមាជិកអាស៊ានចាំបាច់សំរាប់ការចូលជាធរមាននៃវិសោធនកម្មនេះ ដោយយោងទៅតាមកថាខ័ណ្ឌ ២ អាចត្រូវបង្កើនចំនួនបាន តាមការព្រមព្រៀងរវាងបណ្តាភាគី។

៥-ថ្វីបើមានកថាខ័ណ្ឌ ២ វិសោធនកម្មពាក់ព័ន្ធតែ :

(i) ឧបសម្ព័ន្ធ ១ (ដែលបានចែងថា ការធ្វើវិសោធនកម្មត្រូវធ្វើឡើងឱ្យស្របតាមវិសោធនកម្មនៃប្រព័ន្ធរួម និងរួមទាំងការមិនផ្លាស់ប្តូរអត្រាពន្ធគយដែលបាន អនុវត្តទៅលើទំនិញដើមកំណើតរបស់បណ្តាភាគីផ្សេងៗ អនុលោមទៅតាមឧបសម្ព័ន្ធ ១)

(ii) ឧបសម្ព័ន្ធ២

(iii) ការភ្ជាប់ទៅនឹងឧបសម្ព័ន្ធ ៤

(iv) ឧបសម្ព័ន្ធ ៥

## មាត្រា ៧៨
## ការតម្កល់ទុក

សំរាប់ប្រទេសសមាជិកអាស៊ាន កិច្ចព្រមព្រៀង រួមទាំងវិសោធនកម្មរបស់វា នឹងត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ជាអ្នកដែលត្រូវផ្តល់នូវច្បាប់ចម្លងមួយច្បាប់ ទៅប្រទេសសមាជិកអាស៊ាននីមួយៗ។

## មាត្រា ៧៩
## ការចូលជាធរមាន

១-រដ្ឋាភិបាលនៃរដ្ឋហត្ថលេខីនីមួយៗ ត្រូវជូនដំណឹងទៅបណ្តារដ្ឋាភិបាលនៃរដ្ឋហត្ថលេខីដទៃៗទៀតជាលាយល័ក្ខអក្សរថា នីតិវិធីច្បាប់របស់ខ្លួនដែលចាំបាច់សម្រាប់ការចូលជាធរមាននៃកិច្ចប្រមព្រៀងនេះ ត្រូវបានធ្វើរួចរាល់អស់ហើយ។ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃ ទីមួយ នៃខែទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងត្រូវបានធ្វើដោយ

រដ្ឋាភិបាលជប៉ុន និងយ៉ាងតិចមានសមាជិកអាស៊ានមួយ (១) ដែលពាក់ព័ន្ធទៅនឹងរដ្ឋហត្ថលេខីទាំងនោះធ្វើការជូនដំណឹង តាមកាលបរិច្ឆេទនោះ ។

២- ទាក់ទងទៅនឹងរដ្ឋជាសមាជិកអាស៊ានមួយ ដែលបានការធ្វើការជូនដំណឹង ស្របតាមកថាខ័ណ្ឌ ១ បន្ទាប់ពីកាលបរិច្ឆេទដែលការជូនដំណឹងទាំងនោះត្រូវបានធ្វើឡើងដោយរដ្ឋាភិបាលជប៉ុន និងយ៉ាងហោចណាស់ មានរដ្ឋសមាជិកអាស៊ានមួយ (១) យោងតាមកថាខ័ណ្ឌ ១ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃទីមួយ ខែទីពីរ បន្ទាប់ពីកាលបរិច្ឆេទដែលសមាជិកអាស៊ាននោះធ្វើការជូនដំណឹង ។ សមាជិកអាស៊ានមួយ ត្រូវបានភ្ជាប់កាតព្វកិច្ចដោយអាណត្តិ និងលក្ខខ័ណ្ឌ នៃកិច្ចព្រមព្រៀងនេះ រួមទាំងវិការធ្វើសោធនកម្មណាមួយដែលអាចចូលជាធរមាន អនុលោមទៅតាមមាត្រា៧៧ តាមពេលវេលានៃការជូនដំណឹងនោះ ។ សំរាប់គោលបំណងនៃឧបសម្ព័ន្ធ ១ ដំណាក់កាលនៃការលុបបំបាត់ និងកាត់បន្ថយពន្ធគយរបស់រដ្ឋសមាជិកអាស៊ាននោះ ត្រូវចាប់ផ្តើមផងដែរ ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ អនុលោមទៅតាមកថាខ័ណ្ឌ ១ ។

## មាត្រា ៨០
## ការដកខ្លួនចេញ និងការបញ្ចប់

១-ភាគីណាមួយអាចដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះបាន ដោយធ្វើការជូនដំណឹងជាលាយល័ក្ខអក្សរមួយ (០១) ឆ្នាំមុន ទៅបណ្តាភាគីផ្សេងៗទៀត ។

២-កិច្ចព្រមព្រៀងនេះ ត្រូវបញ្ចប់ផងដែរ នៅពេលណាដែលរដ្ឋជាសមាជិកអាស៊ានទាំងអស់ ដែលជាបណ្តាភាគីដកខ្លួន អនុលោមតាមកថាខ័ណ្ឌ ១ ឬនៅពេលដែលជប៉ុនធ្វើដូចគ្នានេះដែរ ។

**ជាសក្ខីភាព** អ្នកចុះហត្ថលេខាខាងក្រោមនេះ ដោយត្រូវបានផ្តល់សិទ្ធិពេញលេញដោយរដ្ឋាភិបាលរបស់ពួកខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

បានធ្វើពីរច្បាប់ជាភាសាអង់គ្លេស និងបានចុះហត្ថលេខា នៅឯ

| | | | | |
|---|---|---|---|---|
| បេនដាស៊ីរីបឺហ្គាវ៉ាន់ ថ្ងៃទី | ០៣ | ខែ | មេសា | ឆ្នាំ ២០០៨ |
| ភ្នំពេញថ្ងៃទី | ០៧ | ខែ | មេសា | ឆ្នាំ ២០០៨ |
| ហ្សាកាតាថ្ងៃទី | ៣១ | ខែ | មីនា | ឆ្នាំ ២០០៨ |

| | | | | | |
|---|---|---|---|---|---|
| វៀងច័ន្ទថ្ងៃទី | ០៤ | ខែ | មេសា | ឆ្នាំ ២០០៨ | |
| កូឡាឡាំពួរថ្ងៃទី | ១៤ | ខែ | មេសា | ឆ្នាំ ២០០៨ | |
| ណៃពីយីដូថ្ងៃទី | ១០ | ខែ | មេសា | ឆ្នាំ ២០០៨ | |
| ម៉ានិលថ្ងៃទី | ០២ | ខែ | មេសា | ឆ្នាំ ២០០៨ | |
| សិង្ហបុរីថ្ងៃទី | ២៦ | ខែ | មីនា | ឆ្នាំ ២០០៨ | |
| បាងកកថ្ងៃទី | ០៧ | ខែ | មេសា | ឆ្នាំ ២០០៨ | និង |
| ហាណូយថ្ងៃទី | ២៨ | ខែ | មីនា | ឆ្នាំ ២០០៨ | ។ |

តំណាងរដ្ឋាភិបាល នៃ
ប្រ៊ុយណេដារ៉ូសាឡឹម :

តំណាងរដ្ឋាភិបាលនៃ
ជប៉ុន :

តំណាងរដ្ឋាភិបាលនៃ
ព្រះរាជាណាចក្រកម្ពុជា :

តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋឥណ្ឌូណេស៊ី :

តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ :

តំណាងរដ្ឋាភិបាលនៃ

ម៉ាឡេស៊ី :

តំណាងរដ្ឋាភិបាលនៃ
សហភាពមីយ៉ាន់ម៉ា :

តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋហ្វីលីពីន :

តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋសឹង្ហបុរី :

តំណាងរដ្ឋាភិបាលនៃ
រាជាណាចក្រថៃឡង់ដ៏ :

តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋសង្គមនិយមវៀតណាម :

*(ត ទៅរាជកិច្ចលេខ ៨១)*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៥៥៩. អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **NGUYEN THANH TUNG** នាយកក្រុមហ៊ុនស្វាយរៀងហ្គាមេន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដូចជាអង្ករ ក្រណាត់ សារុង ប្រេងម៉ាស៊ូត និងថវិកា ដល់អាជ្ញាធរខេត្តស្វាយរៀង ដើម្បីជួយដល់វិស័យសង្គមកិច្ច និងឧបត្ថម្ភដល់កងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ច នៅតំបន់ប្រាសាទព្រះវិហារ ចំណាយអស់ថវិកា ចំនួន ១៨.៥០៦ ដុល្លារអាមេរិក ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:១៥៧០ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជននៅក្រៅប្រទេស ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសាលាបឋមសិក្សាជិស្សារាវង្សី កុដិ និងអណ្តូងទឹក នៅវត្តឧត្តមវង្សី ស្ថិតក្នុងឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដូចមានព្រះនាមនិងនាមខាងក្រោម :-

១-ព្រះតេជគុណ **យិន សួខ** គង់នៅវត្តពុទ្ធរង្សីប្រទេសបារាំង បច្ច័យចំនួន ១១.០៨០ ដុល្លារ
២-លោក **ម៉ក់ សុផល** សប្បុរសជនខ្មែររស់នៅប្រទេសបារាំង ថវិកាចំនួន ១១.២២០ ដុល្លារ

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ១៧ ឆ្នាំ ២០០៩
នាយករដ្ឋមន្ត្រី

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ១៥៦៦.អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **លឹម តែម៉េង** នាយករងក្រុមហ៊ុនស្វាយរៀងហ្គាមេន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដូចជាអង្ករ ក្រណាត់ សារុង ប្រេងម៉ាស៊ូត និងថវិកា ដល់អាជ្ញាធរខេត្តស្វាយរៀង ដើម្បីជួយដល់វិស័យសង្គមកិច្ច និងឧបត្ថម្ភដល់កងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតំបន់ប្រាសាទព្រះវិហារ ចំណាយអស់ថវិកា ចំនួន ៥១.១៣៤ ដុល្លារអាមេរិក ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៥៦៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយអភិវឌ្ឍន៍វិទ្យាល័យ ហ៊ុន សែន វាលរេញ ស្ថិតនៅក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចមានរាយនាមខាងក្រោម ៖

១-លោក **តែវ សេង និង ភរិយា** ថវិកាចំនួន ១២.៥០០ ដុល្លារ
២-លោក **អាណាន់ ស៊ុនយ៉ុត** ថវិកាចំនួន ១០.៥០០ ដុល្លារ

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៩ ឆ្នាំ ២០០៩
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**១៥៦៣.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០៣គ្រឿង ជូនសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា ខេត្តកំពង់ចាម ដែលមានស្នាដៃល្អឆ្នើម ក្នុងការប្រកួតប្រជែងចលនា៣ល្អ និងបំពេញកាតព្វកិច្ចជាពលរដ្ឋល្អ មិនប្រព្រឹត្តអំពើខុសឆ្គងចំពោះសង្គមជាតិ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | **ហាន ហូ** | ជនពិការ |
| ២- លោក | **ញៀម ខុន** | ជនពិការ |
| ៣-លោក | **ឆួក សារឿន** | ជនពិការ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ១០ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៦៨ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយទ្រាក់ការងារ ចំនួន ០២គ្រឿង ជូនមន្ត្រីអង្គការគ្រីសស្ពានអន្តរជាតិ ចំនួន០២រូប ដែលបានជួយដល់មណ្ឌលកុមារកំព្រាអ្នកគង្វាលល្អ និង មណ្ឌលកុមារកំព្រាខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម ៖

១-លោក រូនណាត ណារិន នាយកតំណាងអង្គការគ្រីសស្ពានអន្តរជាតិប្រចាំកម្ពុជា

២- លោក រូនណាត ណារ៉ា នាយកគ្រប់គ្រងអង្គការគ្រីសស្ពានអន្តរជាតិ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/៚

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ១០ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៧៥..អនក្រ-បក

# អនុក្រឹត្យ

# ស្តីពី

# ការដំឡើងឋានន្តរសក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | | |
| ១ | សេង ស្រេង | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| **រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** | | | | |
| ១ | ខាន់ វណ្ណា | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | | |
| ១ | វ៉ា ម៉ូរីន | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២ | យន់ ខឿន | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៣ | ចាប សុវណ្ណ | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៤ | ជួន សាមុត | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

| | | | | |
|---|---|---|---|---|
| ៥ | **យស ចំនួជារ៉ា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | | |
| ១ | **តុង ម៉ុនឡា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ២ | **លូ លីយឹម** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៣ | **ចាន់ ថុល** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៤ | **ឃុំង វណ្ណៈរតេ** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | | |
| ១ | **គីម សាន់** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ២ | **ម៉ុម ណារ៉ា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២** : ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ នៃក្របខ័ណ្ឌ**សុខាភិបាលជាន់ខ្ពស់** របស់**ក្រសួងសុខាភិបាល** ដូចមាននាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **ទី មានហេង** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ |

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រាខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ១០ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៥៦៧..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

# ស ម្រេ ច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង **អប់រំ យុវជន និងកីឡា** ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **គីម អមរា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ២ | **ជឹម រដ្ឋា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៣ | **ម៉ក់ ថាវិន** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៤ | **តូច ជឿន** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២ :** ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ នៃក្របខ័ណ្ឌ**គ្រូបង្រៀនកម្រិតឧត្តម** របស់**ក្រសួងអប់រំ យុវជន និងកីឡា** ចំនួន **៣៦** រូប ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **ស៊ើ សុជាតា** | ស | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ២ | **ឆេព សុរ៉ែន** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៥ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣ | **សុខ កុសល** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៥ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៤ | **ឃាង ចាន់ថុន** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៥ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៥ | **ផុន សេង** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៥ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៦ | **អេង គីមលី** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៧ | **យ៉ឹន សំបូរ** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៨ | **អ៊ុក ថុន** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៩ | **ស៊ិន ពុទ្ធាសារ** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ១០ | **ចាន់ សារាវី** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ១១ | **ជ័យ ទង់** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ |

| | | | ថ្នាក់លេខ ៦ | ថ្នាក់លេខ ៧ |
|---|---|---|---|---|
| ១២ | យ៉ឹម ចាន់ស្រី | ស | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ១៣ | ចាន់ រដ្ឋសុផា | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ១៤ | គុង ហានស៊ីន | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ១៥ | អ៊ុម រស្មីណារី | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ១៦ | សោ សុផាន់ | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ១៧ | ស៊ូ ផល្លា | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ១៨ | យូ បុណ្យណា | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ១៩ | ពៅ សារឿន | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ២០ | គង់ ហេង | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ២១ | ព្រហ្ម សុផាន់ណា | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ២២ | ប៊ិក ជីវី | ស | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ២៣ | ទ៊ា បូណារ៉ា | ស | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ២៤ | សុខ សុហោម៉ា | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ២៥ | ហេង ចន្ទថា | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ២៦ | នូ សេដ្ឋា | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ២៧ | សោម សារឿន | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |

| | | | | |
|---|---|---|---|---|
| ២៨ | នាយ ផាង | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ២៩ | នៅ សារ៉េត | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ៣០ | អ៊ុំ រ៉ាធី | ស | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ៣១ | គីម អឿន | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ៣២ | នៀ សុផន | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ៣៣ | លុយ ចន្ថា | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ៣៤ | ឌុំ សារាធុច | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ៣៥ | សុខ ចន្ថានី | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |
| ៣៦ | ស៊ឹម សុចិចារណ៍ | ស | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ |

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រាខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល :**</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៥៧៧. អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូននាយទាហាន ចំនួន ០៤រូប ចំណុះបញ្ជាការដ្ឋានកងទ័ពជើងគោក ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយសុវត្ថារា** ថ្នាក់ **ធីបឌិន្ទ :**

១- ឧត្តមសេនីយ៍ត្រី **អ៊ុច ណារិទ្ធ** អត្តលេខ ០០១៨៣៩ នាយរងខុទ្ទកាល័យកងទ័ពជើងគោក

២- វរសេនីយ៍ឯក **ជំ វណ្ណារិទ្ធ** អត្តលេខ ០០៨៩៤៥ នាយរងខុទ្ទកាល័យកងទ័ពជើងគោក

៣- វរសេនីយ៍ឯក **ចាន់ ឫទ្ធីឌី** អត្តលេខ ០១០២១១ នាយរងការិយាល័យទី២ កងទ័ពជើងគោក

**ខ-មេដាយសុវត្ថារា** ថ្នាក់ **សេនា :**

- វរសេនីយ៍ទោ **ស៊ុន លឹមហេង** អត្តលេខ ០៣៤២១១ នាយផ្នែកឥស្សរិយយសសរសើរ ការិយាល័យទី១ កងទ័ពជើងគោក

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៥៧៤.អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងនាយទាហាន ចំនួន ៥០រូប ចំណុះកងពលតូចថ្មើរជើងលេខ៥១ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ :**

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | **ព្រាប សារុន** | ០០៣៩៣៣ | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ៥១ |
| ២ | វរសេនីយ៍ឯក | **ប៊ូ សារ៉េត** | ០០៣៩៣៥ | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ៥១ |
| ៣ | វរសេនីយ៍ឯក | **ឡោ ចណ្ណមគ្រ** | ០០០៥៦១ | នាយការិ.ផែនការ នាយកដ្ឋានប្រេង ក្រសួងការពារជាតិ |
| ៤ | វរសេនីយ៍ឯក | **ជុំ សុឃឿន** | ០០៨៣៧៧ | ជំនួយការ ឯកឧត្តម អគ្គនាយក អគ្គនាយកដ្ឋាន ភស្តុភារហិរញ្ញវត្ថុ ក្រសួងការពារជាតិ |
| ៥ | វរសេនីយ៍ឯក | **ផាន់ សារឿន** | ០១០៧៣៦ | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ៥១ |
| ៦ | លោក | **អ៊ុំ រាត្រី** | | អភិបាលក្រុង សេរីសោភ័ណ្ឌ ខេត្ត បន្ទាយមានជ័យ |
| ៧ | លោកស្រី | **អ៊ុំច រ៉ាជា** | | អនុប្រធាន នាយកដ្ឋានរដ្ឋបាល ក្រសួងសុខាភិបាល |

**ខ-មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ សេនា :

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | **សន សុផាត** | ០០១០៦១ | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ៥១ |
| ២ | វរសេនីយ៍ឯក | **ជុំ សេដ្ឋា** | ០០១០៧៥ | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ៥១ |
| ៣ | វរសេនីយ៍ឯក | **ឌី ឈុក** | ០០១០២០ | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ៥១ |
| ៤ | វរសេនីយ៍ទោ | **យស ណារ៉ា** | ០០៣០០៧ | នាយសេនាធិការរង កងពលតូចថ្មើរជើងលេខ ៥១ |

| | | | | |
|---|---|---|---|---|
| ៥ | វរសេនីយ៍ទោ | ព្រហ្ម អឿត | ០០០៧៦០ | នាយសេនាធិការរង កងពលតូចថ្មើរជើងលេខ ៥១ |
| ៦ | វរសេនីយ៍ទោ | យ៉េម ឡុំ | ០១០៨១១ | នាយសេនាធិការរង កងពលតូចថ្មើរជើងលេខ ៥១ |
| ៧ | វរសេនីយ៍ទោ | ឡាជ្ជ សំអាន | ០១៤២៦១ | នាយរងការិយាល័យធានា នាយកដ្ឋានប្រេង ក្រសួងការពារជាតិ |
| ៨ | វរសេនីយ៍ទោ | ដាត់ ចិន្តា | ០១០៨១៧ | នាយការិយាល័យទី ១ កងពលតូចថ្មើរជើងលេខ ៥១ |
| ៩ | វរសេនីយ៍ទោ | គង់ ម៉ុនហោ | ០០៣១៩១ | នាយការិយាល័យទី ២ កងពលតូចថ្មើរជើងលេខ ៥១ |
| ១០ | វរសេនីយ៍ទោ | សួរ ចាន់សារ៉េត | ០១០៧៣៣ | នាយការិយាល័យទី ៣ កងពលតូចថ្មើរជើងលេខ ៥១ |
| ១១ | វរសេនីយ៍ទោ | អ៊ួន សំអឿន | ០០៣៧៣៤ | នាយការិយាល័យទី ៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ១២ | វរសេនីយ៍ទោ | ទេព ហ៊ាញ | ០០៣០៨៩ | នាយការិយាល័យទី ៥ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៣ | វរសេនីយ៍ទោ | អ៊ុំ ស៊ីធឿន | ០០៥២៤២ | នាយការិយាល័យហ្វឹកហ្វឺន កងពលតូចថ្មើរជើងលេខ ៥១ |
| ១៤ | វរសេនីយ៍ទោ | សៅ ចន្ថា | ០០៣១០៣ | នាយការិយាល័យអភិវឌ្ឍន៍ កងពលតូចថ្មើរជើងលេខ៥១ |
| ១៥ | វរសេនីយ៍ទោ | ម៉ៅ គីរី | ០០៣៧៤៤ | មេបញ្ជាការ វរសេនាតូច៥១១ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៦ | វរសេនីយ៍ទោ | ពៅ លន់ | ០០៣០៥៨ | មេបញ្ជាការ វរសេនាតូច៥១២ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៧ | វរសេនីយ៍ទោ | ម៉ែត ឡឿង | ០១០៨៣៣ | មេបញ្ជាការ វរសេនាតូច៥១៣ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៨ | វរសេនីយ៍ទោ | ឈឿត ឈាង | ០១៦១៦២ | នាយការិយាល័យហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៩ | វរសេនីយ៍ទោ | ស្រស់ សារឿត | ០០៤៩៨៨ | នាយការិយាល័យ ហ្វឹកហ្វឺន យោធភូមិភាគទី ៥ |
| ២០ | វរសេនីយ៍ត្រី | សាលួត យ៉ាង | ០១៦១៦៩ | នាយរងការិយាល័យទី ១ កងពលតូចថ្មើរជើងលេខ ៥១ |
| ២១ | វរសេនីយ៍ត្រី | ខៃ ខេត្រា | ០១០៧៣៨ | នាយឯកទេសវិស្វកម្ម កងពលតូចថ្មើរជើងលេខ ៥១ |
| ២២ | វរសេនីយ៍ត្រី | ម៉ែត វណ្ណា | ០៣០៦៣០ | នាយរងការិយាល័យហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥១ |
| ២៣ | លោកជំទាវ | យក សម្បត្តិ | | ទីប្រឹក្សាអម ក្រសួងសុខាភិបាល |
| ២៤ | លោក | ឡាយ ហួន | | ប្រធាននាយកដ្ឋាន ថវិកា និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល |
| ២៥ | លោក | គិន វ៉ាន់នី | | អនុប្រធាននាយកដ្ឋាន ថវិកា និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល |
| ២៦ | លោក | សេង គ្លីប | | វិស្វករសំណង់ ក្រសួងសុខាភិបាល |
| ២៧ | លោក | កែវ ឆាយ | | អនុប្រធានមន្ទីរអភិវឌ្ឍន៍ ជនបទ ខេត្ត បន្ទាយមានជ័យ |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ទោ | ហ៊ិន សុធារា | ០០១០៧២ | នាយសេនាធិការរង កងពលតូចថ្មើរជើងលេខ ៥១ |
| ២ | វរសេនីយ៍ទោ | គង់ ធី | ០១០១៧២ | នាយរងការិយាល័យ នាយកដ្ឋានប្រេង ក្រសួងការពារជាតិ |
| ៣ | វរសេនីយ៍ត្រី | សេង ធារិន | ០៤៥៨៣៨ | មេបញ្ជាការ វរសេនាតូច៥១៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ៤ | វរសេនីយ៍ត្រី | សួន វុទ្ធី | ០១០៨១៣ | នាយឯកទេសសុខាភិបាល កងពលតូចថ្មើរជើងលេខ ៥១ |
| ៥ | វរសេនីយ៍ត្រី | ស៊ិន ណុល | ០១៦០៦១ | នាយឯកទេសគីមីសាស្ត្រ កងពលតូចថ្មើរជើងលេខ ៥១ |
| ៦ | វរសេនីយ៍ត្រី | សួរ ចាន់សារ៉ន | ០០៣០៩៥ | មេបញ្ជាការរង វរសេនាតូច៥១២ កងពលតូចថ្មើរជើងលេខ ៥១ |
| ៧ | វរសេនីយ៍ត្រី | ឡុង សាវ៉ន | ០១០៦៨២ | នាយលេខាធិការដ្ឋាន កងពលតូចថ្មើរជើងលេខ ៥១ |
| ៨ | វរសេនីយ៍ត្រី | ខាន់ សុផែន | ០០៣១៤១ | មេបញ្ជាការរង វរសេនាតូច៥១១ កងពលតូចថ្មើរជើងលេខ ៥១ |
| ៩ | វរសេនីយ៍ត្រី | ប៉ែន ចន្ធី | ០១៦១៨២ | នាយរងការិយាល័យទី ៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ១០ | អនុសេនីយ៍ឯក | អ៊ិន សុវណ្ណា | ០៣០៦០២ | ជំនួយការតែងតាំង ការិយាល័យទី ១ កងពលតូចថ្មើរជើងលេខ ៥១ |
| ១១ | អនុសេនីយ៍ឯក | សុខ សុមន្ថា | ០១៦២០៤ | ជំនួយការបុគ្គលិក ការិយាល័យទី ១ កងពលតូចថ្មើរជើងលេខ ៥១ |
| ១២ | អនុសេនីយ៍ឯក | សង សុផាត | ០១៨៥២០ | មេបញ្ជាការ ត.ស៊ើបការណ៍ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៣ | អនុសេនីយ៍ឯក | សេង ពៅ | ០១៥៩៩៨ | មេបញ្ជាការ ត.ការពារអាកាស កងពលតូចថ្មើរជើងលេខ ៥១ |
| ១៤ | អនុសេនីយ៍ឯក | សុន ស៊ីផូ | ០១៦០៥៥ | ជំនួយការប្រេង ការិយាល័យទី ៤ កងពលតូចថ្មើរជើងលេខ ៥១ |

| | | | | |
|---|---|---|---|---|
| ១៥ | អនុសេនីយ៍ឯក | **យោគ ស៊ីថា** | ០១៦១៧២ | ជំនួយការវិន័យទំណាក់ទំនង-សរសេរ ការិ.១ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៦ | លោក | **ឈិញ សិញ** | | សប្បុរសជន ខេត្ត បន្ទាយមានជ័យ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៥៦៩ . អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងនាយទាហាន ចំនួន ៤៦រូប ចំណុះកងពលតូចថ្មើរជើងលេខ៥១ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសការងារ :**

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ត្រី | **ផុន ខេមរា** | ០០៥២៤១ | មេបញ្ជាការរង វរសេនាតូច៥១៣ កងពលតូចថ្មើរជើងលេខ ៥១ |
| ២ | វរសេនីយ៍ត្រី | **ជឹម ស៊ី** | ០១០៨០៧ | នាយរងផ្នែកហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥១ |
| ៣ | វរសេនីយ៍ត្រី | **ចាន់ សុផល** | ០១៤២៧៣ | ផ្នែកផែនការប្រេង នាយកដ្ឋានប្រេង ក្រសួងការពារជាតិ |
| ៤ | វរសេនីយ៍ត្រី | **ហ៊ុន ប្រុស** | ០១៦២១៥ | មេបញ្ជាការរង វរសេនាតូច៥១៣ កងពលតូចថ្មើរជើងលេខ ៥១ |
| ៥ | អនុសេនីយ៍ឯក | **សុខ ឡឿន** | ០៥៣៥៧០ | មេបញ្ជាការរង វរសេនាតូច៥១៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ៦ | អនុសេនីយ៍ឯក | **សួន ស៊ីណា** | ០៣៥២៦២ | មេបញ្ជាការ ត.កាំភ្លើងធំ កងពលតូចថ្មើរជើងលេខ ៥១ |
| ៧ | អនុសេនីយ៍ឯក | **ជឹម សុវណ្ណ** | ០២៦៣៦៥ | មេបញ្ជាការ ត.បញ្ជូនសារ កងពលតូចថ្មើរជើងលេខ ៥១ |
| ៨ | អនុសេនីយ៍ឯក | **លឹម វណ្ណារិទ្ធ** | ០១០៨៣២ | មេបញ្ជាការ ត.គាំទ្រ ឃ.៥១៣ កងពលតូចថ្មើរជើងលេខ ៥១ |

| | | | | |
|---|---|---|---|---|
| ៩ | អនុសេនីយ៍ឯក | ប៉ែន សុគន្ធ | ០១៦១៩៨ | មេបញ្ជាការ គ.៣ ឃ.៥១៣ កងពលតូចថ្មើរជើងលេខ ៥១ |
| ១០ | អនុសេនីយ៍ឯក | ដួង រ៉ែម | ០២៣០២៩ | មេបញ្ជាការ គ.២ ឃ.៥១៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ១១ | អនុសេនីយ៍ឯក | ណែម ពិសិដ្ឋ | ០៣០៦១៣ | ជំនួយការស្បៀង បញ្ជាការដ្ឋាន កងពលតូចថ្មើរជើងលេខ ៥១ |
| ១២ | អនុសេនីយ៍ឯក | ភម សុធា | ០១៦០១៥ | ជំនួយការបុគ្គលិក បញ្ជាការដ្ឋាន កងពលតូចថ្មើរជើងលេខ ៥១ |
| ១៣ | អនុសេនីយ៍ឯក | ជា តិរម្យ | ០១៦១៦៣ | ជំនួយការហិរញ្ញវត្ថុ បញ្ជាការដ្ឋាន កងពលតូចថ្មើរជើងលេខ ៥១ |
| ១៤ | អនុសេនីយ៍ឯក | ខន់ សេខ | ០៤២៣៥០ | មេបញ្ជាការ គ.១ ឃ.៥១១ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៥ | អនុសេនីយ៍ទោ | ឯម សំអុល | ០៥៣០២៩ | ជំនួយការសោធន៍-ឯកសារ ការិ. ១ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៦ | លោក | ខោ ម៉េងជ្រួន | | អភិបាលរង ក្រុងប៉ោយប៉ែត ខេត្ត បន្ទាយមានជ័យ |
| ១៧ | លោក | លឹម ស៊ុណាត | | នាយកក្រឡាបញ្ជីសាលាដំបូង ខេត្ត បន្ទាយមានជ័យ |

ខ_មេដាយប្រាក់ការងារ :

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ត្រី | ជា ឈឹម | ០១០៧៩៥ | ឯកទេសការពារអាកាស កងពលតូចថ្មើរជើងលេខ ៥១ |
| ២ | អនុសេនីយឯក | សាក់ សំអូន | ០១០៧៣៩ | នាយគិលានដ្ឋាន កងពលតូចថ្មើរជើងលេខ ៥១ |
| ៣ | អនុសេនីយ៍ឯក | ឈិន ប៊ុនធន | ០១៩៩៨២ | នាយឯកទេសគ្រឿងចក្រ កងពលតូចថ្មើរជើងលេខ ៥១ |
| ៤ | អនុសេនីយ៍ឯក | ឈឹម សានិត | ០២៣០៤៤ | ជំនួយការឯកសារ ការិ.១ កងពលតូចថ្មើរជើងលេខ ៥១ |
| ៥ | អនុសេនីយ៍ឯក | ហេង ហាន | ០៣២៩១១ | មេបញ្ជាការ គ.វិស្វកម្ម កងពលតូចថ្មើរជើងលេខ ៥១ |
| ៦ | អនុសេនីយ៍ឯក | ឡុយ យ៉ាន | ០១៦០៣០ | នាយឯកទេសបញ្ជូនសារ កងពលតូចថ្មើរជើងលេខ ៥១ |
| ៧ | អនុសេនីយ៍ឯក | លន់ លន | ០១៩៥១៩ | មេបញ្ជាការ គ.១ ឃ.៥១២ កងពលតូចថ្មើរជើងលេខ ៥១ |
| ៨ | អនុសេនីយ៍ឯក | ម្លង់ ហឿប | ០១៩៥១៩ | មេបញ្ជាការ គ.២ ឃ.៥១២ កងពលតូចថ្មើរជើងលេខ ៥១ |
| ៩ | អនុសេនីយ៍ឯក | ម៉ឿង សុខា | ០១៩៥១៩ | មេបញ្ជាការ គ.៣ ឃ.៥១២ កងពលតូចថ្មើរជើងលេខ ៥១ |
| ១០ | អនុសេនីយ៍ឯក | ស៊ូ ពិសី | ០១៦១៨៦ | ជំនួយការបរិក្ខា ការិយាល័យទី ៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ១១ | អនុសេនីយ៍ឯក | គឹម ចាន់ដារ៉ា | ០១៦០១១ | មេបញ្ជាការ គ.គាំទ្រ ឃ.៥១២ កងពលតូចថ្មើរជើងលេខ ៥១ |
| ១២ | អនុសេនីយ៍ឯក | សៀង ហួត | ០១៦១៦៧ | នាយការិយាល័យអភិវឌ្ឍន៍ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៣ | អនុសេនីយ៍ឯក | ខៀវ ស៊ុយ | ០២១៥០០ | មេបញ្ជាការ គ.គាំទ្រ ឃ.៥១៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៤ | អនុសេនីយ៍ឯក | ឌុច ពោ | ០១១៩៣៩ | មេបញ្ជាការ គ.១ ឃ.៥១៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៥ | អនុសេនីយ៍ឯក | ឆួរ សុខុម | ០២១៤៨០ | ជំនួយការអាវុធគ្រាប់ ការិ.ទី៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៦ | អនុសេនីយ៍ទោ | ចាន់ ថាសនា | ០៣០៦១២ | មេបញ្ជាការ គ.៣ ឃ.៥១៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ១៧ | អនុសេនីយ៍ទោ | ម៉ូ សុវណ្ណ | ០៣៥២៧៧ | ឯកទេស សុខាភិបាល កងពលតូចថ្មើរជើងលេខ ៥១ |
| ១៨ | អនុសេនីយ៍ទោ | ចិ ធី | ០៣០៤១៤ | លិខិតស្នាម បញ្ជាការដ្ឋាន កងពលតូចថ្មើរជើងលេខ ៥១ |
| ១៩ | អនុសេនីយ៍ទោ | ឆេង ជឿត | ០៣៥២៥៩ | ជំនួយការបូកសរុប បញ្ជាការដ្ឋាន កងពលតូចថ្មើរជើងលេខ ៥១ |
| ២០ | អនុសេនីយ៍ទោ | ជុំ អ៊ឹម | ០១៦០២២ | ជំនួយការ ហ្វឹកហ្វឺន កងពលតូចថ្មើរជើងលេខ ៥១ |
| ២១ | អនុសេនីយ៍ទោ | ទ៉ាត ឡូត | ០៣០៦១៦ | បុគ្គលិក ពេទ្យ កងពលតូចថ្មើរជើងលេខ ៥១ |
| ២២ | អនុសេនីយ៍ត្រី | អ៊ុក ម៉ារ៉ាឌី | ១៨០២២៣ | ជំនួយការគ្រឿងចក្រ ការិ.ទី ៤ កងពលតូចថ្មើរជើងលេខ ៥១ |
| ២៣ | អនុសេនីយ៍ត្រី | ឆាយ ប៊ុនឡេង | ០៣០៣២៣ | ជំនួយការស្បៀង ការិ.ទី ៤ កងពលតូចថ្មើរជើងលេខ ៥១ |

**គ-មេដាយសិរីវឌ្ឍនការងារ :**

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ត្រី | **គង់ ខន** | ០២៥២៥០ | ផ្នែកជានា ការិ.ធានា នាយកដ្ឋានប្រេង ក្រសួងការពារជាតិ |
| ២ | អនុសេនីយ៍ឯក | **សែម ដារ៉ា** | ០៣៥៧០៦ | មេបញ្ជាការ ត.១ ឃ.៥១៣ កងពលតូចថ្មើរជើងលេខ ៥១ |
| ៣ | អនុសេនីយ៍ឯក | **សុខ លីម** | ០៤២៣៤៩ | ជំនួយការ ការិយាល័យទី ១ កងពលតូចថ្មើរជើងលេខ ៥១ |
| ៤ | អនុសេនីយ៍ទោ | **សាខុន សាគំណូ** | ០៤២៤០៨ | ជំនួយការ ការិយាល័យទី ១ កងពលតូចថ្មើរជើងលេខ ៥១ |
| ៥ | អនុសេនីយ៍ទោ | **អ៊ុក សំបូរ** | ០២១៥២០ | មេបញ្ជាការ ត.២ ឃ.៥១៣ កងពលតូចថ្មើរជើងលេខ ៥១ |
| ៦ | អនុសេនីយ៍ត្រី | **អេង ម៉ានី** | ០៥៣០៩១ | ជំនួយការ ការិយាល័យទី ៤ កងពលតូចថ្មើរជើងលេខ ៥១ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០៩-២៦៨ ប្រក

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រស្តង់ដារ

## របស់ធនាគារជាតិនៃកម្ពុជា

*********

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៥០៨ /៥២៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងប្រកាសលេខ ធ ៩០៨-១៨៦ប្រក ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីមូលប្បទានប័ត្រស្តង់ដារ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## ស ម្រេ ច

**ប្រការ ១ .-**

ដាក់អោយប្រើប្រាស់មូលប្បទានប័ត្រស្តង់ដារថ្មី ចំនួន ០២(ពីរ ) ប្រភេទ គឺមូលប្បទានប័ត្រចារឹកជាប្រាក់រៀលនិងចារឹកជាប្រាក់ដុល្លារអាមេរិក ជំនួសមូលប្បទានប័ត្រដែលកំពុងប្រើបច្ចុប្បន្ននេះ ។

**ប្រការ ២ .-**

មូលប្បទានប័ត្រស្តង់ដារថ្មីនេះ មានលក្ខណៈសម្គាល់ដូចតទៅៈ

**១-លក្ខណៈទូទៅ :**

ក- ទំហំមូលប្បទានប័ត្រមាន : បណ្តោយ ១៨០មម ទទឹង ៩០មម

ខ- ពណ៌នៃមូលប្បទានប័ត្រ :

- មូលប្បទានប័ត្រចារឹកជាប្រាក់រៀល មានពណ៌មាសស្រាល
- មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក មានពណ៌មរកតស្រាល

គ- មូលប្បទានប័ត្រស្តង់ដាររបស់ធនាគារជាតិនៃកម្ពុជា ស្នាក់ការកណ្តាលនិងសាខាមានលក្ខណៈដូចគ្នាទាំងស្រុង លើកលែងតែអាសយដ្ឋានប៉ុណ្ណោះ ។

**២-លក្ខណៈពិសេស :**

សន្លឹកមូលប្បទានប័ត្រ ត្រូវបានបោះពុម្ពដោយក្រដាសពិសេស និងមានលក្ខណៈពិសេសដូចខាងក្រោម :

- មានរូបបណ្តុះ ( Watermark ) ជារូបផ្កាច័ន្ទត្របកមូល ពង្រាយពាសពេញផ្ទៃក្រដាស

- លើផ្ទៃក្រដាសទាំងសងខាង មានរាយបង្កប់កំណាត់សសៃអំបោះពិសេស ( Tissue ) ចំនួនពីរប្រភេទ ក្នុងនោះមួយប្រភេទមើលឃើញ មានពណ៌ទឹកក្រូចនិងពណ៌បៃតង គ្មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយទេ និងមួយប្រភេទទៀតមើលមិនឃើញ មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ទឹកក្រូចនិងពណ៌បៃតង

- ផ្ទៃខាងឆ្វេងនៃសន្លឹកមូលប្បទានប័ត្រ រួមទាំងសញ្ញាធនាគារផង (រូបធំព្រាល១) ត្រូវបានបោះពុម្ពដោយទឹកខ្មៅទិស្សមាន មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌មាសចំពោះមូលប្បទានប័ត្រចារឹកជាប្រាក់រៀល មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌មរកតចំពោះមូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក

- ផ្ទៃកណ្តាលនៃផ្ទៃខាងស្តាំរបស់សន្លឹកមូលប្បទានប័ត្រ ត្រង់ប្រអប់រាងបួនជ្រុងទ្រវែងទាំងពីរ ត្រូវបានបោះពុម្ពដោយទឹកខ្មៅពិសេស មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ស៊ីជម្ពូ

- គំនូសបន្ទាត់ទាំង៦ កំណាត់លើមូលប្បទានប័ត្រ សុទ្ធតែត្រូវបានផ្គុំឡើងដោយអក្សរតូចល្អិត " NATIONALBANKOFCAMBODIA និង

- លេខមូលប្បទានប័ត្រ នៅជ្រុងលើខាងស្តាំ ត្រូវបានបោះពុម្ពដោយទឹកខ្មៅពិសេស ពណ៌ក្រហម មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ។

**ប្រការ ៣ .-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងគ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤ .-**

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ .-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

ភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០០៩

**ទេសាភិបាល**

**ជា-ចាន់តូ**

<u>កន្លែងទទួល</u>

- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

<u>ចម្លងជូន</u>

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័តិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៩-២៧០ ប្រ.ក

# ប្រ កា ស

## ស្តីពី

## ការផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិ នៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាថ្មី ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០០៩

## ស ម្រេ ច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងគ្រប់គ្រងរាល់អាជីវកម្មប្តូរប្រាក់ ដែលកំពុងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

និយមន័យៈ

១- **រូបិយវត្ថុ** សំដៅដល់ប្រាក់រៀលដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ។

២- **រូបិយប័ណ្ណ** សំដៅដល់រូបិយវត្ថុបរទេស ឬមធ្យោបាយទូទាត់ជារូបិយវត្ថុបរទេស ។

៣- **អាជីវកម្មប្តូរប្រាក់** សំដៅដល់ ការទិញ-លក់ប្រាក់រៀលជាមួយនឹងរូបិយប័ណ្ណនានា ឬការទិញ-លក់រូបិយប័ណ្ណមួយ ជាមួយនឹងរូបិយប័ណ្ណផ្សេងៗទៀត ។

**ប្រការ ៣.-**

ប្រតិបត្តិការដែលជាសកម្មភាពប្តូរប្រាក់ រួមមាន :

- ទិញ និងលក់ក្រដាសប្រាក់ជារូបិយប័ណ្ណ
- ទិញមូលប្បទានប័ត្រទេសចរណ៍ ។

**ប្រការ ៤.-**

១- បុគ្គលដែលមានបំណងធ្វើអាជីវកម្មប្តូរប្រាក់ត្រូវតែសុំអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។

២- បុគ្គលដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្មប្តូរប្រាក់ត្រូវមានកាតព្វកិច្ច និងសិទ្ធិ ដូចតទៅ :

ក- ត្រូវមានដើមទុនអប្បបរមាចំនួន ៨0.000.000 រៀល (ប៉ែតសិបលានរៀល) តម្កល់នៅធនាគារជាតិនៃកម្ពុជា ជាអចិន្ត្រៃយ៍ដោយទទួលកម្រៃការប្រាក់ដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា

ខ- មានសិទ្ធិចូលរួមក្នុងការដេញថ្លៃទិញ-លក់ ប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា

គ- មានសិទ្ធិចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ធនាគារជាតិនៃកម្ពុជា លើការសម្គាល់រូបិយប័ណ្ណក្លែងក្លាយ ។

**ប្រការ ៥.-**

១- ពាក្យសុំអាជ្ញាប័ណ្ណត្រូវមានបញ្ជាក់ ឬមានភ្ជាប់ជាមួយនូវ :

ក- នាមករណ៍ យីហោ និងអាសយដ្ឋានធ្វើអាជីវកម្ម

ខ- លិខិតបង់ប្រាក់តម្កល់ដើមទុន

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

២- ពាក្យសុំលិខិតអនុញ្ញាតត្រូវមានបញ្ជាក់ ឬមានភ្ជាប់ជាមួយនូវ :

ក- ឈ្មោះ និងទីលំនៅអចិន្ត្រៃយ៍របស់អ្នកដាក់ពាក្យសុំ

ខ- ទីតាំងធ្វើអាជីវកម្មដោយមានបញ្ជាក់ពីអាជ្ញាធរខណ្ឌ ឬស្រុក និង

គ- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៦.-**

១- ធនាគារជាតិនៃកម្ពុជានឹងពិនិត្យលើពាក្យស្នើសុំក្នុងរយៈពេល ៤៥ថ្ងៃ គិតពីថ្ងៃបានទទួលពាក្យស្នើសុំពេញលេញ ហើយអាចចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ឬបដិសេធពាក្យស្នើសុំនោះ ។

២- អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតមិនអាចផ្ទេរ ឬប្តូរឈ្មោះបានឡើយ ។

៣- អាជ្ញាប័ណ្ណមានសុពលភាពរយៈពេល៣ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាប័ណ្ណ ។

៤- លិខិតអនុញ្ញាតមានសុពលភាពរយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ។

**ប្រការ ៧.-**

១- អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោម :

ក- សោហ៊ុយដាក់ពាក្យសុំអាជ្ញាប័ណ្ណ ចំនួន ១០០.០០០រៀល ( មួយរយពាន់រៀល) ។

ខ- សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំនួន ១.២០០.០០០ រៀល ( មួយលានពីររយពាន់រៀល) ដែលត្រូវបង់នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ ។

គ- ក្នុងរយៈពេល៣០ថ្ងៃមុនអាជ្ញាប័ណ្ណអស់សុពលភាព អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណជាថ្មី ។

ឃ- ក្នុងករណីមិនបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណទាន់ពេលវេលា អ្នកកាន់អាជ្ញាប័ណ្ណនឹងត្រូវរងការពិន័យជាប្រាក់ចំនួន ២០.០០០រៀល (ម្ភៃពាន់រៀល) ក្នុងមួយថ្ងៃ ។ ប្រសិនបើអាជ្ញាប័ណ្ណអស់សុពលភាពរយៈពេល ៣០ថ្ងៃ អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំជាថ្មីឡើយ ។

២- អ្នកដាក់ពាក្យសុំលិខិតអនុញ្ញាតប្តូរប្រាក់ត្រូវបង់សោហ៊ុយដូចខាងក្រោម :

ក- សោហ៊ុយដាក់ពាក្យសុំលិខិតអនុញ្ញាត ចំនួន ១០០.០០០រៀល ( មួយរយពាន់រៀល)

ខ- សោហ៊ុយលិខិតអនុញ្ញាតប្រចាំឆ្នាំ ចំនួន ២០០.០០០ រៀល ( ពីររយពាន់រៀល) ។

គ- ក្នុងរយៈពេល៣០ថ្ងៃមុនលិខិតអនុញ្ញាតអស់សុពលភាព អ្នកកាន់លិខិតអនុញ្ញាតត្រូវដាក់ពាក្យសុំបន្តជាថ្មី ។

៣- ចំពោះបុគ្គលដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណ សោហ៊ុយនឹងត្រូវបានគណនាតាមសមាមាត្រ នៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ ។

៤- អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ត្រូវតែជាកម្មសិទ្ធិរបស់បុគ្គលដែលធ្វើអាជីវកម្មប្តូរប្រាក់ ។

៥- ក្នុងករណីមានទីតាំង ឬអាសយដ្ឋានធ្វើប្រតិបត្តិការច្រើនកន្លែង ទីតាំងធ្វើប្រតិបត្តិការនីមួយៗត្រូវតែមានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ហើយមិនត្រូវប្រកបអាជីវកម្មប្តូរប្រាក់នៅទីកន្លែងណាផ្សេងក្រៅពីអាសយដ្ឋាន ឬទីតាំងដែលបានអនុញ្ញាតឡើយ ។

៦-រាល់ការផ្លាស់ប្តូរអាសយដ្ឋាន ទីតាំងធ្វើប្រតិបត្តិការ កម្មសិទ្ធិធ្វើអាជីវកម្ម ការបិទអាជីវកម្ម និងបើកទីតាំងថ្មី អាជីវករប្តូរប្រាក់ត្រូវតែជូនដំណឹងភ្លាមជាលាយលក្ខណ៍អក្សរដល់ធនាគារជាតិនៃកម្ពុជា ។

រាល់ការកែប្រែទាំងនេះមិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការមុនពេលបានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរពីធនាគារ ជាតិនៃកម្ពុជាឡើយ ។

**ប្រការ ៨.-**

១- អ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត :

ក- ត្រូវលើកយីហោនៅកន្លែងអាជីវកម្មរបស់ខ្លួន ដោយដាក់អក្សរ "ប្តូរប្រាក់" និងអាចដាក់បន្ថែមជាភាសាអង់គ្លេស "Authorized Money Changer" ។

ខ- ត្រូវដាក់បង្ហាញអាជ្ញាប័ណ្ណគ្រប់ពេលវេលាទាំងអស់នៅកន្លែងដែលងាយមើលឃើញនៅក្នុងបរិវេណដែលបានអនុញ្ញាត ។

គ- ត្រូវដាក់បង្ហាញឱ្យសាធារណជនឃើញច្បាស់ជាប្រចាំនូវតារាងអត្រាទិញ-លក់ប្រចាំថ្ងៃរវាងប្រាក់រៀលជាមួយប្រាក់ដុល្លារ និងរវាងប្រាក់ដុល្លារជាមួយនឹងរូបិយប័ណ្ណផ្សេងៗ ។

ឃ- ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមធ្វើអាជីវកម្មប្តូរប្រាក់នៅទីតាំងថ្មី ។

២- អ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ត្រូវគោរពតាមក្រមប្រតិបត្តិដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៩.-**

ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាប័ណ្ណឬលិខិតអនុញ្ញាត បើអ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត :

ក- ល្មើសនឹងខ្លឹមសារនៃប្រកាស និងឧបសម្ព័ន្ធនៃប្រកាសនេះ

ខ- មិនសហការជាមួយធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ ឬ អង្កេត

គ- បានប្រព្រឹត្តការក្លែងបន្លំ និងធ្វើការបំភ័ន្តដោយចេតនា

ឃ- ធ្វើវិច្ឆេទកម្មកេងយកចំណេញដោយការបំប៉ោងអត្រាប្តូរ

ង- ផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យសាធារណជនមានការយល់ច្រឡំ ឬបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល ។

ច- ល្មើសនឹងបទបញ្ញាពាក់ព័ន្ធនឹងច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ ១០.-**

ការខកខានមិនបានអនុវត្តតាមខ្លឹមសារនៃប្រកាសនេះត្រូវទទួលរងទណ្ឌកម្ម យោងតាមមាត្រា ៧០ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១១.-**

ប្រកាសលេខ ធ៩៩៨-៣៩៣ប្រក. ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ចំពោះអាជីវកម្មប្តូរប្រាក់ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១២.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់ នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១៣.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៩

**ទេសាភិបាល**

**ជា_ចាន់តូ**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ១២
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B9-09-230 Pro Kor

*Unofficial Translation*

# PRAKAS
# ON
# MONEY CHANGER LICENSE OR AUTHORIZATION

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26, 1996 promulgating the Law on Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1206/036 of December 29, 2006 promulgating the Law on amendment article 14 and article 57 of the Law on Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram CS/RKM/0897/03 of August 22, 1997 promulgating the Law on Foreign Exchange;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0508/526 of May 13, 2008 on the re-appointment of His Excellency Chea Chanto as Governor of the National bank of Cambodia, as equivalent to senior Minister;
- With reference to the Royal Kram NS/RKM/0607/014 of June 24, 2007 promulgating the Law on Anti-Money Laundering and Combating the Financing of Terrorism.
- Pursuant to the agreement reached at the meeting of the top management of National Bank of Cambodia on October 15, 2009

## DECIDES

**Article 1.-**

The objective of this Prakas is to manage money changer operations carrying out in the Kingdom of Cambodia.

**Article 2.-**

Definitions:

1. **Domestic Currency** refers to the Riel issued by the National Bank of Cambodia.



P.O Box 25, 22-24 Preah Norodom Blvd., Phnom Penh, Cambodia
Phone : 855 23 722563
Fax/Phone : 855 23 426117

2. **Foreign Currency** refers to currencies or mean of payment established by foreign government.

3. **Money Changer Operations** refer to the operations of buying and selling domestic currency in exchange for foreign currencies or buying and selling a foreign currency in exchange for others.

**Article 3.-**

Money changer operations include:

- buying and selling banknotes.
- buying traveller checks

**Article 4.-**

1- Any person who wants to run a money changer operation shall apply for a license or authorization at the National Bank of Cambodia.

2- The applicants shall:

   a. have minimum paid-up capital of KHR 80 million (eighty million Riel) kept in account at the National Bank of Cambodia permanently and it will generate interest set forth by the National Bank of Cambodia.

   b. have the right to participate in the Riel auction conducted by the National Bank of Cambodia.

   c. have the right to participate in the training on detecting counterfeit money organized by the National Bank of Cambodia.

**Article 5.-**

1- The application for license must include:

   a. the legal name and address

   b. evidence of paid-up capital

   c. other information required by the National Bank of Cambodia

2- The application for authorization shall include:

   a. name and permanent address of the applicant

   b. operation address approved by the territory authority, district or commune.

   c. other information required by the National Bank of Cambodia

**Article 6.-**

1- Upon receiving an application, NBC shall issue or refuse issuing the license or authorization at her discretion in 45 days.

2- License or authorization cannot be transferred to another person.

3- License can be used for three years starting from the issuing date.

4- Authorization can be used for one year starting from the issuing date.

**Article 7.-**

1- The license applicant shall pay fees as follows:

a. Application fee of KHR 100,000 (one hundred thousand Riel) ;

b. Annual license fee of KHR 1,200,000 (one million and two hundred thousand Riel) to be paid before January 15 every year.

c. Within 30 days before the expiration of the license, operator shall apply for the license renewal.

d. In case of failing to renew the license in time, the operator shall be fined KHR 20,000 (twenty thousand Riel) per day. If the operator fails to renew the license within 30 days, the National Bank of Cambodia shall not accept the renewal application.

2- The authorization applicant shall pay fees as follows:

a. Application fee of KHR 100,000 (one hundred thousand Riel) ;

b. Annual authorization fee of KHR 200,000 (two hundred thousand Riel).

c. Within 30 days before the expiration of the authorization, operator shall apply for the authorization renewal.

3- Any person who applies for license during the year shall pay the fees calculated with time proportion to the end of the year.

4- The license or authorization shall own by the operator.

5- In case of running multiple operations in many locations or addresses, each location or address shall be licensed or authorized by the National Bank of Cambodia and shall not operate in a other different location .

6- Any change in address, location of operation, ownership, close of operation, and opening new location, operator shall report immediately in writing to the National Bank of Cambodia. In all above changes, operation shall not be allowed before betting the written approval from the National Bank of Cambodia.

**Article 8.-**

1- The holder of license or authorization:

a. shall display operational trade name "ប្តូរប្រាក់" in Khmer and in English "**Authorized Money Changer**"

b. shall display the license at all time in the approved premise which is easily noticeable.

c. shall display to the public the quotation list of the daily exchange rate between Riels and Dollars and between Dollars and other currencies.

d. shall apply for approval from the National Bank of Cambodia prior to commencing business at the new address.

2- The license or authorization holder shall comply with the code of conducts attached to this Pakas.

**Article 9.-**

The National Bank of Cambodia may suspend or revoke the license or authorization, if the holder:

a. violates the meaning of this Prakas and its attachment

b. does not cooperate with the National Bank of Cambodia or relevant authority on their duty of examination or investigation

c. engages in fraud and intentional misrepresentation

d. speculate by manipulating the exchange rates

e. discloses information that lead to the misunderstanding or losing confidence of the public on the national currency.

f. is convicted of a violation of Law on an Anti-money Laundering and Combating the Financing of Terrorism,

**Article 10.-**

Any holder of license or authorization who fail to comply with the provision of this Prakas shall be penalised according to article 70 of the Law on Organization and Conduct of the National Bank of Cambodia.

**Article 11.-**

The Prakas N° B998-393 PRK, dated August 5, 1998 on the Management of Foreign Exchange Dealers is hereby repealed.

**Article 12.-**

The General Direction, the General Secretariat, the General Inspection, the General Cashier and all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the supervisory authority of the National Bank of Cambodia shall strictly implement this Prakas.

**Article 13.-**

This Prakas shall have effect from the signing date.

Phnom Penh, October 19, 2009

**Governor**

**Signed and sealed: CHEA CHANTO**

cc:

- The member of the Board of Directors
- The parties concerned as stated in Article 12
- Archive
- CM "for info."
- Administration
- Department of CM

"for publication in the National Gazette"

## ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៩.០៩ ២៣ ប្រក ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៩

# ក្រមប្រតិបត្តិសម្រាប់អាជីវករប្តូរប្រាក់

## ១.ដែនអនុវត្ត

ក្រមប្រតិបត្តិនេះអនុវត្តចំពោះអាជីវករប្តូរប្រាក់ទាំងអស់ ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អាជីវករប្តូរប្រាក់ត្រូវគោរពតាមក្រមប្រតិបត្តិនេះជាអចិន្ត្រៃយ៍ ។

ធនាគារជាតិនៃកម្ពុជា គឺជាអាជ្ញាធរគ្រប់គ្រងនិងត្រួតពិនិត្យ ដែលនៅក្រោមយុត្តាធិការនេះ អាជីវករប្តូរប្រាក់ត្រូវបានត្រួតពិនិត្យ និងត្រូវបានដាក់ពិន័យ ឬទណ្ឌកម្មចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ បទប្បញ្ញត្តិនានា និងការមិនគោរពតាមគោលការណ៍ដែលមានចែងនៅក្នុងក្រមប្រតិបត្តិនេះ ។

បុគ្គលដែលធ្វើសកម្មភាពជាអាជីវករប្តូរប្រាក់ ត្រូវតែស្នើសុំការអនុញ្ញាត (អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត) ពីធនាគារជាតិនៃកម្ពុជា មុននឹងចាប់ផ្តើមធ្វើប្រតិបត្តិការប្តូររូបិយប័ណ្ណ ។

## ២. ភារកិច្ចរបស់អាជីវករប្តូរប្រាក់

១- អាជីវករប្តូរប្រាក់ដែលបានទទួលអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតត្រូវអនុវត្តដូចតទៅ :

ក- បោះពុម្ពសៀវភៅវិក័យប័ត្រឱ្យហើយជាស្រេច ដែលនៅលើវិក័យប័ត្រនោះត្រូវមាន លេខរៀង ឈ្មោះ នាមករណ៍ យីហោ អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង ។ លេខរៀងនីមួយៗនៃវិក័យប័ត្រនេះត្រូវធ្វើជាពីរច្បាប់ ដែលច្បាប់ដើមសម្រាប់អតិថិជន និងច្បាប់ចម្លងសម្រាប់ទុកជាឯកសាររបស់អាជីវករប្តូរប្រាក់ ។ អាជីវករប្តូរប្រាក់ត្រូវផ្តល់វិក័យប័ត្រឱ្យអតិថិជននៅរាល់ពេលធ្វើប្រតិបត្តិការ ។

ខ- បោះពុម្ពសៀវភៅវិក័យប័ត្រពិសេសមួយទៀតសម្រាប់ការដកហូតប្រាក់ ឬមូលប្បទានប័ត្រទេសចរណ៍ក្លែងក្លាយ ។ លេខរៀងនីមួយៗនៃវិក័យប័ត្រនេះត្រូវធ្វើជាបីច្បាប់ ដែលច្បាប់ដើមសម្រាប់អតិថិជន ច្បាប់ចម្លងមួយសម្រាប់ផ្តល់ឱ្យធនាគារជាតិនៃកម្ពុជាដោយត្រូវភ្ជាប់ជាមួយក្រដាសប្រាក់ ឬមូលប្បទានប័ត្រទេសចរណ៍ក្លែងក្លាយ និងច្បាប់ចម្លងមួយទៀតសម្រាប់ទុកជាឯកសាររបស់អាជីវករប្តូរប្រាក់ ។

គ- មានបុគ្គលិកដែលមានសមត្ថភាពក្នុងការធ្វើវិក័យប័ត្រ ការកត់ត្រា និងធ្វើរបាយការណ៍ជូនធនាគារជាតិនៃកម្ពុជា ។

២- ជាទូទៅ អាជីវករប្តូរប្រាក់ត្រូវតែប្រកាន់ខ្ជាប់នូវភាពសុចរិតផ្នែកវិជ្ជាជីវៈ ដោយមិនក្លែងបន្លំ ឬឆ្លៀតឱកាសពីការមិនយល់ដឹងរបស់អតិថិជន ដើម្បីផ្តល់ប្រាក់ក្លែងក្លាយ ឬបន្លំក្នុងការគណនាចំនួនប្រាក់ដែលអតិថិជនត្រូវបានទទួលជាដើម ។

## ៣- សកម្មភាពហាមឃាត់

ក្រៅពីសកម្មភាពប្តូររូបិយប័ណ្ណ និងទិញមូលប្បទានប័ត្រទេសចរណ៍ អាជីវករប្តូរប្រាក់មិនត្រូវធ្វើប្រតិបត្តិការ ដូចខាងក្រោម :

- ផ្តល់សេវាផ្ទេរប្រាក់
- ជួញដូររូបិយប័ណ្ណដោយការទូទាត់មិនផ្ទាល់ដៃ នៅក្នុងរយៈពេលជាក់លាក់នៅពេលអនាគត
- ជួញដូរមូលប័ត្រ ភាគហ៊ុន និងធ្វើជាជើងសាករ ដោយខ្លួនឯងផ្ទាល់ ឬធ្វើក្នុងនាមអតិថិជន
- ទទួលប្រាក់បញ្ញើពីសាធារណជន
- ផ្តល់ឥណទានដល់សាធារណជន
- ផ្តល់មធ្យោបាយទូទាត់សងប្រាក់ដល់សាធារណជន ។
- ផ្សាយពាណិជ្ជកម្មណាមួយដែលធ្វើឱ្យសាធារណជនយល់ច្រឡំថាខ្លួនផ្តល់សេវាប្រតិបត្តិការខាងលើ
- ជួញដូរក្រដាសប្រាក់ក្លែងក្លាយ

រាល់សកម្មភាពដែលអនុវត្តដោយខុសច្បាប់គឺជាបទឧក្រិដ្ឋនិងត្រូវបានហាមឃាត់ភ្លាមមិនឱ្យធ្វើប្រតិបត្តិការ ហើយអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតជាផ្លូវការរបស់អាជីវករប្តូរប្រាក់នឹងត្រូវបានដកហូត ។

## ៤- ការស្គាល់អតិថិជន

នៅពេលដំណើរការប្តូររូបិយប័ណ្ណ អាជីវករប្តូរប្រាក់ត្រូវស្គាល់អតិថិជនឱ្យបានច្បាស់លាស់ ។ ការស្គាល់អតិថិជននេះត្រូវបានធ្វើឡើងតាមរយៈការតម្រូវឱ្យអតិថិជនផ្តល់លិខិតសម្គាល់ខ្លួនជាផ្លូវការដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុង ឬក្រៅប្រទេស ។ លិខិតសម្គាល់ខ្លួនទាំងនោះ រួមមាន អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងលិខិតសម្គាល់ខ្លួនជាផ្លូវការផ្សេងទៀតដែលមានបិទរូបថត ។

ការសម្គាល់អត្តសញ្ញាណនេះនឹងត្រូវអនុវត្ត ចំពោះ :

- អតិថិជនដែលប្តូរប្រាក់លើសពី ១០.០០០ដុល្លារ (ដប់ពាន់ដុល្លារអាមេរិក)
- អតិថិជនដែលប្តូរប្រាក់មួយលើកៗមានចំនួនតិច ប៉ុន្តែញឹកញាប់ដោយគ្មានមូលហេតុច្បាស់លាស់ ។

ចំពោះអតិថិជនដែលធ្លាប់ធ្វើប្រតិបត្តិការជាធម្មតា និងមានកម្មវត្ថុប្តូរប្រាក់ច្បាស់លាស់ ដូចជា សម្រាប់បង់ពន្ធ បើកប្រាក់បៀវត្ស ឬទិញកសិផល ។ល។ ការសម្គាល់អត្តសញ្ញាណនេះអាចមានលក្ខណៈធូរស្រាលជាង ។

ប្រសិនបើអតិថិជនបដិសេធក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណណាមួយ អាជីវករប្តូរប្រាក់មានសិទ្ធិបដិសេធមិនធ្វើប្រតិបត្តិការបាន ។

## ៥. ក្រដាសប្រាក់ក្លែងក្លាយ

ក្នុងពេលធ្វើប្រតិបត្តិការ អាជីវករប្តូរប្រាក់ត្រូវពិនិត្យមើលក្រដាសប្រាក់ និងមូលប្បទានប័ត្រទេសចរណ៍ដែលបានបង្ហាញសម្រាប់ទិញ ដើម្បីកំណត់នូវអត្តសញ្ញាណក្លែងក្លាយ ។ ប្រសិនបើអាជីវករប្តូរប្រាក់ពិនិត្យឃើញថាក្លែងក្លាយ អាជីវករនោះត្រូវរក្សាទុករូបិយប័ណ្ណក្លែងក្លាយនោះ ហើយចេញជាវិក័យប័ត្រមួយឱ្យទៅអតិថិជនដោយបញ្ជាក់ប្រាប់អតិថិជនថា ខ្លួននឹងបញ្ជូនក្រដាសប្រាក់/មូលប្បទានប័ត្រទេសចរណ៍ មកធនាគារជាតិនៃកម្ពុជា ។

អាជីវករប្តូរប្រាក់ត្រូវពិនិត្យក្រដាសប្រាក់ដែលខ្លួនប្រគល់ទៅឱ្យអតិថិជនដើម្បីកំណត់អត្តសញ្ញាណ និងដកហូតក្រដាសប្រាក់ក្លែងក្លាយចេញពីក្នុងចរាចរណ៍ ។

ក្រដាសប្រាក់ក្លែងក្លាយត្រូវតែបញ្ជូនមកធនាគារជាតិនៃកម្ពុជាភ្លាម១ ដោយភ្ជាប់ជាមួយវិក័យប័ត្រចម្លងមួយច្បាប់ ។ ច្បាប់ដើមត្រូវប្រគល់ឱ្យអតិថិជន ច្បាប់ទីពីរត្រូវរក្សាទុកនៅក្នុងបញ្ជី និងច្បាប់ទី៣ត្រូវរក្សាទុកជាឯកសាររបស់អាជីវករប្តូរប្រាក់ ។ វិក័យប័ត្រនេះត្រូវតែបញ្ជាក់ឱ្យបានច្បាស់អំពីអត្តសញ្ញាណរបស់អតិថិជន អាសយដ្ឋាន ប្រទេសកំពុងស្នាក់នៅ ប្រភេទអត្តសញ្ញាណប័ណ្ណ និងលេខអត្តសញ្ញាណប័ណ្ណ កាលបរិច្ឆេទនិងទីកន្លែងដែលផ្តល់អត្តសញ្ញាណប័ណ្ណនោះ ។

ប្រសិនបើអតិថិជនព្យាយាមលក់ក្រដាសប្រាក់ក្លែងក្លាយជាច្រើនឬក្នុងបរិមាណតិចតួចតែច្រើនដងអាជីវករប្តូរប្រាក់ត្រូវរាយការណ៍ជាបន្ទាន់អំពីបុគ្គលនោះទៅអាជ្ញាធរមានសមត្ថកិច្ច និងទីស្នាក់ការកណ្តាលឬសាខាធនាគារជាតិនៃកម្ពុជា ដែលនៅជិតបំផុត ។

ការបោះផ្សាយ ឬបោះផ្សាយឡើងវិញនូវក្រដាសប្រាក់ក្លែងក្លាយដោយចេតនា និងការរួមគំនិតជួយសម្រួលការធ្វើចរាចរក្រដាសប្រាក់ក្លែងក្លាយគឺជាបទឧក្រិដ្ឋដែលនឹងត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ និងត្រូវបានដកហូតអាជ្ញា-ប័ណ្ណឬលិខិតអនុញ្ញាតធ្វើអាជីវកម្មប្តូរប្រាក់ ។ ដូច្នេះ អាជីវករប្តូរប្រាក់ទាំងអស់ត្រូវធ្វើអាជីវកម្មរបស់ខ្លួនដោយប្រុងប្រយ័ត្នខ្ពស់បំផុត និងត្រូវការពារការធ្វើចរាចរក្រដាសប្រាក់និងមូលប្បទានប័ត្រទេសចរណ៍ក្លែងក្លាយ ។

## ៦. ការប្តូរប្រាក់ និងកាតព្វកិច្ចរាយការណ៍ : ការប្រឆាំងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

អាជីវករប្តូរប្រាក់ជាអ្នកចូលរួមយ៉ាងសកម្មក្នុងទីផ្សារប្តូរប្រាក់ ។ ដូច្នេះអាជីវករប្តូរប្រាក់ត្រូវបានចាត់ទុកជាបុគ្គលរាយការណ៍នៅក្រោមច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងន័យនេះ អាជីវករប្តូរប្រាក់ត្រូវមានកាតព្វកិច្ចក្នុងការអនុវត្តតាមបទប្បញ្ញត្តិដែលបានកំណត់នៅក្រោមច្បាប់នេះ រួមមានកាតព្វកិច្ចសម្គាល់អត្តសញ្ញាណរបស់អតិថិជន រាយការណ៍អំពីប្រតិបត្តិការសង្ស័យ និង ប្រតិបត្តិការប្តូរប្រាក់ ដែលលើសពីកម្រិតដែលកំណត់ ដោយអង្គភាពស៊ើបការហិរញ្ញវត្ថុ ។

គោលបំណងនៃការតម្រូវឱ្យបំពេញកាតព្វកិច្ចទាំងនេះ គឺដើម្បីជួយឱ្យអាជីវករប្តូរប្រាក់ជៀសផុតពីការចូលរួមទាំងដោយចេតនានិងដោយអចេតនាក្នុងសកម្មភាពសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលជាសកម្មភាពឧក្រិដ្ឋដូចមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ។ ដូច្នេះ ដើម្បីប្រកបមុខរបរដោយសុច្ចរិត ជាពលរដ្ឋល្អ និងការពារខ្លួនផុតពីសកម្មភាពខុសច្បាប់ទាំងនោះ អាជីវករប្តូរប្រាក់ត្រូវយកចិត្តទុកដាក់ប្រតិបត្តិតាមបញ្ញត្តិច្បាប់ឱ្យបានម៉ឺងម៉ាត់ ។

នីតិវិធីក្នុងការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នឹងត្រូវបានណែនាំបន្ថែមទៀតដោយអង្គភាពស៊ើបការហិរញ្ញវត្ថុ ។

អាជីវករប្តូរប្រាក់ត្រូវផ្តល់របាយការណ៍ជារៀងរាល់ខែអំពីប្រតិបត្តិការទិញ-លក់រូបិយប័ណ្ណតាមការកំណត់ដូចតទៅ :

ក- ត្រូវធ្វើកំណត់ត្រាដោយបំពេញតាមតារាង១នៃឧបសម្ព័ន្ធនេះ នូវរាល់ប្រតិបត្តិការប្តូរប្រាក់

ខ- ត្រូវបំពេញតាមតារាង២នៃឧបសម្ព័ន្ធនេះ នូវរាល់ការប្តូរប្រាក់ដោយអតិថិជនណាម្នាក់ដែលមានទឹកប្រាក់លើសពី ១០.០០០ដុល្លារ (ដប់ពាន់ដុល្លារអាមេរិក) ឬការប្តូរប្រាក់ញឹកញាប់ដោយអតិថិជនណាម្នាក់ដែលមានទឹកប្រាក់សរុបលើសពី ១០.០០០ដុល្លារ (ដប់ពាន់ដុល្លារអាមេរិក) ។

របាយការណ៍អំពីប្រតិបត្តិការប្រចាំថ្ងៃរបស់អាជីវករប្តូរប្រាក់ត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ) នៅក្នុងសប្តាហ៍ទីពីររៀងរាល់ខែបន្ទាប់ ។

## ៧. ការរក្សាទុកបញ្ជី និងកំណត់ត្រា

១- អាជីវករប្តូរប្រាក់ត្រូវរក្សាទុកសៀវភៅចុះបញ្ជី និងកំណត់ត្រាឱ្យបានត្រឹមត្រូវស្របតាមកាតព្វកិច្ចគ្រប់គ្រងពន្ធដារ ស្តង់ដារវិជ្ជាជីវៈ និងកាតព្វកិច្ចបទប្បញ្ញត្តិនិងគតិយុត្តផ្សេងៗទៀត ។

២- ការចុះបញ្ជីនិងកំណត់ត្រាអំពីសកម្មភាពប្តូររូបិយប័ណ្ណគឺជាកាតព្វកិច្ច ។

៣- អាជីវករប្តូរប្រាក់ដែលកាន់អាជ្ញាប័ណ្ណត្រូវមានសៀវភៅធំ (General Ledger) ដើម្បីកត់ត្រានូវរាល់សកម្មភាពទិញ-លក់រូបិយប័ណ្ណ ។ សៀវភៅនេះត្រូវរក្សាទុកនៅនឹងកន្លែងប្រកបអាជីវកម្ម និងត្រូវអាចទៅរកបានដោយងាយ ក្នុងករណីមានការចុះត្រួតពិនិត្យដល់ទីកន្លែង ។ កំណត់ត្រាដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជានៅពេលធ្វើការត្រួតពិនិត្យដល់ទីកន្លែង ត្រូវមានដូចខាងក្រោម :

- ច្បាប់ចម្លងឯកសារជួញដូរប្រចាំថ្ងៃដែលរៀបតាមលំដាប់លេខរៀង និងកាលបរិច្ឆេទ
- ច្បាប់ចម្លងវិក័យប័ត្រដែលបានចេញឱ្យសម្រាប់ការដកហូតក្រដាសប្រាក់និងមូលប្បទានប័ត្រទេសចរណ៍ក្លែងក្លាយ
- ច្បាប់ចម្លងរបាយការណ៍ប្រតិបត្តិការសង្ស័យដែលបានផ្ញើជូនធនាគារជាតិនៃកម្ពុជា ។

កំណត់ត្រាទាំងអស់ត្រូវរក្សាទុកជាឯកសារ សម្រាប់រយៈពេល ៥ ឆ្នាំ ។

## ៨. ការត្រួតពិនិត្យនិងការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា

ក្រុមការងារត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា អាចចុះទៅត្រួតពិនិត្យដល់ទីកន្លែងរបស់អាជីវករប្តូរប្រាក់ ដោយពុំចាំបាច់ជូនដំណឹងជាមុន ។

អាជីវករប្តូរប្រាក់ទាំងអស់ត្រូវសហការ ដើម្បីសម្រួលដល់ដំណើរការនៃការត្រួតពិនិត្យ និងផ្តល់សៀវភៅចុះបញ្ជី កំណត់ត្រា និងឯកសារជាភស្តុតាងនៃប្រតិបត្តិការផ្សេងៗតាមការស្នើសុំរបស់ក្រុមត្រួតពិនិត្យ ។

ប្រសិនបើអាជីវករប្តូរប្រាក់បង្អាក់ដំណើរការត្រួតពិនិត្យ ឬបដិសេធមិនសហការ តំរិយាបថបែបនេះនឹងត្រូវទទួលរងការពិន័យពីធនាគារជាតិនៃកម្ពុជា ។

អាជីវករប្តូរប្រាក់ទាំងអស់ត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់ និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់បញ្ញត្តិដែលមានចែងនៅក្នុងក្រមប្រតិបត្តិនេះ ។

## ៩. ការបញ្ជាក់អំពីការទទួលយកក្រមប្រតិបត្តិ និងការសន្យាគោរពតាម

អាជីវករប្តូរប្រាក់ទាំងអស់ត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់ និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់បញ្ញត្តិដែលមានចែងនៅក្នុងក្រមប្រតិបត្តិនេះ ។

**ធនាគារជាតិនៃកម្ពុជា**

តារាង១

## គំរូនៃការចុះបញ្ជី
## រាល់ប្រតិបត្តិការប្តូររូបិយប័ណ្ណ

ឈ្មោះអាជីវកម្មប្តូរប្រាក់ : ..................................................................................................

| ថ្ងៃខែប្រតិបត្តិការ | ប្រភេទ និងចំនួន នៃរូបិយប័ណ្ណ | | អត្រាប្តូរប្រាក់ |
|---|---|---|---|
| | ទិញ | លក់ | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

តារាង២

## គំរូនៃការចុះបញ្ជី
## រាល់ប្រតិបត្តិការប្តូររូបិយប័ណ្ណ
## ដែលមានចំនួន ១០,០០០ ដុល្លារអាមេរិក ឬលើស

ឈ្មោះអាជីវកម្មប្តូរប្រាក់ : ........................................................................................................

| ថ្ងៃខែប្រតិបត្តិការ | ឈ្មោះអតិថិជន | សញ្ជាតិ | លេខអត្តសញ្ញាណប័ណ្ណ[1] | ចំនួនប្រតិបត្តិការ (បញ្ជាក់ថាតើចំនួនទិញ ឬលក់រូបិយប័ណ្ណ) | | អត្រាប្តូរប្រាក់ |
|---|---|---|---|---|---|---|
| | | | | ជារូបិយវត្ថុ | ជារូបិយប័ណ្ណ | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

[1] ក្នុងករណីជាអង្គភាពអាជីវកម្ម ត្រូវកត់ត្រានូវឈ្មោះអង្គភាពអាជីវកម្មនោះ និងឈ្មោះ សញ្ជាតិ លេខអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនរបស់បុគ្គលដែលធ្វើប្រតិបត្តិការសំរាប់ ឬក្នុងនាមជាអង្គភាពអាជីវកម្ម

**APPENDIX TO PRAKAS No B 9-09-230 Prok Kor**
**DATED October 19, 2009**
**THE CODE OF CONDUCT FOR MONEY CHANGER OPERATION**

## 1- SCOPE

This code of conduct shall apply for all money changers operating in Cambodia. Money changer shall, at all times, comply with this code of conduct.

The National Bank of Cambodia (NBC) is the regulatory and supervisory authority, and under its jurisdiction, the Money Changers are regulated and shall be sanctioned for any offenses against laws, regulations, and non compliance with the principles set forth in this Code of Conduct.

Any person who operates its business as money changer shall apply for approval (license or authorization) from NBC before starting money changing operation.

## 2- MONEY CHANGER OBLIGATION

i. A licensed or authorized money changer shall be required to have:
   a. A receipt which states the serial numbers, trade name, address, and phone number. Each serial number shall have duplicated pages in which first page is for customer and the second page is for own documentation. Money changer shall provide receipt to customer for all transactions.
   b. A special receipt for seizing counterfeit banknote or traveler check. Each serial number shall have three pages in which the first one is for customer, the second one with the counterfeit banknote is for NBC, and the third one is for own documentation.
   c. Qualified employees who can provide receipt, record, and report to NBC.

ii. In general, money changer shall provide service in fair and professional manner by committing no fraud or taking advantage of customer's low level of knowledge of detecting counterfeit or calculating the amount to be received.

## 3- PROHABITED ACTIVITIES

Money changer shall be strictly prohibited from:

- Providing money transfer services
- Providing forward foreign exchange
- Providing securities brokerage service
- Accepting deposit from the public
- Providing loan to the public
- Providing mean of payment to the public
- Advertising that can make the public misunderstood that he or she provides the above services.
- Dealing counterfeit banknotes

Any activity against the law shall be liable to criminal prosecution and his or her license or authorization shall be revoked.

## 4- DUE DILIGENCE

Money changer shall provide due diligence for all transactions by requesting customer's official identification. The official identifications shall be national identification card, passport, and other identification card with photo.

This due diligence shall be applied for:

- customer with transaction over USD 10,000 (ten thousand US dollars)
- customer who makes smaller transaction for several times without clear purposes.

The customers who make transactions with clear purpose for tax payment, salary payment, or agricultural product purchases, etc. the due diligence shall be applied in a better way.

If customer refuses to disclose the identification, money changer can refuse to provide the service.

## 5- COUNTERFEIT BANKNOTE

In all transactions, money changer shall detect counterfeit banknote and traveler check. If counterfeit banknote and traveler check were detected, money changer shall provide receipt to customer and send the counterfeit to NBC.

Money changer shall detect his or her own banknote in order to prevent counterfeit from circulation.

The counterfeit attached by receipt shall be immediately sent to NBC. The original page shall be given to the customer, the second page for bookkeeping and the third page is for own documentation. The receipt shall record clearly customer identification, address, residential country, type and number of identification card, date and place of issue.

If customer sells a large amount of counterfeit or small amount but for many times, money changer shall report this to the concerned authority and NBC or the nearest NBC branch.

Knowingly issuing or re-issuing counterfeits and complicity to facilitate circulation of counterfeit banknote are liable to criminal prosecution and license or authorization shall be revoked. Therefore, Money Changer is required to exercise utmost care and to refrain from facilitating circulation of counterfeit banknote and traveler check.

## 6- VIGILANCE AND REPORTING OBLIGATION: ANTI-MONEY LAUNDERING AND COMBATING FINANCING OF TERRORISM

Money changer is the active participant in the foreign exchange market. Therefore, money changer is considered to be a reporting person under the law on anti-money laundering and combating financing of terrorism. In this context, money changer has to comply with this law by implementing customer due diligence and reporting the transaction with amount over the limit set forth by the financial intelligence unit.

The purpose of the obligation is to prevent money changer from participating with purpose or without purpose in the activity related to money laundering and financing terrorism which is the criminal activity set forth in criminal law. Money changer shall comply strictly with regulation and law in order to refrain from illegal activities and to be a good citizen.

The procedure for anti-money laundering and financing of terrorism will be provided by the financial intelligence unit.

Money changer shall report on a monthly basis the follows:

a. All transactions shall be recorded as shown in table 1

b. All transaction with the amount over USD 10,000 (ten thousand US dollars) shall be reported as shown in the table 2. Any person who transact frequently amounted to over USD 10,000 (ten thousand US dollars) is also reported in the same manner.

Daily transaction report of the money changer shall be sent to NBC (Exchange Management Department and Financial Intelligence Unit) by the second week of the following month.

## 7- BOOKKEEPING AND RECORDING

i. Money changer shall maintain bookkeeping and recording in compliance with tax obligation, professional standard, and requirement by regulations and other law.
ii. Bookkeeping and recording of foreign exchange transaction is the obligation.
iii. A licensed money changer shall have a general ledger for recording all foreign exchange transactions. The said general ledger shall be kept at the place of operation and can be examined by the authority if needed. Document required by NBC for on-site examination are as followings:
   a. a copy of daily dealing receipts in its order of serial number and date
   b. a copy of receipt issued for customer when there is a counterfeit banknote or traveler check
   c. a copy of suspicious transaction sent to NBC

All records shall be maintained for 5 years.

## 8- NBC SUPERVISION AND EXAMINATION

The examination team of NBC can conduct on-site examination on money changer without prior notice.

Money changers shall cooperate and facilitate the examination process and provide all bookkeeping, records and other transactions' evidence material requested by the team.

If money changer obstructs the examination process or refuse to cooperate, such behaviors shall be liable to sanctions determined by the NBC.

## 9- ACEPTANCE OF THE CODE OF CONDUCT

Money changer shall clearly understand and strictly implement all articles set forth in this code of conduct.

National Bank of Cambodia

Table 1

# Foreign Exchange Recording Form

Name of Money Changer:.......................................................

| Transaction Dates | Types and Amount of Currencies | | Exchange Rates |
|---|---|---|---|
| | Buying | Selling | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

Table 2

**Foreign Exchange Recording Form**
**For Transaction over USD 10,000**

Money Changer Name:......................................................................

| Transaction Date | Customer Name | Nationality | ID No.[1] | No. Transactions (buying or selling amount) | | Exchange Rate |
|---|---|---|---|---|---|---|
| | | | | National Currency | Foreign Currency | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

[1] In case of Business Unit, its business name and name, nationality, identification card number or passport number of the person who does the operation for or in the name of the business unit.